ចលនាលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា
ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍

ថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

ខែតុលា ឆ្នាំ២០២៦

ស្កេនដើម្បីអាន

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”)

របាយការណ៍ស្តីពី “សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា” (“របាយការណ៍”) ជាការបោះពុម្ពផ្សាយរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (“គម្រោង”) នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”)។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល (“អង្គការ”) ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។

ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាព ដែលប្រជាពលរដ្ឋទាំងអស់អាចទទួលបានសិទ្ធិមនុស្សមូលដ្ឋាន ទទួលបាននីតិរដ្ឋដែលគ្មាននិទណ្ឌភាព ទទួលបានការគោរពដោយស្មើភាពគ្នា គ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាច ដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជាប្រកបដោយចីរភាព។

ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌សកំពុងហើរចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យ ថាជាការទាមទារសេរីភាពនៅកម្ពុជា។

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក

គម្រោងនេះ គឺជាគម្រោងបន្តពីគម្រោងសង្កេតសវនាការ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌របស់ ម.ស.ម.ក ដែលមានគោលដៅគាំទ្រសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមានគោលបំណងចម្បងចំនួនពីរៈ ទី១បង្កើនការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងប្រព័ន្ធតុលាការ និងទី២ ផ្សព្វផ្សាយគោលគំនិតអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។ ក្នុងគោលបំណងទី១ គម្រោងបានធ្វើការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ហើយជាលទ្ធផលបានបោះពុម្ពផ្សាយនូវរបាយការណ៍ និងធ្វើការតស៊ូមតិដោយផ្អែកលើកស្តុតាង ដើម្បីបង្កើននូវការគោរពតាមបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការ និងវិស័យយុត្តិធម៌នៅកម្ពុជា។ គម្រោងបាននឹងកំពុងសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៣ មក ហើយនៅសាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ ចាប់តាំងពីខែមិថុនា/កក្កដា ឆ្នាំ២០២២។ នេះគឺជារបាយការណ៍ប្រចាំឆ្នាំ

លើកទីដប់ដែលគម្រោងបានផលិតឡើង និងជារបាយការណ៍ទីបួនដែលបានបញ្ចូលទិន្នន័យពីការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ទាំងអស់។

ក្នុងគម្រោងនេះ ម.ស.ម.ក ក៏បានផលិត**កម្រងមេរៀន**ដែលមានសេចក្តីពន្យល់ពេញលេញ វីដេអូ ខិត្តប័ណ្ណព័ត៌មាន និងសំណួរអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផងដែរ។ កម្រងមេរៀននេះអាចស្វែងរកបាននៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជា (www.sithi.org)។

សំណួរ និងមតិចូលរួម

លោកអ្នកអាចស្វែងរករបាយការណ៍នេះ និងរបាយការណ៍មុនៗនៅលើគេហទំព័ររបស់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ www.cchrcambodia.org និងនៅលើគេហទំព័រ Sithi Portal។ ប្រសិនបើលោកអ្នកមានចម្ងល់ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org ។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ទូរស័ព្ទលេខ៖ +៨៥៥(០)២៣ ៧២ ៦៩ ០១

CC BY NC SA

មាតិកា

អក្សរកាត់ និងបញ្ជីពាក្យ 6

ខ្លឹមសារសង្ខេប 7

១. សេចក្តីផ្តើម 9

១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ 9

១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ 9

១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា 10

១.២ វិសាលភាព និងវិធីសាស្ត្រ 13

២.ទិដ្ឋភាពទូទៅ 18

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការទាំងអស់បានគោរព 21

៣.១ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រាប់គ្រាន់ដើម្បីរៀបចំការពារក្តី 21

៣.២ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ 22

៣.៣ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ 23

៣.៤ សិទ្ធិមានវត្តមាននៅពេលសវនាការ 28

៣.៥ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល 33

៣.៦ ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី 38

៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការមួយចំនួនបានគោរព 45

៤.១ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ 45

៤.២ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស 51

៤.៣ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង 61

៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរពពេញលេញ 69

៥.១ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ 69

៥.២ សិទ្ធិទទួលបានមេធាវី 72

៥.៣ សិទ្ធិមានសេរីភាព 78

៥.៤ សិទ្ធិបង្ហាញកស្តុតាង 84

៥.៥ សិទ្ធិកុមារទំនាស់នឹងច្បាប់ 88

៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ 94

៦.១ អនុសាសន៍រួម 94

៦.២ អនុសាសន៍ស្តីពីសិទ្ធិទទួលបានមេធាវី 95

៦.៣ អនុសាសន៍ទាក់ទងនឹងសិទ្ធិមានសេរីភាព 96

៦.៤ អនុសាសន៍ស្តីពីសិទ្ធិបង្ហាញកស្តុតាង 96

៦.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ 97

៦.៦ អនុសាសន៍សិទ្ធិមានវត្តមានក្នុងសវនាការ 97

៦.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស 97

៦.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព 98

៦.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ 98

៦.១០ អនុសាសន៍ទាក់ទងនឹងវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី 99

៦.១១ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់ 99

អក្សរកាត់ និងបញ្ជីពាក្យ

គណៈមេធាវី	គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
ម.ស.ម.ក	មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
តារាងសង្កេតការសវនាការ	តារាងសង្កេតសវនាការប្រើដោយ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការ
ការណែនាំអំពីតារាងសង្កេតសវនាការ	ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ឱ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតសវនាការ
ក្រមសីលធម៌	ជាឯកសារកំណត់អំពីការកិច្ចមិនជ្រៀតជ្រែក មិនលម្អៀង និងរក្សាការសម្ងាត់ដែលអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ត្រូវគោរពតាម
រដ្ឋធម្មនុញ្ញ	រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
អ.ស.ក	អនុសញ្ញាស្តីពីសិទ្ធិកុមារ
ប្រព័ន្ធគ្រប់គ្រងទិន្នន័យ	ប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការដែលបានកត់ត្រាលើតារាងសង្កេតការសវនាការ
ក.អ.ស.ព.ន	កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
ស.ស.ស.ម	សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស
ច្បាប់រៀបចំអង្គការតុលាការ	ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
ច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម	ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
ច្បាប់លក្ខន្តិក:ចៅក្រម និងព្រះរាជអាជ្ញា	ច្បាប់ស្តីពីលក្ខន្តិក:នៃចៅក្រម និងព្រះរាជអាជ្ញា
រដ្ឋាភិបាល	រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
ការិយាល័យឧត្តមស្នងការ	ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស
អំឡុងពេលគម្រោង	ចាប់ពីខែមករា ឆ្នាំ២០២៥ ដល់ខែធ្នូ ឆ្នាំ២០២៥

ខ្លឹមសារសង្ខេប

ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌចំនួន ៤២២ នៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ[1] ដើម្បីវាយតម្លៃកម្រិតនៃការអនុវត្តក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលមានចែងក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញអំពីការវិភាគទិន្នន័យដែលប្រមូលបាន និងប្រៀបធៀបជាមួយនឹងរបាយការណ៍មុនៗ ក្នុងគោលបំណងដើម្បីរួមចំណែកលើកកម្ពស់តម្លាភាព គណនេយ្យភាព និងពង្រឹងដំណើរការគ្រប់គ្រងយុត្តិធម៌ក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះបង្ហាញថាជាលើកទីមួយចាប់តាំងពី ម.ស.ម.ក បានសង្កេតសវនាការនៅសាលាឧទ្ធរណ៍នៅឆ្នាំ២០២២ ដែលសាលាឧទ្ធរណ៍ទាំងបួនបានលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួនប្រាំមួយ៖ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិមានវត្តមានពេលសវនាការ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ និងរង្វាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី។ គួរឱ្យលើកទឹកចិត្តផងដែរដែលមិនមានតុលាការណាមួយ បានខកខានក្នុងការលើកកម្ពស់សិទ្ធិដែលបានគោរពនៅឆ្នាំ២០២៤ នោះឡើយ។

គួរឱ្យកត់សម្គាល់ផងដែរថា មានសិទ្ធិចំនួនបីនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានតុលាការទាំងបួន បានលើកកម្ពស់នោះទេ នៅឆ្នាំ២០២៥។ សិទ្ធិទាំងបីនេះរួមមាន ដូចជា សិទ្ធិទទួលបានមេធាវី សិទ្ធិមានសេរីភាព និងសិទ្ធិបង្ហាញភស្តុតាង។ ចំពោះសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនត្រូវបានសាលាឧទ្ធរណ៍ភ្នំពេញលើកកម្ពស់នោះទេ រីឯសាលាឧទ្ធរណ៍ចំនួនបីផ្សេងទៀតមិនមានទិន្នន័យគ្រប់គ្រាន់ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃចំពោះសិទ្ធិនេះទេ។ ចំពោះការលើកកម្ពស់សិទ្ធិមានសេរីភាពនៅតុលាការគោលដៅទាំងបួន មានការថយចុះ ដែលជាទូទៅការឃុំខ្លួនមានការកើនឡើងចាប់ពីឆ្នាំ២០២៤ មានជនជាប់ចោទប្រាំមួយនាក់ក្នុងចំណោមប្រាំពីរនាក់ត្រូវបានឃុំខ្លួន។ រីឯសិទ្ធិបង្ហាញភស្តុតាងវិញ គឺមិនមានបង្ហាញភស្តុតាងជាកោសលវិច័យ និងវេជ្ជសាស្ត្រ ក្នុងចំណោមសំណុំរឿងចំនួន ៤២២ ដែលសង្កេតនៅឆ្នាំ២០២៥។ កង្វះនូវទម្រង់នៃភស្តុតាងទាំងនេះអាចប៉ះពាល់ដល់ភាពគ្រប់ជ្រុងជ្រោយក្នុងដំណើរការនីតិវិធីទាំងមូល។ ក្នុងចំណោមសវនាការទាំងអស់ដែលបានសង្កេត មានចំនួន ៩៣ % បានប្រើរយៈពេលសួរដេញដោលក្នុងសវនាការនីមួយៗតិចជាង ឬស្មើមួយម៉ោង រីឯចំនួន ៧% ផ្សេងទៀតនៃសវនាការទាំងនោះមានរយៈពេលលើសពីមួយម៉ោង។

[1] គម្រោងនេះបានចាប់ផ្តើមសង្កេតសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងនៅសាលាឧទ្ធរណ៍ព្រះសីហនុ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២២។

សាលាឧទ្ធរណ៍ភ្នំពេញបង្ហាញពីវឌ្ឍនភាពពីមួយឆ្នាំទៅមួយឆ្នាំ ដោយបានលើកកម្ពស់សិទ្ធិចំនួនប្រាំបី នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បើធៀបនឹងឆ្នាំ២០២៤ មានចំនួនប្រាំពីរ។ គួរកត់សម្គាល់ថា សិទ្ធិដែលបានលើកកម្ពស់បន្ថែមមួយទៀតនោះក្នុងឆ្នាំ២០២៥ គឺសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ មានចំនួន ៨៦% នៃសវនាការបានចំណាត់ការក្នុងអំឡុងពេលតិចជាង ៦ ខែគិតពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍ត្បូងឃ្មុំបានអនុវត្តគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់សិទ្ធិចំនួនប្រាំបួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយសិទ្ធិបន្ថែមថ្មីដែលបានគោរពឆ្នាំ២០២៥ គឺសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ ក្នុងឆ្នាំ២០២៣ សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានលើកកម្ពស់សិទ្ធិចំនួនបួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាលាឧទ្ធរណ៍នីមួយៗ នេះបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។

សាលាឧទ្ធរណ៍បាត់ដំបង ក៏បង្ហាញនូវវឌ្ឍនភាពប្រសើរផេងដៃក្នុងចំណោមតុលាការគោលដៅទាំងបួន ដោយបានលើកកម្ពស់សិទ្ធិចំនួនប្រាំបីនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហើយបើធៀបនឹងឆ្នាំ ២០២៤ មានតែចំនួនប្រាំប៉ុណ្ណោះ។ សិទ្ធិបន្ថែមចំនួនបីដែលបានលើកកម្ពស់ក្នុងឆ្នាំ២០២៥ នោះ គឺសិទ្ធិមានវត្តមានពេលសវនាការ វិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា និងមេធាវី និងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ សាលាឧទ្ធរណ៍ព្រះសីហនុក៏បានលើកកម្ពស់សិទ្ធិចំនួនប្រាំពីរនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានការកើនឡើងធៀបនឹងឆ្នាំ២០២៤ មានតែចំនួនប្រាំមួយ។ នេះជាឆ្នាំទីពីរហើយដែលមិនមានទិន្នន័យគ្រប់គ្រាន់ក្នុងការវាយតម្លៃពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់។ នៅឆ្នាំ ២០២៥ សំណុំរឿងដែល ម.ស.ម.ក បានសង្កេតមានតែកុមារចំនួនប្រាំបួននាក់ប៉ុណ្ណោះ។

១. សេចក្តីផ្តើម

១.១ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសសរស្តម្ភស្នូលនៃនីតិរដ្ឋ និងជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ សិទ្ធិនេះមានវិសាលភាពហួសពីសវនាការលើបុគ្គលម្នាក់ៗ ដោយហេតុថាការលើកកម្ពស់ ឬការរំលោភសិទ្ធិនេះ នឹងឆ្លុះបញ្ចាំងអំពីគុណភាព និងស្ថានភាពនៃប្រព័ន្ធច្បាប់ក្នុងដែនយុត្តាធិការដែលប្រកាន់ខ្ជាប់នូវនីតិរដ្ឋ។ ធាតុផ្សេងៗនៃសិទ្ធិទាំងនេះ មានគោលបំណងធានានូវភាពត្រឹមត្រូវ និងតម្លាភាពក្នុងការអនុវត្តច្បាប់ ដើម្បីធានាសិទ្ធិរបស់ជនជាប់សង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ ដើម្បីជាផលប្រយោជន៍ដល់សង្គមទាំងមូល។ ធាតុទាំងនោះ រួមបញ្ចូលក្នុងដំណើរការនៃនីតិវិធីព្រហ្មទណ្ឌទាំងមូល ដោយគិតពីពេលចាប់ផ្តើមនីតិវិធី ឬការឃាត់ខ្លួនជនសង្ស័យ រហូតដល់បណ្តឹងតវ៉ាជាស្ថាពរត្រូវបានបញ្ចប់។[2]

១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ

មូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានចែងក្នុងមាត្រា១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (“ស.ស.ស.ម”) និងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.អ.ស.ព.ន”) ក្នុងចំណោមលិខិតបកររណ៍ផ្សេងៗទៀត។[3] មាត្រា ១០ នៃ ស.ស.ស.ម និងមាត្រា ១៤ (១) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។ ក.អ.ស.ព.ន ពន្យល់បន្ថែមអំពីធាតុផ្សេងៗទៀតនៃការជំនុំជម្រះដោយយុត្តិធម៌ដែលមានជាអាទិ៍ដូចជា សិទ្ធិ និងគោលការណ៍ ដូចតទៅ (សំដៅដល់ “សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌”)៖ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីរបស់ខ្លួនមុនពេលជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិមានមេធាវី សិទ្ធិទទួលបានការការពារប្រឆាំងនឹងការឆ្លើយដាក់បន្ទុកលើខ្លួនឯង និងសិទ្ធិប្តឹងតវ៉ាទៅតុលាការជាន់ខ្ពស់ដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់។

---

[2] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក “តើអ្វីជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌?” (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/bdfnh66h

[3] ស.ស.ស.ម (ឆ្នាំ១៩៤៨); ក.អ.ស.ព.ន (ឆ្នាំ១៩៦៦); មាត្រា ៨ នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៦៩); មាត្រា ៧ នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងប្រជាជន (ឆ្នាំ១៩៨១) មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៥០) មាត្រា ៤៧-៥០ នៃធម្មនុញ្ញអឺរ៉ុបស្តីពីសិទ្ធិជាមូលដ្ឋានរបស់សហភាពអឺរ៉ុប (ឆ្នាំ២០០០)។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នទៅលើ ក.អ.ស.ព.ន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ហើយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានបញ្ចូលកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជា។[4] ដូច្នេះ បញ្ញត្តិនៃ ក.អ.ស.ព.ន ត្រូវអនុវត្តដោយផ្ទាល់ក្នុងតុលាការកម្ពុជា ដូចបានបញ្ជាក់ក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ២០០៧។[5] នៅក្នុងការពិនិត្យចុងក្រោយបំផុតរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២២ អំពីការអនុវត្តនូវសិទ្ធិមនុស្សដែលអនុលោមទៅនឹង ក.អ.ស.ព.ន. របស់គណៈកម្មាធិការសិទ្ធិមនុស្សបានបង្ហាញនូវការព្រួយបារម្ភមួយចំនួនទាក់ទងនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលរួមមាន ការចោទប្រកាន់ពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិមិនត្រឹមត្រូវនៅកន្លែងឃាត់ខ្លួនរបស់នគរបាលយុត្តិធម៌ និងមន្ទីរឃុំឃាំង ការឃុំខ្លួនបណ្តោះអាសន្នលើមនុស្សជាច្រើន និងឯករាជ្យភាពរបស់តុលាការ។[6]

១.១.២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់កម្ពុជា

ក្របខ័ណ្ឌគ្រឹះសម្រាប់ការជំនុំជម្រះដោយយុត្តិធម៌មានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះផ្តល់ឱ្យមានការបែងចែកអំណាច និងប្រព័ន្ធតុលាការឯករាជ្យ ដែលធានានូវសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ដូចខាងក្រោម៖

- គ្មានការរំលោភបំពានលើរូបរាងកាយបុគ្គលណាម្នាក់ឡើយ។
- គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោស ចាប់ខ្លួន ឬឃុំខ្លួនឡើយ លើកលែងតែធ្វើឡើងស្របតាមច្បាប់។
- ហាមដាច់ខាតចំពោះការបង្ខិតបង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយ ឬការធ្វើទុក្ខទោសផ្សេងៗដែលដាក់ទណ្ឌកម្មបន្ថែមលើជននៅក្នុងឃុំ ឬជនជាប់ឃុំ។
- ចម្លើយសារភាពដែលទទួលបានតាមរយៈការបង្ខំលើរាងកាយ ឬផ្លូវចិត្ត មិនត្រូវបានទទួលស្គាល់ជាភស្តុតាងនៃពិរុទ្ធភាពឡើយ។
- រាល់វិមតិសង្ស័យដែលកើតឡើងនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ។
- ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោស រហូតទាល់តែតុលាការសម្រេចជាស្ថាពរលើសំណុំរឿងនោះ។
- ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិការពារខ្លួនតាមរយៈបណ្តឹងឧប្រាស្រ័យទៅតុលាការ។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមព្រហ្មទណ្ឌ”) ចែងអំពីប្រភេទបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។[7] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមនីតិវិធីព្រហ្មទណ្ឌ”) ចែងលម្អិតអំពីការប្រព្រឹត្តចំពោះជនសង្ស័យ ជនត្រូវចោទ និងជន

---

[4] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា (ឆ្នាំ១៩៩៣) https://tinyurl.com/58rn4thj

[5] សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ២, https://tinyurl.com/3p3z9zzn

[6] គណៈកម្មាធិការសិទ្ធិមនុស្ស (HRC), “សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយលើកទីបីរបស់កម្ពុជា (CCPR/C/KHM/CO/3), វាក្យខណ្ឌ ២២, ២៦, ៣២

[7] ក្រមព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០១០), https://tinyurl.com/2hrdjbf7

ជាប់ចោទ។[8] ក្រមនេះ ចែងអំពីតួនាទី និងទំនួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីការពារក្តី ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតដំបូងរហូតដល់ពេលឃាត់ខ្លួន និងក្នុងអំឡុងពេលនៃដំណើរការរឿងក្តីព្រហ្មទណ្ឌទាំងមូល រហូតដល់បណ្តឹងតវ៉ាបញ្ចប់ជាស្ថាពរ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦[9] ចែងអំពីបទដ្ឋាន និងនីតិវិធីសម្រាប់ដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ និងការពារសិទ្ធិរបស់ពួកគេក្នុងអំឡុងពេលដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ។[10]

បន្ថែមលើនេះ ច្បាប់គ្រឹះចំនួនបីទាក់ទងនឹងតុលាការ ពោលគឺច្បាប់ស្តីពីការរៀបចំអង្គការតុលាការ[11] ច្បាប់ស្តីពីលក្ខន្តិក:ចៅក្រម និងព្រះរាជអាជ្ញា[12] និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[13] ដែលបានអនុម័តក្នុងឆ្នាំ២០១៤ ក្នុងគោលបំណងពង្រឹងនូវឯករាជ្យ តម្លាភាពរបស់តុលាការ និងការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋកម្ពុជា។ យ៉ាងណាក្តី ច្បាប់ទាំងនេះទទួលរងនូវការរិះគន់ថាបានធ្វើឱ្យចុះខ្សោយនូវការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការ។[14]

គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បានកត់សម្គាល់នូវការវិឌ្ឍមួយចំនួនក្នុងឆ្នាំ២០២៥ ដែលពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងប្រទេសកម្ពុជា។

- ខែមករា ឆ្នាំ២០២៥ ក្រសួងយុត្តិធម៌បានប្រកាសថាបានបង្កើតក្រុមស្រាវជ្រាវ វិភាគគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលមានសមាសភាពចំនួន ១២ រូប ទទួលខុសត្រូវស្រាវជ្រាវ វិភាគ និងផ្តល់យោបល់លើគោលនយោបាយ និងយុទ្ធសាស្ត្រទាក់ទងនឹងកំណែទម្រង់តុលាការ។
- នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥ អ្នកទទួលការងារនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ចំនួនពីររូប (អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់ចៅក្រម និងមេធាវី) Margaret Satterthwaite និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ចេញបណ្តឹងជាផ្លូវការណ៍ទៅរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹង«ការកង្វះការទទួលបានជំនួយផ្នែកច្បាប់នៅកម្ពុជា ដោយសារតែបញ្ហានៃវិជ្ជាជីវៈផ្នែកច្បាប់ និងកង្វះនូវការទទួលបានជំនួយមេធាវីដោយឥតគិតថ្លៃ»។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបាន

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") (ឆ្នាំ២០១៧), https://tinyurl.com/3tk7sk6c

[9] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦), https://tinyurl.com/2vxr7293

[10] យូនីសេហ្វ "សំណួរ-ចម្លើយអំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅកម្ពុជា" (ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦), https://tinyurl.com/46ftzbjk

[11] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ (ឆ្នាំ២០១៤), https://tinyurl.com/csk3c96f

[12] ច្បាប់ស្តីពីលក្ខន្តិក:នៃចៅក្រម និងព្រះរាជអាជ្ញា (ឆ្នាំ២០១៤), https://tinyurl.com/y8zhk6yc

[13] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ឆ្នាំ២០១៤), https://tinyurl.com/yc2t8kwz

[14] ម.ស.ម.ក គោលដៅយុត្តិធម៌ API អាដហុក អង្គការតម្លាភាពកម្ពុជា និង IFEX "របាយការណ៍រួមស្តីពីសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា"(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨),https://tinyurl.com/545deb9s; ម.ស.ម.ក "ការវិភាគលើសេចក្តីព្រាងច្បាប់ចំនួនបីទាក់ទងនឹងតុលាការ" (ឆ្នាំ២០១៤), https://tinyurl.com/jzmpp4un; សូមមើលផងដែរ មតិយោបល់របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សលើសេចក្តីព្រាងច្បាប់គ្រឹះចំនួនបីទាក់ទងនឹងតុលាការ (ខែឧសភា ឆ្នាំ២០១៤)៖ https://tinyurl.com/ys4jypw5; https://tinyurl.com/yt3ud573; https://tinyurl.com/yufd4442.

ឱ្យដឹងថា «ជំនួយផ្នែកច្បាប់នៅកម្ពុជារងផលប៉ះពាល់យ៉ាងខ្លាំងដោយពុំមានការផ្តល់ឱ្យនូវមូលនិធិពីអាជ្ញាធរ និងមិនមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ស្តីពីគោលនយោបាយជំនួយផ្នែកច្បាប់ និងការមិនមានគោលនយោបាយជាតិស្តីពីជំនួយផ្នែកច្បាប់ «អាចជាច្រកមួយនាំឱ្យមានការរំលោភជាប្រព័ន្ធលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសមភាពចំពោះមុខច្បាប់» របាយការណ៍បានបង្ហាញផងដែរថា ជំនួយផ្នែកច្បាប់បានផ្តល់ឱ្យតែជនជាប់ចោទដែលបានចោទប្រកាន់ពីបទឧក្រិដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាជំនួយផ្នែកច្បាប់ គឺមិនមានក្នុងគោលនយោបាលជាផ្លូវការរបស់រាជរដ្ឋាភិលបាលនោះទេ ដែលនេះនាំឱ្យរងផលប៉ះពាល់យ៉ាងខ្លាំងនៅពេលដែលមូលនិធិគាំទ្រមិនត្រូវបន្តផ្តល់ឱ្យដោយម្ចាស់ជំនួយ។

- ក្នុងរបាយការណ៍ប្រចាំឆ្នាំផ្ញើទៅក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិខែតុលា ឆ្នាំ២០២៥ របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សប្រចាំកម្ពុជា លោកសាស្ត្រាចារ្យ Vitit Muntarbhorn មានការបារម្ភមួយចំនួនទាក់ទងនឹងដំណើរការប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។[15] របាយការណ៍ក៏បានបង្ហាញផងដែរថា «ការប្រឈមនៅតែបន្តកើតមានចំពោះការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងពន្ធនាគារ» ដោយកត់សម្គាល់ថា មានបញ្ហាមួយដែលគួរត្រូវដោះស្រាយនៅក្នុងរបាយការណ៍មុននៃអាណត្តិរបស់គាត់ដែលនៅតែបន្តមាន នេះបង្ហាញពីកង្វះការកែចម្រើនគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណាក៏ដោយ អ្នករាយការណ៍ពិសេសបានបន្ថែមថា «លោកបានយល់ពីការខិតខំប្រឹងប្រែងរបស់អាជ្ញាធរក្នុងការគាំទ្រវិធីសាស្ត្រផ្សេងជាជំនួសក្នុងការដោះស្រាយវិវាទ ព្រមទាំងការកាត់បន្ថយភាពចង្អៀតណែនក្នុងពន្ធនាគារផងដែរ»។ អ្នករាយការណ៍ពិសេសបានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជាថា "គួរពិនិត្យលើស្ថាប័នតុលាការ រួមទាំងបង្កើតនូវវិធានទាំងឡាយឱ្យមានភាពច្បាស់លាស់ចំពោះសកម្មភាពរបស់ចៅក្រម និងព្រះរាជអាជ្ញាដែលពួកគេមិនបានប្រកាន់ខ្ជាប់តាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងធានាថាតុលាការត្រូវប្រតិបត្តិតាមភាពត្រឹមត្រូវនៃនីតិវិធីច្បាប់ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌»។ របាយការណ៍បានលើកឡើងបន្ថែមថា រាជរដ្ឋាភិបាល «ត្រូវធានានូវការផ្តល់សំណងប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបំពាននៅពេលដែលអំពើនោះកើតឡើងលើបុគ្គលណាម្នាក់ រួមទាំងពង្រឹងប្រព័ន្ធតុលាការដើម្បីបញ្ចប់អំពើនិទណ្ឌភាពប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តិដោយឃោរឃៅ អមនុស្សធម៌ ឬបន្ទោកបន្ទាប»។ ជាការឆ្លើយតបទៅនឹងរបាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកម្ពុជា តាមរយៈបេសកកម្មអចិន្ត្រៃយ៍របស់ខ្លួនប្រចាំអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ បានចេញសេចក្តីថ្លែងការណ៍មួយកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ

[15] លោក សាស្ត្រាចារ្យ Vitit Muntarbhorn បានលាលែងជាផ្លូវការពីតួនាទីជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សប្រចាំកម្ពុជាក្នុងដើមខែធ្នូ ឆ្នាំ២០២៥ ដោយថាមានបញ្ហាសុខភាព។

២០២៥។ សេចក្តីថ្លែងការណ៍បានរិះគន់របាយការណ៍នេះ ហើយបានជំរុញឱ្យអ្នករាយការណ៍ពិសេសដោះស្រាយបញ្ហាសិទ្ធិមនុស្ស "ប្រកបដោយអត្ថន័យ និងជាក់ស្តែង" ជាពិសេសបញ្ហាទាក់ទងនឹងព្រំដែនកម្ពុជា។

១.២ វិសាលភាព និងវិធីសាស្ត្រ

អំឡុងពេលធ្វើរបាយការណ៍នេះ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក បានចូលរួមសង្កេតសវនាការនៃសំណុំរឿងព្រហ្មទណ្ឌនៅតុលាការគោលដៅទាំងបួនជាប្រចាំ។ អ្នកសង្កេតសវនាការបានប្រើតារាងសង្កេតសវនាការ ("តារាងសង្កេតសវនាការ"[16] ដែលរួមមានសំណួរជាង ៨០ ដែលផ្តោតសំខាន់លើសិទ្ធិសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមមានសិទ្ធិដូចខាងក្រោមនេះ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់
- សិទ្ធិមានសេរីភាព
- សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល
- សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី
- សិទ្ធិទទួលបានមេធាវី
- សិទ្ធិមានវត្តមាននៅពេលសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិមិនត្រូវបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង
- សិទ្ធិបង្ហាញភស្តុតាង (រួមមានសិទ្ធិហៅ និងសាកសួរសាក្សី)
- សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ
- សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់
- សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីយុត្តិធម៌ និងមិនលម្អៀង ("ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី")។

ក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមគាំទ្រក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការសវនាការ និងសកម្មភាពសង្កេតសវនាការរបស់ខ្លួនដល់តំណាងសាលាជម្រះក្តី និងមហាអយ្យការអមសាលាជម្រះក្តីនីមួយៗ ព្រមទាំងដល់ក្រសួងយុត្តិធម៌ផងដែរ។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធមួយទំព័រភ្ជាប់ជាមួយតារាងសង្កេតការសវនាការសម្រាប់ប្រើនៅក្នុងសវនាការពាក់ព័ន្ធនឹងកុមារ (កុមារទំនាស់នឹងច្បាប់)។

[16] ម.ស.ម.ក "តារាងសង្កេតការសវនាការនៅសាលាឧទ្ធរណ៍" https://tinyurl.com/3jcd458

ផ្អែកលើតារាងសង្កេតការសវនាការ ម.ស.ម.ក បានចងក្រងគោលការណ៍ណែនាំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (“គោលការណ៍ណែនាំស្តីអំពីតារាងសង្កេតការសវនាការ”)[17] ដើម្បីផ្តល់នូវការយល់ដឹងអំពីមូលដ្ឋានច្បាប់ និងគោលបំណងនៃសំណួរនីមួយៗ ដើម្បីជានាឱ្យមានការបកស្រាយដូចគ្នាទាំងអស់។ អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ក៏បានទទួលនូវឯកសារក្របខ័ណ្ឌច្បាប់ដែលរៀបរាប់អំពីច្បាប់ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនានាទុកជាមូលដ្ឋានសម្រាប់បញ្ជាក់ពីសំណួរនីមួយៗនៅក្នុងតារាងសង្កេតការសវនាការ។

នៅក្នុងការសង្កេតសវនាការនេះ ម.ស.ម.ក បានយកចិត្តទុកដាក់ជាពិសេសចំពោះសិទ្ធិប្តឹងឧទ្ធរណ៍ រួមបញ្ចូលទាំងសិទ្ធិទទួលបានការពិនិត្យសំណុំរឿងឡើងវិញដោយពេញលេញផងដែរ មានន័យថាបណ្តឹងឧទ្ធរណ៍ត្រូវតែពាក់ព័ន្ធទាំងទិដ្ឋភាពផ្នែកច្បាប់ សត្យានុម័តនៃការផ្តន្ទាទោស និងការកាត់ទោសលើបុគ្គលនោះ។ ពោលគឺត្រូវផ្តល់នូវ “ការវាយតម្លៃពេញលេញលើកស្តុតាង និងកិច្ចដំណើរការជំនុំជម្រះ។”[18] ដើម្បីបញ្ជាក់ពីការប្តេជ្ញាគោរពតាមគោលការណ៍អន្តរជាតិដែលអនុវត្តចំពោះការសង្កេតសវនាការ ម.ស.ម.ក បានបង្កើតក្រមសីលធម៌សម្រាប់អ្នកសង្កេតសវនាការ ដែលមានចែងអំពីការមិនជ្រៀតជ្រែក មិនលម្អៀង និងរក្សាការសម្ងាត់ដែលអ្នកសង្កេតសវនាការត្រូវគោរពតាម។[19]

ក្រុមអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក មិនបានកំណត់គោលដៅលើការជំនុំជម្រះជាក់លាក់ណាមួយឡើយ។ ការសង្កេតសវនាការធ្វើឡើង ស្របតាមកាលវិភាគរបស់តុលាការ គឺមិនបានកំណត់ដោយជាក់លាក់ចំពោះសវនាការណាមួយនោះទេ។ វិធីសាស្ត្រនេះជានាថា ដំណើរការនៃប្រមូលទិន្នន័យប្រព្រឹត្តទៅដោយមិនលំអៀង និងមានលក្ខណៈជាតំណាង។ នៅពេលដែលអ្នកសង្កេតសវនាការចូលរួមសង្កេតសវនាការ រាល់ព័ត៌មានត្រូវបានកត់ត្រាភ្លាមៗដោយបញ្ចូលទៅក្នុងតារាងសង្កេតសវនាការ។ ទិន្នន័យដែលប្រមូលបានផ្តោតទាំងស្រុងលើដំណើរការសវនាការ ដោយមិនមានសម្ភាសន៍ ឬកិច្ចសន្ទនាបន្ថែមឡើយ លើកលែងតែក្នុងករណីដែលអ្នកសង្កេតសវនាការត្រូវការព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ។ ក្រោយបញ្ចប់សវនាការនីមួយៗ ទិន្នន័យត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យរបស់ ម.ស.ម.ក។ បន្ទាប់មក ទិន្នន័យទាំង

---

[17] ម.ស.ម.ក “គោលការណ៍ណែនាំអំពីតារាងសង្កេតការសវនាការនៅសាលាឧទ្ធរណ៍របស់ ម.ស.ម.ក” https://tinyurl.com/ywr3twde

[18] ក.អ.ស.ព.ន, មាត្រា ១៤ (៥) ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៧៥ គណៈកម្មាធិការសិទ្ធិមនុស្ស “សេចក្តីពន្យល់ទូទៅលេខ ៣២ – មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និងការជំនុំជម្រះដោយយុត្តិធម៌” (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧), CCPR/C/GC/៣២, វាក្យខណ្ឌ ៤៨, https://tinyurl.com/ymw9vvcs គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, *V. P. Domukovsky et al. v. Georgia* (ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៨) *GAOR*, A/ ៥៣/៤០ (លេខ II) ទំព័រ ១១១ វាក្យខណ្ឌ ១៨.១១, https://tinyurl.com/mvntuakv

[19]អង្គការលើកលែងទោសអន្តរជាតិ “សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌ បោះពុម្ពលើកទីពីរ” (ឆ្នាំ២០១៤), https://tinyurl.com/nnhppm6b; គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្ស “តើអ្វីជាការជំនុំជម្រះដោយយុត្តិធម៌៖ មគ្គុទ្ទេសក៍ជាមូលដ្ឋានស្តីពីបទដ្ឋាន និងការអនុវត្តច្បាប់” (ឆ្នាំ២០០០), https://tinyurl.com/y9ymx3z7; អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប “ការសង្កេតសវនាការ៖ សៀវភៅណែនាំសម្រាប់អ្នកប្រតិបត្តិ” (ឆ្នាំ២០០៨), https://tinyurl.com/2p88e64s; គណៈកម្មការអ្នកច្បាប់អន្តរជាតិ “សៀវភៅណែនាំស្តីការសង្កេតសវនាការ” (ឆ្នាំ២០០២), https://tinyurl.com/3a3b3u9r
ម.ស.ម.ក “ក្រមសីលធម៌សង្កេតសវនាការ” https://tinyurl.com/3fxvhxz6

នោះត្រូវបាន ម.ស.ម.ក ធ្វើការវិភាគដើម្បីកំណត់អំពីការអនុវត្តល្អ និងចំណុចមិនទាន់ប្រសើរ។ លទ្ធផលនៃការវិភាគទាំងនេះ ត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃពីវឌ្ឍនភាព និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងសម្រាប់តុលាការគោលដៅនីមួយៗ។

សម្រាប់គោលបំណងនៃការវិភាគនេះ ម.ស.ម.ក នឹងចាត់ទុកថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគោរព ប្រសិនបើសិទ្ធិនេះទទួលបានការគោរពយ៉ាងហោចណាស់ចំនួន ៨០% នៃសវនាការ និងចំនួនជនជាប់ចោទដែលបានសង្កេតក្នុងអំឡុងពេលនៃការធ្វើបាយការណ៍នេះ។ ទោះបីយ៉ាងនេះក្តី ក្នុងករណីដែលមានការបំពានលើសិទ្ធិដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន និងសិទ្ធិដាច់ខាត (សូមមើលទំព័រទី៦៤) ម.ស.ម.ក នឹងកំណត់ថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មិនត្រូវបានគោរពដោយមិនផ្អែកលើចំនួននៃភាគរយនោះឡើយ។ ម.ស.ម.ក អាចធ្វើការវិភាគ និងវាយតម្លៃលើការអនុវត្តរបស់តុលាការគោលដៅបានអាស្រ័យលើចំនួនសំណុំរឿងដែលបានសង្កេតចាប់ពីដប់សំណុំរឿងឡើងទៅ។

រាប់បញ្ចូលទាំងរបាយការណ៍មុនៗ ម.ស.ម.ក មិនបានកត់ត្រានូវការប្រើប្រាស់រាល់ឧបករណ៍អេឡិចត្រូនិចក្នុងអំឡុងពេលសវនាការ ដោយចៅក្រម តំណាងមហាអយ្យការ និងមេធាវីការពារទេ គឺមានការកត់ត្រាការសន្ទនាតាមទូរស័ព្ទតែប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងការវាយតម្លៃលើសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង។ ការវិភាគ និងការប្រៀបធៀបលើសវនាការដែលបានសង្កេតចំនួន ៤២២ សំណុំរឿងនៅឆ្នាំ២០២៥ គឺមានចំនួនតិចជាងឆ្នាំ២០២៤ (៥៨២ សំណុំរឿង) ដោយសារប្រឈមនឹងកង្វះនូវហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការកាត់នូវមូលនិធិរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍអន្តរជាតិនៅដើមឆ្នាំ២០២៥។ លទ្ធផលពីការប្រតិបត្តិរបស់តុលាការគោលដៅនៅឆ្នាំ២០២៥ ត្រូវបានយកមកប្រៀបធៀបនឹងរបកគំហើញនៅឆ្នាំ២០២៤ និងឆ្នាំកន្លងមក។ ម.ស.ម.ក សង្ឃឹមថានឹងនៅតែបន្តសង្កេតសវនាការនៅសាលាឧទ្ធរណ៍គោលដៅប្រកបដោយប្រសិទ្ធភាព។

ផ្នែកតាមកិច្ចសហការជាមួយសាលាឧទ្ធរណ៍ និងជាមួយក្រសួងយុត្តិធម៌ ម.ស.ម.ក តែងធានាថាសាលាឧទ្ធរណ៍មានឱកាសក្នុងការផ្តល់ធាតុចូលលើរបកគំហើញពីការសង្កេតសវនាការ មុននឹងធ្វើការបោះពុម្ពផ្សាយ។ នៅឆ្នាំ២០២២ ម.ស.ម.ក បានប្រជុំជាត្រីមាសជាមួយតុលាការគោលដៅ ដើម្បីបង្ហាញពីរបកគំឃើញពីការសង្កេតសវនាការ ក៏ដូចជា ការស្វែងរកការបញ្ជាក់បន្ថែមក្នុងករណីចាំបាច់។ ក្នុងកិច្ចប្រជុំកន្លងមក រួមទាំងកិច្ចប្រជុំនៅឆ្នាំ២០២៥ ផងដែរ តុលាការបានស្វាគមន៍ចំពោះការចូលរួម និងការខិតខំរបស់ ម.ស.ម.ក ក្នុងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ម.ស.ម.ក សម្តែងនូវការកើតសរសើរយ៉ាងជ្រាលជ្រៅចំពោះសាលាឧទ្ធរណ៍គោលដៅដែលបានផ្តល់នូវកិច្ចសហប្រតិបត្តិការដ៏មានតម្លៃ និងចូលរួមក្នុងកិច្ចសន្ទនាក្នុងគោលបំណងលើកកម្ពស់វិស័យយុត្តិធម៌។

ជារួម សេចក្តីព្រាងរបាយការណ៍ត្រូវបានផ្ញើជូនប្រធានសាលាជម្រះក្តីនៃសាលាឧទ្ធរណ៍នីមួយៗ និងអគ្គព្រះរាជអាជ្ញាអមសាលាជម្រះក្តីទាំងនេះ ដើម្បីទទួលបាននូវមតិយោបល់ ព្រមទាំងមូលហេតុផ្សេងៗ ដូចជាបញ្ហាប្រឈម និងអនុសាសន៍។ ម.ស.ម.ក ទទួលបានធាតុពីសាលាឧទ្ធរណ៍បាត់ដំបងនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ

២០២៦ សាលាឧទ្ធរណ៍ភ្នំពេញនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៦ សាលាឧទ្ធរណ៍ព្រះសីហនុនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៦ និងសាលាឧទ្ធរណ៍ត្បូងឃ្មុំនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ហើយធាតុចូលទាំងនោះត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ ដើម្បីបង្ហាញពីការឆ្លើយតប បញ្ហាប្រឈមរបស់មន្ត្រីវិជ្ជាជីវៈច្បាប់។ ម.ស.ម.ក ក៏ផ្ញើជូនសេចក្តីព្រាងរបាយការណ៍នេះដល់ក្រសួងយុត្តិធម៌នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៦ ដើម្បីទទួលបានធាតុចូល។

ចំពោះសេចក្តីព្រាងរបាយការណ៍ឆ្នាំ២០២៤ ម.ស.ម.ក បានផ្ញើជូនទៅក្រសួងយុត្តិធម៌នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២៥។ ម.ស.ម.ក បានទទួលលិខិត និងធាតុចូលពីក្រសួងយុត្តិធម៌នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ក្រោយថ្ងៃផុតកំណត់នៃការបោះពុម្ពផ្សាយ។ ជាការគួរឱ្យលើកទឹកចិត្តដែលក្រសួងយុត្តិធម៌ បានផ្តល់កិច្ចសហការជាមួយ ម.ស.ម.ក ក្នុងការអនុវត្តគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាច្រើនឆ្នាំកន្លងមក និងបានផ្តល់ធាតុចូលលើរបាយការណ៍ប្រចាំនេះផងដែរ។ ក្នុងទិសដៅនៃការស្ថាបនា ម.ស.ម.ក បានដាក់បញ្ចូលនូវមតិយោបល់ និងធាតុចូលរបស់ក្រសួងយុត្តិធម៌ដូចខាងក្រោម ពាក់ព័ន្ធនឹងរបាយការណ៍ឆ្នាំ២០២៤ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

- ក្រសួងយុត្តិធម៌បានយល់ស្របនឹងរបកគំហើញមួយចំនួន ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចជា៖ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលហួសហេតុ វិជ្ជាជីវៈចៅក្រម ព្រះរាជអាជ្ញា និងមេធាវី សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសម្ពាងហេតុ សិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិកុមារទំនាស់នឹងច្បាប់។
- នៅក្នុងផ្នែកខ្លះនៃធាតុចូលនេះ ក្រសួងយុត្តិធម៌បានបង្ហាញការយល់ឃើញថា ម.ស.ម.ក គួរបញ្ចូលព័ត៌មានលម្អិតថែមទៀត និងអំពីរបៀបដែលតុលាការគោលដៅអាចធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ចំពោះចំណុចនេះ ម.ស.ម.ក បានបង្ហាញក្នុងចំណុចអនុសាសន៍នៃរបាយការណ៍ឆ្នាំ២០២៤ (ផ្នែកទី៦) ដែលមានអនុសាសន៍លម្អិត និងអាចផ្តល់ព័ត៌មានដល់តុលាការគោលដៅក្នុងការលើកកម្ពស់គ្រប់ទិដ្ឋភាពទាំងអស់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
- នៅក្នុងសមាសភាគខ្លះនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្រសួងយុត្តិធម៌បានយល់ឃើញថា ម.ស.ម.ក គួរតែបញ្ចូលធាតុចូលពីតុលាការគោលដៅ។ ម.ស.ម.ក បានបញ្ចូលការយល់ឃើញ និងការឆ្លើយតបពីតុលាការគោលដៅទាំងបួនទៅក្នុងគ្រប់ផ្នែកដែលតុលាការបានឆ្លើយតប។
- ទាក់ទិននឹងសិទ្ធិទទួលបានការសន្មតទុកជាថាគ្មានទោស និងការដែលជនជាប់ចោទជាប់ឃុំស្លៀកពាក់ឯកសណ្ឋានពន្ធនាគារ ក្រសួងយុត្តិធម៌បានកត់សម្គាល់ថាអគ្គនាយកដ្ឋានពន្ធនាគារ គឺជាអ្នកទទួលខុសត្រូវសម្រាប់ផ្តល់សម្លៀកបំពាក់ដល់ជនជាប់ឃុំចូលរួមក្នុងសវនាការ ដូច្នោះបញ្ហានេះ គួរត្រូវបានលើកឡើងទៅស្ថាប័នពាក់ព័ន្ធជាជាងតែស្ថាប័នតុលាការ។ គួរកត់សម្គាល់ថា «ការស្នើឱ្យតុលាការប្តូរសម្លៀកបំពាក់ជនជាប់ចោទមុនពេលសវនាការ អាចមានការលើកឡើងពីមន្ត្រីពន្ធនាគារថា មិនមាន

ការណែនាំជារួមទេ រវាងក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ» ដែលអនុញ្ញាតឱ្យមន្ត្រីពន្ធនាគារផ្លាស់ប្តូរឯកសណ្ឋានរបស់ពន្ធនាគារទៅជាឯកសណ្ឋានស៊ីវិល។

- ចំពោះសិទ្ធិទទួលបានមេធាវី ក្រសួងយុត្តិធម៌បានលើកឡើងថា ចៅក្រម «អាចប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ និងពន្យល់ដោយសង្ខេបនូវសិទ្ធិសំខាន់ៗតែប៉ុណ្ណោះ និងមិនអាចពន្យល់លម្អិតនោះទេ ដោយហេតុថា ធ្វើដូច្នោះ អាចនាំឱ្យតំណាងមហាអយ្យការ ភាគីជនរងគ្រោះ ឬមេធាវីរបស់គេ យល់ថាចៅក្រមមានភាពលំអៀង និងយកចិត្តទុកដាក់ខ្លាំងលើជនជាប់ចោទ»។ ម.ស.ម.ក យល់ថាការគោរពសិទ្ធិរបស់ភាគីក្នុងសំណុំរឿងពេញលេញ និងដោយយកចិត្តទុកដាក់គ្រប់ជ្រុងជ្រោយ គឺជាការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

  ព័ត៌មានដែលបានលើកឡើងដោយក្រសួងយុត្តិធម៌ ជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក៏ដូចជាការឆ្លើយតបទៅនឹងអនុសាសន៍នៅក្នុងរបាយការណ៍នេះ ហើយ ម.ស.ម.ក សូមស្វាគមន៍ និងលើកទឹកចិត្តចំពោះការបន្តកិច្ចខិតខំប្រឹងប្រែងនេះ។

២.ទិដ្ឋភាពទូទៅ

ផ្នែកនេះកំណត់ពីទិន្នន័យដើមដែលបានកត់ត្រាក្នុងតារាងសង្កេតការសវនាការរបស់ ម.ស.ម.ក លើសំណុំរឿងចំនួន ៤២២ សវនាការនៅសាលាឧទ្ធរណ៍គោលដៅចំនួនបួន ចន្លោះថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

តួលេខទី១៖ទិដ្ឋភាពទូទៅនៃសំណុំរឿងដែល ម.ស.ម.ក បានសង្កេតក្នុងឆ្នាំ២០២៥

សាលាឧទ្ធរណ៍	*ភ្នំពេញ*	*បាត់ដំបង*	*ព្រះសីហនុ*	*តាខ្មៅ*	*សរុប*
ចំនួនសំណុំរឿងសរុប	*២៤៥*	*៦៤*	*១៤*	*៩៩*	*៤២២*
ចំនួនបទឧក្រិដ្ឋ[20]	*១០៥*	*២០*	*៤*	*២៥*	*១៥៤*
ចំនួនបទមជ្ឈិម[21]	*១៣៩*	*៤៥*	*៩*	*៧២*	*២៦៥*
ចំនួនបទលហុ[22]	*២*	*០*	*១*	*២*	*៥*
ចំនួនជនជាប់ចោទ	*៣៣៧*	*៨២*	*២២*	*១៣២*	*៥៧៣*
ចំនួនជនជាប់ចោទជាកុមារ	*០*	*៨*	*០*	*១*	*៩*
ចំនួនជនជាប់ចោទជាស្ត្រី	*៥៣*	*១១*	*២*	*១៨*	*៨៤*

ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន (មេធាវីការពារ) និងដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ទាំងពីរភាគីទាក់ទងនឹងបញ្ហារដ្ឋប្បវេណី) អាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមដែលចេញដោយសាលាដំបូង[23]។ តួលេខទី២ បានបង្ហាញថាភាគីជនជាប់ចោទបានដាក់បណ្តឹងឧទ្ធរណ៍ភាគច្រើន (៩០%)។

[20] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពីប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៦)។

[21] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារលើសពី ៦ ថ្ងៃ និងរហូតដល់ប្រាំឆ្នាំ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៧)។

[22] រាល់បទល្មើសដែលអតិបរមានៃទោសដាក់ពន្ធនាគារតិចជាង ឬស្មើប្រាំមួយថ្ងៃ ឬពិន័យជាប្រាក់ប៉ុណ្ណោះ (ក្រមព្រហ្មទណ្ឌ មាត្រា ៤៨)។

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៣៧៥

ក្រាហ្វិចទី២៖ ភាគីដែលបានប្តឹងឧទ្ធរណ៍នៅក្នុងសវនាការដែលបានសង្កេត នៅឆ្នាំ២០២៥[24]



តារាងខាងក្រោមនេះ ម.ស.ម.ក បានកំណត់ថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព (ពណ៌បៃតង) និងសិទ្ធិដែលមិនទាន់ត្រូវបានគោរពពេញលេញ (ពណ៌ទឹកក្រូច)។ ចំពោះសញ្ញាព្រួញចង្អុលឡើងលើ (↑) សំដៅលើសិទ្ធិដែលត្រូវបានគោរពលើកដំបូងនៅឆ្នាំ២០២៥ ដែលបង្ហាញអំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ បើធៀបនឹងរយៈពេលនៃរបាយការណ៍មុន។ រីឯសញ្ញាព្រួញចង្អុលចុះក្រោម (↓) បង្ហាញអំពីសិទ្ធិដែលត្រូវបានគោរពនៅឆ្នាំ២០២៤ ប៉ុន្តែមិនត្រូវបានគោរពពេញលេញនៅក្នុងឆ្នាំ២០២៥ ដែលនេះបង្ហាញអំពីការខកខានក្នុងការលើកកម្ពស់បទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌។ ដោយឡែក សម្រាប់ពណ៌ប្រផេះបង្ហាញថា ម.ស.ម.ក មិនអាចប្រមូលទិន្នន័យគ្រប់គ្រាន់ ដើម្បីវាយតម្លៃថាតើសិទ្ធិជាក់លាក់ណាមួយត្រូវបានគោរព ឬយ៉ាងណា។

សាលាឧទ្ធរណ៍ / សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌	ភ្នំពេញ	បាត់ដំបង	ព្រះសីហនុ	ត្បូងឃ្មុំ
សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី				
សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ				
សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់				
សិទ្ធិមានវត្តមាននៅពេលសវនាការ		↑		

[24] ទិន្នន័យនេះ គឺផ្អែកលើចំនួនសំណុំរឿងសរុបចំនួន ៤២២ ដែលបានសង្កេតនៅឆ្នាំ២០២៥។

សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល	↑			
ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី		↑	↑	
សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ				
សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស				↑
សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង		↑		
សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ				
សិទ្ធិទទួលបានមេធាវី				
សិទ្ធិមានសេរីភាព				
សិទ្ធិបង្ហាញភស្តុតាង				
សិទ្ធិរបស់កុមារទំនាស់នឹងច្បាប់				

ផ្នែកខាងក្រោមនេះ គឺជាការវិភាគទៅលើការអនុវត្តរបស់តុលាការពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ។ ចំពោះគោលបំណងនៃការវិភាគ ជាដំបូង របាយការណ៍នឹងបង្ហាញអំពីទិដ្ឋភាពនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានគោរពដោយសាលាឧទ្ធរណ៍គោលដៅទាំងបួន ហើយបន្ទាប់មក បង្ហាញអំពីការអនុវត្តដែលមិនទាន់បានគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅឡើយ។

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការឆាំងអស់បានគោរព

៣.១ សិទ្ធិជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រាប់គ្រាន់ដើម្បីរៀបចំការពារក្តី

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	ក្រមនីតិវិធីព្រហ្មទណ្ឌ	ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
មាត្រា ១៤(៣)(ខ)	មាត្រា ៤៨, ៩៨, ១៤៥, ២៥៩ & ៣១៩	មាត្រា ២៩

ជនណាដែលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ គួរត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី។ រយៈពេល "គ្រប់គ្រាន់" គឺអាស្រ័យលើកាលៈទេសៈជាក់ស្តែងនៃសំណុំរឿងនីមួយៗ។[25] គោលការណ៍ណែនាំបានកំណត់ថា ជនជាប់ចោទត្រូវតែមានលទ្ធភាពរៀបចំឱ្យបានត្រឹមត្រូវ ដើម្បីតតាំងនឹងភស្តុតាងរបស់អយ្យការ ការស៊ើបអង្កេត និងបង្ហាញសាក្សីរបស់ខ្លួន។ នេះជាតួនាទីរបស់មេធាវីការពារក្នុងការស្នើសុំពន្យារពេលសវនាការជំនុំជម្រះ ប្រសិនបើខ្លួនយល់ឃើញថា ពេលវេលាសម្រាប់ការរៀបចំការពារក្តីនោះមិនគ្រប់គ្រាន់។[26]

មធ្យោបាយចាំបាច់សម្រាប់រៀបចំការពារក្តី រួមមានការទទួលបានឯកសារសំណុំរឿង និងភស្តុតាងដើម្បីឱ្យជនជាប់ចោទដឹងច្បាស់អំពីបទចោទប្រកាន់លើពួកគេ ហើយដើម្បីឱ្យពួកគេអាចផ្តល់ការណែនាំគ្រប់ជ្រុងជ្រោយដល់មេធាវីរបស់ខ្លួន។[27] ជាពិសេស រាប់បញ្ចូលទាំងការទទួលបានភស្តុតាងទាំងឡាយដែលព្រះរាជអាជ្ញាគ្រោងនឹងបង្ហាញនៅក្នុងតុលាការ និងភស្តុតាងដោះបន្ទុក។ នៅដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍នេះ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេនៅក្នុងការប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាព ជនជាប់ចោទមានសិទ្ធិទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់សាលាដំបូង ដែលមានសំអាងហេតុត្រឹមត្រូវ និងកំណត់ហេតុនៃការជំនុំជម្រះ។[28] លើសពីនេះ ជនជាប់ចោទត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយផ្ទាល់។ បទប្បញ្ញត្តិនេះធានានូវការគោរពចំពោះគោលការណ៍ស្មើភាពគ្នា និងតម្រូវឱ្យ

[25] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

[26] ដូចខាងលើ

[27] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៣។

[28] ដូចខាងលើ, វាក្យខណ្ឌ ៤៩, សូមមើល គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១៧៩៧/២០០៨ រវាង Mennen និងប្រទេសហូឡង់ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០), CCPR/C/៩៩/D/១៧៩៧/២០០៨, វាក្យខណ្ឌ ៨.២.-៨.៤, https://tinyurl.com/z2x7tu9e

ជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីភ្លាមៗ ព្រមទាំង ត្រូវមានមធ្យោបាយដែលអាចអនុញ្ញាតឱ្យមានទំនាក់ទំនងដោយសម្ងាត់រវាងជនជាប់ចោទ និងមេធាវីរបស់ពួកគេ។[29]

ទោះបីជា ម.ស.ម.ក មិនទទួលបាននូវព័ត៌មានចាំបាច់ទាំងអស់ដែលពាក់ព័ន្ធនឹងការសង្កេតសវនាការលើបណ្តឹងឧទ្ធរណ៍ដើម្បីវាយតម្លៃថាតើជនជាប់ចោទមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងទំនាក់ទំនងជាមួយមេធាវីក៏ដោយ ក៏មានព័ត៌មានដែលបង្ហាញថាសិទ្ធិទាំងនេះត្រូវបានគោរពដោយតុលាការគោលដៅទាំងបួនដែរ។ បន្ថែមពីនេះ គ្មានជនជាប់ចោទណាម្នាក់ក្នុងចំណោម ៣២៣ នាក់ (៥៦%) ដែលមេធាវីការពាររបស់ពួកគេត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។

ជនជាប់ចោទទាំងអស់ទទួលបានមេធាវីការពារនៅមុនដំណើរការនីតិវិធីជំនុំជម្រះ ដូច្នោះពុំមានសំណុំរឿងណាមួយដែលមេធាវីរបស់ជនជាប់ចោទ បានលើកឡើងអំពីបញ្ហាកង្វះខាតពេលវេលាក្នុងការរៀបចំការពារក្តីនោះទេ។ ម.ស.ម.ក សាទរចំពោះសាលាឧទ្ធរណ៍ទាំងនោះដែលបានគោរពយ៉ាងខ្ជាប់ខ្ជួននូវសិទ្ធិរបស់ជនជាប់ចោទក្នុងការជួបនិយាយជាមួយមេធាវីរបស់ខ្លួនមុនពេលជំនុំជម្រះ និងសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការពារក្តីត្រូវបានលើកកម្ពស់ជាប់ជានិច្ចដោយសាលាឧទ្ធរណ៍តាំងពីឆ្នាំ ២០១៤ មកម្លេះ។

ម.ស.ម.ក បានចូលរួមស្តាប់សាលដីកា**ចំនួន៣៣ សំណុំរឿង** ហើយសាលដីកាទាំងនោះត្រូវបានធ្វើឡើងជាសាធារណៈ។

គ្មានជនជាប់ចោទណាម្នាក់ដែលមេធាវីរបស់ខ្លួនត្រូវបានចាត់តាំងនៅថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះឡើយ។

មិនមានមេធាវីការពារឱ្យជនជាប់ចោទណាមួយ ក្នុងចំណោម ៣២៣ នាក់ បានលើកពីបញ្ហាកង្វះពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តីនោះទេ។

៣.២ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	ក្រមនីតិវិធីព្រហ្មទណ្ឌ	ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
មាត្រា ១៤(១)	មាត្រា ៣១៧	មាត្រា ៧

[29] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៤, សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិនិយាយជាមួយមេធាវី" (ខែកញ្ញា ឆ្នាំ ២០២២), https://tinyurl.com/yckvz5

សេចក្តីសម្រេចរបស់តុលាការ ត្រូវតែប្រកាសជាសាធារណៈដែលនេះជាមូលដ្ឋានគ្រឹះធានានូវតម្លាភាព និងគណនេយ្យភាព។[30] យោងតាមមាត្រា ១៤(១) នៃ ក.អ.ស.ព.ន ទោះបីជានៅពេលដែលសាធារណជនមិនត្រូវបានឱ្យចូលរួមក្នុងសវនាការក៏ដោយ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ កស្តុតាង និងសំអាងហេតុផ្លូវច្បាប់ ត្រូវតែបង្ហាញជាសាធារណៈ។[31] សេចក្តីសម្រេចជាសាធារណៈ ជំរុញឱ្យមានតម្លាភាព និងគណនេយ្យភាព ដែលនាំឱ្យចៅក្រមធ្វើសកម្មភាពដោយភាពហ្មត់ចត់បំផុត និងធានាឱ្យមានការផ្តល់យុត្តិធម៌ដោយស្មើភាព។ វិធាននេះមានការលើកលែងតែមួយចំនួនប៉ុណ្ណោះ ដូចជានៅពេលសេចក្តីសម្រេចមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈដើម្បីផលប្រយោជន៍របស់កុមារ។[32]

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ ត្រូវបានគោរពដោយតុលាការទាំងបួន។ ម.ស.ម.ក កត់សម្គាល់ជាវិជ្ជមានចំពោះសាលាឧទ្ធរណ៍ទាំងនោះដែលបានគោរពយ៉ាងជាប់ជាប្រចាំចំពោះសិទ្ធិនេះ។

៣.៣ សិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	**ក្រមនីតិវិធីព្រហ្មទណ្ឌ**	**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
មាត្រា ១៤(៣) (ក) និង (ច)	មាត្រា ៣២២, ៣២៥, ៣៣០, ៣៣១ និង ៣៩៦	មាត្រា ៦ និង ៥១

ជនជាប់ចោទបទព្រហ្មទណ្ឌ ត្រូវទទួលបានការជូនដំណឹង "ភ្លាមៗ" អំពីប្រភេទនៃបទល្មើសដែលបានចោទប្រកាន់មកលើពួកគេ។ ចៅក្រមមានកាតព្វកិច្ចផ្តល់ការពន្យល់ឱ្យបានគ្រប់គ្រាន់ និងធានាថាជនជាប់ចោទយល់អំពីប្រភេទ និងមូលហេតុនៃបទចោទប្រកាន់មកលើពួកគេ ធ្វើដូច្នេះ ពួកគេអាចរៀបចំមេធាវីការពារបានត្រឹមត្រូវ។[33] ព័ត៌មានទាក់ទងនឹងការចោទប្រកាន់ ត្រូវតែផ្តល់ជូនភ្លាមៗ នៅពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់ជាផ្លូវការពីបទព្រហ្មទណ្ឌតាមច្បាប់ជាតិ ឬភ្លាមៗនៅពេលដែលជននោះត្រូវបានកំណត់ជាសាធារណៈថាជាជនជាប់ចោទ។ ការជូនដំណឹងនេះអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ (លុះត្រាតែមានការបញ្ជាក់ជា

[30] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/5ssncyyy

[31] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ៣២, វាក្យខណ្ឌ ២៩។

[32] ដូចខាងលើ

[33] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ,សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់" (ខែកញ្ញា ឆ្នាំ២០២២ https://tinyurl.com/5h6ec5vz

លាយលក្ខណ៍អក្សរនៅពេលក្រោយ) ឬជាលាយលក្ខណ៍អក្សរ ដែលព័ត៌មានបង្ហាញទាំងអង្គច្បាប់ និងអង្គហេតុ សម្រាប់ជាមូលដ្ឋាននៃការចោទប្រកាន់។[34]

គួរកត់សម្គាល់ថា អ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យនៅពេលចាប់ផ្តើមសវនាការរបស់សាលាឧទ្ធរណ៍ ជនជាប់ចោទគួរដឹងច្បាស់ជាមុនអំពីបទចោទប្រកាន់មកលើពួកគេ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមគប្បីរំឭកជនជាប់ចោទអំពីព័ត៌មានទាំងនេះ និងដើម្បីធានាថាជនជាប់ចោទយល់ច្បាស់អំពីព័ត៌មាននេះ ជាពិសេសនៅក្នុងករណីដែលការចោទប្រកាន់អាចមានការផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលឃាត់ខ្លួន/ការចោទប្រកាន់ដំបូង និងការជំនុំជម្រះជាក់ស្តែង។ បន្ថែមពីនេះ មាត្រា៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងយ៉ាងច្បាស់ថា វិធានដែលអនុវត្តចំពោះមុខតុលាការដំបូងក៏ត្រូវយកមកអនុវត្តចំពោះមុខសាលាឧទ្ធរណ៍ដែរ។

កត់សម្គាល់ជាវិជ្ជមានសម្រាប់ឆ្នាំទីពីរជាប់ៗគ្នា ដែលចៅក្រមបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់បាន ១០០% នៃសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅតាមសាលាឧទ្ធរណ៍ទាំងបួន។ នេះគឺជាវឌ្ឍនភាពដ៏សំខាន់មួយបើប្រៀបធៀបទៅនឹងឆ្នាំ២០២២ ដែលចៅក្រមបានអានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ត្រឹមតែ ៥៩,៧% នៃសវនាការដែលបានសង្កេត។ ចំណុចដែលគួរឱ្យលើកទឹកចិត្តបន្ថែមទៀតនោះគឺចៅក្រមបានអានប្រាប់ពីកាលបរិច្ឆេទនៃបទល្មើស ទីតាំងនៃបទល្មើស និងភាគីពាក់ព័ន្ធ ដែលជាលទ្ធផលចៅក្រមបានអានប្រាប់កាលបរិច្ឆេទនៃបទល្មើសចំនួន ៩៧% ទីតាំងបទល្មើសចំនួន ៩៨% និងភាគីពាក់ព័ន្ធចំនួន ១០០% ដែលនេះជាភាពល្អប្រសើរឡើងបើប្រៀបធៀបនឹងឆ្នាំ២០២៤ (៩៤%, ៩១%, ៩៩%)។ ទោះជាយ៉ាងនេះក្តី ទិដ្ឋភាពមួយនៃសិទ្ធិនេះនៅតែត្រូវការការកែលម្អបន្ថែម នោះគឺការអានប្រាប់អំពីមាត្រាពាក់ព័ន្ធនៃច្បាប់ដែលជាមូលដ្ឋានដើម្បីចោទប្រកាន់ជនជាប់ចោទ។ មានសំណុំរឿងចំនួន ៣២% (១៣៣ ក្នុងចំណោម ៤២២) ដែលចៅក្រមមិនបានអានអំពីមាត្រាពាក់ព័ន្ធនៃច្បាប់នោះទេដែលមានតួលេខកើនឡើង បើធៀបនឹងឆ្នាំមុនមានត្រឹម ៣០%។

សាលាឧទ្ធរណ៍ភ្នំពេញ

ដូចគ្នាទៅនឹងសាលាឧទ្ធរណ៍គោលដៅទាំងបីផ្សេងទៀតដែរ នៅក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញ ចៅក្រមបានអានប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ចំនួន ១០០% (២៤៥)។ នេះជាឆ្នាំទីបីជាប់ៗគ្នាដែលសាលាឧទ្ធរណ៍ភ្នំពេញបានអនុវត្តបែបនេះ ដែលជាការល្អប្រសើរឡើងគួរឱ្យកត់សម្គាល់បើប្រៀបធៀបទៅនឹងឆ្នាំ២០២៣។ គួរឱ្យកត់សម្គាល់ថា សាលាឧទ្ធរណ៍ភ្នំពេញមិនបានបង្ហាញពីភាពប្រសើរឡើងពាក់ព័ន្ធនឹងការអានប្រាប់អំពីមាត្រាពាក់ព័ន្ធនៃច្បាប់ដោយចៅក្រមនោះទេ។ ការអានប្រាប់ជន

---

[34] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ សូមមើលផងដែរ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ៦០៩/១៩៩៥, Nathaniel Williams v. និងចាម៉ៃកា *(ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧) CCPR/C/*៦១/*D/*៦០៩/*១៩៩៥* ដែលក្នុងនោះគណៈកម្មាធិការបានបញ្ជាក់បន្ថែមថា ព័ត៌មានលម្អិតអំពីការចោទប្រកាន់ត្រូវតែផ្តល់ជូននៅ"ពេលចាប់ផ្តើមការស៊ើបអង្កេតបឋម ឬនៅពេលកំណត់សវនាការមួយចំនួនផ្សេងទៀតដែលនាំទៅដល់ការសង្ស័យជាផ្លូវការ និងយ៉ាងច្បាស់ប្រឆាំងនឹងជនជាប់ចោទ"។

ជាប់ចោទអំពីមាត្រាពាក់ព័ន្ធនៃច្បាប់ មានត្រឹមតែ ៥៦% (១៣៧ ក្នុងចំណោម ២៤៥) នៃសំណុំរឿងដែលជាតួលេខដូចគ្នាទៅនឹងឆ្នាំ២០២៤ ដែរ។ ទោះបីជាចំណុចនេះមិនទាន់ទទួលបានភាពប្រសើរក៏ដោយ សាលាឧទ្ធរណ៍ភ្នំពេញក៏ទទួលបានភាពប្រសើរឡើងលើការអានប្រាប់កាលបរិច្ឆេទនៃបទល្មើស និងភាគីពាក់ព័ន្ធដោយចៅក្រមនៅក្នុងសវនាការចំនួន ៩៦% និង១០០% តាមផ្នែកនីមួយៗ។ ចំណុចប្រសើរផ្សេងទៀតគឺ ការកើនឡើងនៃតួលេខដែលចៅក្រមបានអានប្រាប់អំពីទីកន្លែងនៃបទល្មើស ដែលមានចំនួន ៩៨% នៃសំណុំរឿង ដែលកើនឡើងពី ៨៨% នៅឆ្នាំ២០២៤។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា សំណុំរឿងភាគច្រើន គឺចៅក្រមបានអានប្រាប់ និងពន្យល់អំពីប្រភេទ និងមូលហេតុនៃចោទប្រកាន់ដល់ជនជាប់ចោទ តែអាចមានការខកខាននូវចំណុចខ្លះ ដូចនេះ តុលាការនឹងពង្រឹងលើបញ្ហានេះ។ ដោយឡែកពាក់ព័ន្ធនឹងការចោទប្រកាន់ដែលអាចមានការផ្លាស់ប្តូរ ឬកែប្រែបទចោទក្នុងដំណើរការនីតិវិធី តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ថានឹងពិនិត្យ ព្រមទាំងអាចបញ្ជាក់បន្ថែមលើផ្នែកនេះ ដើម្បីធានាថាជនជាប់ចោទទទួលបានព័ត៌មានពេញលេញ។[35]

តួលេខទី៣៖ ការរឹតនៃសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០២៣-២០២៥)[36]



សាលាឧទ្ធរណ៍បាត់ដំបង

[35] នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[36] ទិន្នន័យនេះគឺផ្អែកលើសំណុំរឿងសរុបចំនួន ៣៣៦ ដែលបានសង្កេតនៅឆ្នាំ២០២៣ និងសំណុំរឿងសរុបចំនួន២៧៦ ដែលបានសង្កេតនៅឆ្នាំ២០២៤ និងសំណុំរឿងសរុបចំនួន ២៤៥ ដែលបានសង្កេតនៅឆ្នាំ២០២៥។

សាលាឧទ្ធរណ៍បាត់ដំបងមានការអនុវត្តស្រដៀងគ្នាទៅនឹងឆ្នាំ២០២៤ ពាក់ព័ន្ធនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។ សាលាឧទ្ធរណ៍នេះមានតួលេខចំនួន ១០០% ពាក់ព័ន្ធនឹងការអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទ។ ទោះជាយ៉ាងនេះក្តី មិនមានវឌ្ឍនភាពពាក់ព័ន្ធនឹងការអានប្រាប់មាត្រាពាក់ព័ន្ធនៃច្បាប់ទេ ដោយចំនួន ៧៦,៦% នៃសំណុំរឿងដែលបានសង្កេត (៤៩ ក្នុងចំណោម ៦៤) ដែលជាតួលេខដូចគ្នាទៅនឹងឆ្នាំមុនដែរ។ គួរកត់សម្គាល់ជាវិជ្ជមានដែលចៅក្រមបានអានប្រាប់អំពីកាលបរិច្ឆេទ និងទីកន្លែងនៃបទល្មើស និងភាគីពាក់ព័ន្ធមានចំនួន ១០០% នៃផ្នែកនីមួយៗ ដែលបង្ហាញភាពល្អប្រសើរបើប្រៀបធៀបនឹងឆ្នាំ២០២៤ មានចំនួនត្រឹមតែ៨៩,៥% ៩៤,៥% និង៩៨% នៃផ្នែកនីមួយៗ។ ជាការលើកទឹកចិត្តដែលតុលាការនឹងធ្វើឱ្យប្រសើរឡើងចំពោះការអានប្រាប់អំពីមាត្រាច្បាប់ពាក់ព័ន្ធ ដើម្បីគោរពសិទ្ធិនេះឱ្យបានយ៉ាងពេញលេញ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថា គាត់តែងតែប្រាប់ដល់ជនជាប់ចោទឱ្យបានដឹងពីច្បាប់ រួមទាំងមាត្រាច្បាប់ព័ន្ធពាក់នឹងការចោទប្រកាន់នោះ គឺមិនដែលខកខានឡើយ។[37]

សាលាឧទ្ធរណ៍ព្រះសីហនុ

ទោះបីជាសាលាឧទ្ធរណ៍ព្រះសីហនុមានលទ្ធផលគួរឱ្យកត់សម្គាល់ជាវិជ្ជមាន ដែលបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទរហូតដល់ ១០០% នៃសំណុំរឿងដែលបានសង្កេតក្តី ប៉ុន្តែមានការធ្លាក់ចុះពាក់ព័ន្ធចៅក្រមអានប្រាប់អំពីមាត្រាពាក់ព័ន្ធនៃច្បាប់ដល់ជនជាប់ចោទ មានចំនួន ៥០% នៃសំណុំរឿងដែលបានសង្កេត បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៧២% ។ គួរឱ្យកត់សម្គាល់ផងដែរថា ក្នុងឆ្នាំ ២០២៣ ចៅក្រមបានអានប្រាប់មាត្រាពាក់ព័ន្ធនៃច្បាប់ចំនួន ៧៦% នៃសំណុំរឿងសរុប ដែលថយចុះពី ៨៩,៨% ក្នុងឆ្នាំ២០២២។ ក៏មានការថយចុះផងដែរពាក់ព័ន្ធនឹងការអានប្រាប់អំពីកាលបរិច្ឆេទនៃបទល្មើសពីចំនួន ៨៦% នៅឆ្នាំ២០២៤ មកត្រឹម ៦៤% នៅឆ្នាំ២០២៥។ ចៅក្រមបានអានប្រាប់ជនជាប់ចោទអំពីទីកន្លែងនៃបទល្មើសចំនួន ៨៦% និងភាគីពាក់ព័ន្ធចំនួន ១០០% នៃសំណុំរឿងសរុប។

នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបាននិយាយថា ចៅក្រមស៊ើបសួរបានអានប្រាប់អំពីបទចោទប្រកាន់ដល់ជនជាប់ចោទរួចហើយ បន្ទាប់ពីមានដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ពោលគឺចំណុចនេះមិនមែនជាបន្ទុករបស់សាលាឧទ្ធរណ៍នោះទេ។ តំណាងតុលាការបានលើកឡើងទៀតថា ជាធម្មតាចៅក្រមសាលាឧទ្ធរណ៍តែងតែពិនិត្យមើលសំណុំរឿងទាំងមូល និងសេចក្តីសម្រេចរបស់សាលាដំបូង បន្ទាប់មក

[37] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសនោការរបស់ខ្លួន។

ចៅក្រមត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេ និងភាគីពាក់ព័ន្ធ និងសួរថាតើផ្នែកណាមួយនៃសាលក្រមរបស់សាលាដំបូងដែលខ្លួនប្តឹងតវ៉ា និងមូលហេតុ។ ជាទូទៅ ជនជាប់ចោទតែងបដិសេធថាខ្លួនមិនបានប្រព្រឹត្តបទល្មើស ឬលើកឡើងថាការផ្តន្ទាទោសនោះគឺធ្ងន់ធ្ងរពេក។ ដូច្នេះហើយ មិនចាំបាច់តម្រូវឱ្យចៅក្រមអានប្រាប់និងពន្យល់អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នោះទេ។ ទោះជាយ៉ាងនេះក្តី តំណាងសាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍ថ្លែងថា ចៅក្រមនឹងអានប្រាប់ដល់ជនជាប់ចោទ ក រណីជនជាប់ចោទនិយាយថាខ្លួនមិនយល់អំពីបទចោទប្រកាន់លើពួកគេ[38] ដូច្នេះ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ស្នើឱ្យ ម.ស.ម.ក ពិចារណាលើកម្រិតនៃវាយតម្លៃចំពោះសិទ្ធិដែលអនុវត្តនៅសាលាឧទ្ធរណ៍ពីព្រោះថាសិទ្ធិមួយចំនួនសាលាដំបូងបានប្រាប់រួចទៅហើយ ដូច្នេះជនជាប់ចោទបានយល់ដឹងអំពីសិទ្ធិទាំងនេះរួចហើយ។[39] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថាការប្រាប់ជនជាប់ចោទឱ្យដឹងពីមាត្រាច្បាប់ហាក់ដូចជាមិនសូវមានសារៈសំខាន់នោះទេ ហើយបានចោទសួរថាការដែលជនជាប់ចោទមិនបានដឹងអំពីមាត្រាច្បាប់នេះ តើជនជាប់ចោទនោះនឹងទទួលរងផលប៉ះពាល់អ្វីដែរ។ តុលាការបានបន្ថែមថា ជនជាប់ចោទបានទទួលព័ត៌មានលម្អិតហើយអំពីសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់លើគាត់ ចាប់តាំងពីសាលាដំបូងមកម្លេះ ហើយបណ្តឹងឧទ្ធរណ៍របស់គាត់ភាគច្រើន គឺសុំការបន្ធូរបន្ថយទោស ដូច្នោះចៅក្រមបានប្រាប់ត្រឹមអត្ថបទច្បាប់ប៉ុណ្ណោះ ហើយករណីខ្លះមិនបានប្រាប់មាត្រាច្បាប់នោះទេ។[40]

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បួនឆ្នាំជាប់ៗគ្នាដែលសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានគោរពសិទ្ធិជនជាប់ចោទពាក់ព័ន្ធនឹងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។ សាលាឧទ្ធរណ៍ត្បូងឃ្មុំបានរក្សាកំណត់ត្រារបស់ខ្លួនបាន ១០០% ដែលចៅក្រមបានអានប្រាប់អំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដល់ជនជាប់ចោទ។ ពាក់ព័ន្ធនឹងការអានប្រាប់អំពីមាត្រាច្បាប់ពាក់ព័ន្ធ សាលាឧទ្ធរណ៍ត្បូងឃ្មុំរក្សាបាននូវកំណត់ត្រាកម្រិតខ្ពស់របស់ខ្លួន ៩៧% នៃសំណុំរឿងដែលបានសង្កេត ដែលកើនឡើងពី ៩៦% នៅឆ្នាំ២០២៤។ សាលាឧទ្ធរណ៍ត្បូងឃ្មុំក៏បានអនុវត្តល្អប្រសើរតាំងពីឆ្នាំមុនពាក់ព័ន្ធនឹងការអានប្រាប់អំពីកាលបរិច្ឆេទ និងទីកន្លែងនៃបទល្មើស និងភាគីពាក់ព័ន្ធមានចំនួន ១០០% នៃផ្នែកនីមួយៗ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍

---

[38] លិខិតលេខ ១៩១៩/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ដោយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីឆ្លើយតបទៅនឹងលទ្ធផលរកឃើញក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[39] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[40] នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ត្បូងឃ្មុំបានលើកឡើងថា តុលាការនឹងជម្រាបដល់ចៅក្រមត្រូវប្រាប់ព័ត៌មានសំខាន់ៗដែលមានក្នុងសំណុំរឿងដល់ភាគីទាំងអស់ពេលសួរដេញដោល ដើម្បីឱ្យភាគីទាំងនោះទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយអ្នកសង្កេតសវនាការរបស់ ម.ស.ម.ក ក៏ទទួលព័ត៌មាននោះដែរ ដូចជា កាលបរិច្ឆេទនៃដីកាឃុំខ្លួន ។ល។ [41]

ក្រាហ្វលេខទី៤៖ សិទ្ធិក្នុងការយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់នៅតាមតុលាការគោលដៅ [42]



៣.៤ សិទ្ធិមានវត្តមាននៅពេលសវនាការ

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា			
ក.អ.ស.ព.ន	រដ្ឋធម្មនុញ្ញ	ក្រមនីតិវិធីព្រហ្មទណ្ឌ	ច្បាប់ស្តីពីយុត្តិធម៌អនីតិជន	ច្បាប់ស្តីពីពន្ធនាគារ[43]
មាត្រា ១៤(៣)(ឃ)	មាត្រា ៣៨	មាត្រា ៣០០	មាត្រា ៦ និង ៥១	មាត្រា ៦២

ការជំនុំជម្រះត្រូវតែធ្វើឡើងដោយមានវត្តមានរបស់ជនជាប់ចោទ ដោយសារតែការធ្វើបែបនេះផ្តល់ឱកាសឱ្យពួកគេបានស្តាប់ និងឆ្លើយតបទៅនឹងកស្តុតាងដែលដាក់បន្ទុកលើពួកគេ និងអាចការពារខ្លួនបាន។[44] នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងកុមារ សវនាការត្រូវមានវត្តមាន "មេធាវី ឬជំនួយការផ្នែកច្បាប់សមស្របផ្សេង

[41] នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[42] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅតុលាការនេះនៅឆ្នាំ២០២៥។

[43] ច្បាប់ស្តីពីពន្ធនាគារ (ឆ្នាំ២០១១) https://tinyurl.com/37eyeh3t

[44] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ឃ),គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦

ទៀត" និងវត្តមានរបស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ឬអ្នកមើលថែផ្សេងទៀត លុះត្រាតែមានការរកឃើញថាប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់កុមារ ឬតាមការស្នើសុំមិនចូលរួមសវនាការរបស់កុមារ។ [45]

សិទ្ធិមានវត្តមាននៅពេលសវនាការ អាចអនុវត្តបានចំពោះដំណើរបណ្តឹងឧទ្ធរណ៍ ប្រសិនបើពាក់ព័ន្ធនឹងបញ្ហានៃអង្គហេតុ និងអង្គច្បាប់[46] ដែលជាករណីកើតឡើងនៅកម្ពុជា។ ការជំនុំជម្រះដោយកំបាំងមុខ ពោលគឺអវត្តមានជនជាប់ចោទ គឺអាចអនុញ្ញាតបានតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ នៅក្នុងកាលៈទេសៈពិសេស និងនៅពេលដែលជាប្រយោជន៍នៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ[47]។ ទោះជាយ៉ាងនេះក្តី យុត្តិកម្មច្បាស់លាស់ត្រូវតែផ្តល់ជូនសម្រាប់ពួកគេ ហើយជនជាប់ចោទក៏អាចលះបង់សិទ្ធិមានវត្តមានក្នុងសវនាការបានផងដែរ។[48]

នៅឆ្នាំ២០២៥ ជនជាប់ចោទ ៩៤% (៥៣៨ ក្នុងចំណោម ៥៧៣) មានវត្តមាននៅក្នុងសវនាការដែលបានសង្កេត ដែលតួលេខនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ជាវិជ្ជមានបើធៀបនឹងឆ្នាំ២០២៤ ដែលមានចំនួន ៨៨% និងឆ្នាំ២០២៣ ដែលមាន ៨១,៦%។ នេះជាឆ្នាំដំបូងដែលសិទ្ធិនេះ ត្រូវបានគោរពដោយតុលាការគោលដៅទាំងបួន កាលឆ្នាំ២០២៤ សាលាឧទ្ធរណ៍បាត់ដំបងស្ទើរតែបំពេញដល់កម្រិត ៨០% ដែលកំណត់ថាសិទ្ធិនេះត្រូវបានគោរពពេញលេញ។ ដោយឡែកសាលាឧទ្ធរណ៍ត្បូងឃ្មុំរក្សាទិន្នន័យ ៩៤% ទាំងឆ្នាំ២០២៤ និង២០២៥ ដូច្នោះ តុលាការទាំងបួនមានភាពប្រសើរក្នុងការគោរពបានជាប់ជាប្រចាំនូវសិទ្ធិនេះ ដោយសង្ឃឹមថានឹងមានវឌ្ឍនភាពបន្ថែមទៀតសម្រាប់ឆ្នាំបន្តបន្ទាប់។

តួលេខទី ៥៖ ភាគរយនៃសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការនៅតាមតុលាការគោលដៅ[49]



[45] គណៈកម្មាធិការសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៣, ៥៦

[46] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣៨៧/១៩៨៩, Karttunen ទល់នឹងប្រទេសហ្វាំងឡង់ (ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩២) CCPR/C/៤៦/D/៣៨៧/១៩៨៩, វាក្យខណ្ឌ ៧.៣ https://tinyurl.com/267vaeud

[47] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៦

[48] គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ០១៦/១៩៧៧, Mbenge ទល់នឹងប្រទេសហ្ស៊ៀ (ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣) CCPR/C/១៨/D/១៦/១៩៧៧ វាក្យខណ្ឌ ១៤.១, https://tinyurl.com/2e7vba3k

[49] ទិន្នន័យនេះ គឺផ្អែកទៅលើចំនួនជនជាប់ចោទសរុប (៥៧៣ នាក់) ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតក្នុងឆ្នាំ២០២៥។

សាលាឧទ្ធរណ៍ភ្នំពេញ

សាលាឧទ្ធរណ៍ភ្នំពេញបានគោរពសិទ្ធិមានវត្តមាននៅសវនាការជាទៀងទាត់ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ ២០១៨ ហើយឆ្នាំ២០២៥ ក៏នៅតែបន្តគោរពសិទ្ធិនេះទៀតផងដែរ។ ចំនួនជនជាប់ចោទដែលមានវត្តមាននៅពេលសវនាការមានចំនួន ៣២១ ក្នុងចំណោម ៣៣៧ នាក់ដែលស្មើនឹង៩៥% នៃសំណុំរឿងដែលបានសង្កេត។ ផ្អែកតាមតួលេខនេះ សាលាឧទ្ធរណ៍ភ្នំពេញ មានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដូចជា ក្នុងឆ្នាំ២០២៣ មានតួលេខ ៨១% និងនៅឆ្នាំ២០២៤ តួលេខនេះបានកើនឡើងដល់ ៩៤%។ ការអនុវត្តនេះក៏បង្ហាញអំពីភាពល្អប្រសើរជាងគេពាក់ព័ន្ធនឹងការគោរពសិទ្ធិមានវត្តមានក្នុងចំណោមតុលាការគោលដៅទាំងបួន។

វឌ្ឍនភាពនេះ បង្ហាញឱ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់សាលាឧទ្ធរណ៍ភ្នំពេញក្នុងការដោះស្រាយបញ្ហាទាំងនេះ ដោយហេតុថាកន្លងមកមានការលើកឡើងថា អវត្តមានរបស់ជនជាប់ចោទនៅពេលមានសវនាការ ជារឿយៗតែងតែកើតឡើងដោយហេតុថា បញ្ហាភស្តុភារ បញ្ហាទំនាក់ទំនងរវាងតុលាការ និងមណ្ឌលអប់រំកែប្រែ។ នៅក្នុងសំណុំរឿងមុនៗ តុលាការបានលើកឡើងថា មានករណីជាច្រើន គឺមិនមានការដឹកជញ្ជូនជនជាប់ចោទមកកាន់តុលាការនោះទេ អាចដោយហេតុថាតុលាការបានបញ្ជូនព័ត៌មានទៅខុសមណ្ឌលអប់រំកែប្រែ និងដោយហេតុថា មណ្ឌលអប់រំកែប្រែមិនបានផ្តល់បច្ចុប្បន្នភាពដល់តុលាការអំពីការផ្ទេរជនជាប់ឃុំទៅមណ្ឌលអប់រំកែប្រែផ្សេងទៀត។ បញ្ហានេះអាចដោះស្រាយតាមរយៈការកែលម្អការធ្វើកំណត់ត្រា និងទំនាក់ទំនងរវាងតុលាការ និងមណ្ឌលអប់រំកែប្រែ។ នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក តុលាការក៏បានពន្យល់ផងដែរថា ខ្លួនអាចបើកសវនាការលើសំណុំរឿងដោយគ្មានវត្តមានរបស់ជនជាប់ចោទបាន ប្រសិនបើមេធាវីរបស់ពួកគេមានវត្តមាន ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ ប្រសិនបើបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងដោយអយ្យការ ឬប្រសិនបើសំណុំរឿងនោះកកស្ទះនៅតុលាការអស់រយៈពេលយូរ ហើយភាគីស្នើសុំឱ្យចៅក្រមជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ។[50] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានលើកឡើងថា ករណីខ្លះដែលជនជាប់ចោទអវត្តមានពេលសវនាការដោយសារតែជនជាប់ចោទដែលជាប់ឃុំត្រូវបានផ្ទេរទៅពន្ធនាគារផ្សេង ហើយតុលាការមិនបានទទួលព័ត៌មានបច្ចុប្បន្នភាពនៃការផ្ទេរនោះ ដូច្នោះក្រឡាបញ្ជីអាចនឹងកោះហៅជនជាប់ចោទនៅពន្ធនាគារដែលបានជាប់ឃុំដំបូង។[51]

តួលេខទី៦៖ ការប្រៀបធៀបនៃសំណុំរឿងដែលជនជាប់ចោទមានវត្តមានពេលសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០២៤)[52]

---

[50] លិខិតលេខ ៤៣១/២១ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលឆ្លើយតបទៅនឹងលទ្ធផលរកឃើញក្នុងរបាយការណ៍ប្រចាំឆ្នាំ២០១៩/២០២០ របស់ ម.ស.ម.ក ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

[51] នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៦ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[52] ទិន្នន័យនេះផ្អែកលើជនជាប់ចោទចំនួន ១២៩ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ ២០១៤/២០១៥, ជនជាប់ចោទចំនួន ៤០៤ នាក់ ដែលមានវត្តមាន

តើជនជាប់ចោទមានវត្តមានពេលសវនាការដែរទេ?	មាន	គ្មាន
២០១៤/២០១៥	៧៩%	២១%
២០១៦/២០១៧	៧២,៤%	២៧,៦%
២០១៧/២០១៨	៨២,៥%	១៧,៥%
២០១៨/២០១៩	៨០,៧%	១៩,៣%
២០១៩/២០២០	៩០,២%	៩,៨%
២០២១	៨៣,១%	១៦,៩%
២០២២	៨១,៨%	១៨,២%
២០២៣	៨១,៥%	១៨,៥%
២០២៤	៩៤%	៦%
២០២៥	៩៥%	៥%

សាលាឧទ្ធរណ៍បាត់ដំបង

សាលាឧទ្ធរណ៍បាត់ដំបង មានភាពល្អប្រសើរឡើងវិញនូវការគោរពសិទ្ធិមានវត្តមាននៅសវនាការនេះ ដែលការគោរពសិទ្ធិនេះធ្លាប់បានថយចុះពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤ តែក្នុងឆ្នាំ២០២៥ ជនជាប់ចោទមាន

ពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៥៥៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧, ជនជាប់ចោទចំនួន ២៦០ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ ២០១៧/២០១៨ ជនជាប់ចោទចំនួន ២៨៤ នាក់ ដែលមានវត្តមាននៅពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ ២០១៨/២០១៩, ជនជាប់ចោទចំនួន ២៣០ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ២៥៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ ២០១៩/២០២០, ជនជាប់ចោទចំនួន ៩៨ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ១១៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ២០២១,ជនជាប់ចោទចំនួន ២៨៨ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ ២០២២, ជនជាប់ចោទចំនួន ៣៧៥ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៤៦០ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៣៦ ដែលបានសង្កេតនៅឆ្នាំ ២០២៣, ជនជាប់ចោទចំនួន ៣៤៣ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៦៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៧៦ ដែលបានសង្កេតនៅឆ្នាំ ២០២៤ និងជនជាប់ចោទចំនួន ៣២១ នាក់ ដែលមានវត្តមានពេលសវនាការក្នុងចំណោមជនជាប់ចោទចំនួន ៣៣៧ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៤៥ ដែលបានសង្កេតនៅឆ្នាំ២០២៥។

វត្តមាននៅពេលសវនាការមានតួលេខ ៨៩% (៧៣ ក្នុងចំណោម ៨២ ជនជាប់ចោទ) ។ សង្ឃឹមថាសាលាឧទ្ធរណ៍បាត់ដំបងនឹងបន្តភាពប្រសើរឡើងដើម្បីត្រឡប់ដូចឆ្នាំកន្លងមកដែលមានតួលេខ ៩១% ក្នុងឆ្នាំ ២០២២ មុនពេលថយមកត្រឹម ៨២% នៅឆ្នាំ២០២៣ និងបន្តថយចុះរហូតដល់ ៧៧% នៅឆ្នាំ២០២៤។ គួរព្រឹកថា នៅឆ្នាំ២០២២ ឯកឧត្តមអនុប្រធានតុលាការបានមានប្រសាសន៍ថា តុលាការនឹងចាត់វិធានការលើបញ្ហានេះយ៉ាងម៉ឺងម៉ាត់ ដោយហេតុថាវត្តមានរបស់ជនជាប់ចោទក្នុងសវនាការ គឺជាធាតុផ្សំដ៏ចម្បងមួយនៃលទ្ធភាពទទួលបានយុត្តិធម៌ ហើយថាតុលាការតម្រូវឱ្យជនជាប់ចោទគ្រប់រូបមានវត្តមាន រួមទាំង ជនជាប់ចោទដែលបានស្នើសុំមិនបង្ហាញខ្លួនផងដែរ។[53] នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងតុលាការបានអះអាងថា ក្នុងសំណុំរឿងមួយចំនួន តុលាការបានកោះហៅជនជាប់ចោទយ៉ាងត្រឹមត្រូវហើយ ប៉ុន្តែពួកគេបដិសេធ ឬគេចវេះមិនចូលរួម ដែលយោងតាមច្បាប់ តុលាការមានសិទ្ធិបន្តដំណើរការនីតិវិធីបើកសវនាការដោយអវត្តមានជនជាប់ចោទបាន។ ការពន្យារពេលបើកសវនាការក្នុងករណីបែបនេះ អាចប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិផ្សេងទៀតរបស់ជនជាប់ចោទ។[54] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា ករណីខ្លះ ជនជាប់ចោទអវត្តមានក្នុងសវនាការ ដោយសារមូលហេតុជនជាប់ចោទត្រូវបានផ្ទេរទៅពន្ធនាគារផ្សេង ហើយតុលាការពុំទទួលបានព័ត៌មានបច្ចុប្បន្នភាពនោះទាន់ពេល ដូច្នោះក្រឡាបញ្ជីបានធ្វើការកោះហៅជនជាប់ចោទនៅពន្ធនាគារដែលបានជាប់ឃុំលើកដំបូង នេះបណ្តាលឱ្យជនជាប់ចោទមិនមានវត្តមានក្នុងសវនាការ ម្យ៉ាងទៀតជនជាប់ចោទខ្លះ គាត់បង់បោះសិទ្ធិមានវត្តមានរបស់គាត់។ តែយ៉ាងណា តុលាការព្យាយាមមិនប្រើនីតិវិធីសវនាការកំបាំងមុខទេ ពីព្រោះការធ្វើបែបនេះនឹងនាំឱ្យតុលាការមានចំណាត់ការទ្វេដងលើសំណុំរឿងដដែល។[55] សង្ឃឹមថាតុលាការនឹងបន្តអនុវត្តការប្តេជ្ញាចិត្តនេះ និងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងគោលបំណងត្រឡប់ទៅដូចការសម្រេចបាននៅឆ្នាំ២០២២ ឬអាចលើសនេះ។

សាលាឧទ្ធរណ៍ព្រះសីហនុ

នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ព្រះសីហនុមិនត្រឹមតែបានគោរពសិទ្ធិមានវត្តមាននៅពេលសវនាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានធ្វើឱ្យប្រសើរឡើងនូវការគោរពសិទ្ធិនេះគួរឱ្យកត់សម្គាល់ថែមទៀតផង។ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បានកត់ត្រាថា ជនជាប់ចោទមានវត្តមាន ៩១% (២០ ក្នុងចំណោម ២២) នៃសវនាការដែលបានសង្កេត ដែលកើនឡើងពី ៨៥% កាលពីឆ្នាំ២០២៤។ នេះគឺជាការ

---

[53] នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[54] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន ។

[55] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ប្រសើរឡើងគួរឱ្យកត់សម្គាល់ដែលខ្ពស់ជាងតួលេខនៅឆ្នាំ២០២៣ មានត្រឹមតែ ៩០% នៃសវនាការដែលបានសង្កេត ព្រមទាំងបង្ហាញអំពីវឌ្ឍនភាពកើនឡើងចាប់តាំងពីឆ្នាំ២០២២ ដែលមានតួលេខ ៧៤,៤% ប៉ុណ្ណោះ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

សាលាឧទ្ធរណ៍ត្បូងឃ្មុំបានបន្តការគោរពសិទ្ធិនេះនៅឆ្នាំ២០២៥ ដែលជនជាប់ចោទមានវត្តមានក្នុងសវនាការចំនួន ៩៤% (១២៤ ក្នុងចំណោម ១៣២) ជាតួលេខដូចគ្នាទៅនឹងឆ្នាំ២០២៤។ ការរក្សាបាននូវអត្រាដ៏ខ្ពស់បែបនេះគឺជាលទ្ធផលគួរឱ្យកត់សម្គាល់ជាវិជ្ជមាន ដោយហេតុថានៅឆ្នាំ២០២៣ ជនជាប់ចោទមានវត្តមានចំនួន ៧៣% ដែលទាបជាងកម្រិតកំណត់ថាបានការគោរពសិទ្ធិមានវត្តមាននៅពេលសវនាការ។ តាមរយៈការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងតុលាការ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអះអាងថា កន្លងមក តុលាការតែងតែកោះហៅជនជាប់ចោទឱ្យចូលរួមក្នុងសវនាការ ប៉ុន្តែជនជាប់ចោទខ្លះបានលះបង់សិទ្ធិមានវត្តមាននេះដោយសារហេតុផលផ្សេងៗ។[56] សាលាឧទ្ធរណ៍ត្បូងឃ្មុំក៏បានកត់សម្គាល់ផងដែរថា សាលាឧទ្ធរណ៍បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីធានាឱ្យមានវត្តមានជនជាប់ចោទ ដូចជា ការចេញដីកាកោះហៅច្រើនដង ការអនុញ្ញាតឱ្យមានការលើកពេលសវនាការ និងការធ្វើសវនាការកំប៉ាំងមុខតែនៅក្នុងករណីដែលចាំបាច់ខ្លាំងប៉ុណ្ណោះ។[57] ផ្អែកតាមតួលេខនេះឃើញថា មានការរីកចម្រើនគួរឱ្យកត់សម្គាល់នៃវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ សូមកោតសរសើរ និងលើកទឹកចិត្តសាលាឧទ្ធរណ៍ត្បូងឃ្មុំបន្តនូវការខិតខំប្រឹងប្រែងធ្វើឱ្យមានវឌ្ឍនភាពបែបនេះកាន់តែល្អប្រសើរបន្ថែមទៀត។

៣.៥ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

ច្បាប់អន្តរជាតិ	ច្បាប់ជាតិ
ក.អ.ស.ព.ន	**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
មាត្រា ១៤ (៣) (គ)	មាត្រា ៥៧

មាត្រា ១៤ (៣)(គ) នៃ ក.អ.ស.ព.ន ធានាថា ជនគ្រប់រូបដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវទទួលបានសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ ការពន្លឿននីតិវិធី គឺជាធាតុដ៏សំខាន់មួយនៃការជំនុំជម្រះដោយយុត្តិធម៌។[58]

ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដោយឆាប់រហ័ស គឺជាមូលដ្ឋានគ្រឹះមួយដើម្បីធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌។ កាលណាដំណើរការជំនុំជម្រះក្តីត្រូវបានអូសបន្លាយពេលកាន់តែយូរ នោះការជំនុំជម្រះ

---

[56] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងារគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន

[57] ដូចខាងលើ

[58] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៧។

ក៏កាន់តែមានការលំបាកដែរ ដូចជា ការប៉ះពាល់ដល់អត្ថិភាពនៃភស្តុតាង (ឧ. ការបាត់បង់ ការថយចុះតម្លៃភស្តុតាង ឬការបំផ្លាញភស្តុតាង) ហើយពេលវេលាកន្លងផុតយូរអាចនាំឱ្យប៉ះពាល់ការផ្តល់សក្ខីកម្មរបស់សាក្សី ឬការមានពេលចូលរួមរបស់ពួកគេ។ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល ចាត់ទុកថា ការរងចាំការជំនុំជម្រះអាចបង្កឱ្យមានផលវិនាសដល់ជីវភាពរស់នៅ ការរងការមាក់ងាយដែលអាចកើតចេញពីការត្រូវបានចោទប្រកាន់ និងផលប៉ះពាល់រយៈពេលវែង ហើយទទួលស្គាល់ទៀតថាជនជាប់ចោទត្រូវនៅតែសន្មតថាបុគ្គលគ្មានទោសរហូតទាល់តែមានភស្តុតាងបង្ហាញពីពិរុទ្ធភាព ដែលបន្ទុកនៃការបង្ហាញភស្តុតាងពីពិរុទ្ធភាពគឺតំណាងអយ្យការ។[59] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល គឺមិនត្រឹមតែដើម្បីការពារឧត្តមប្រយោជន៍របស់ជនជាប់ចោទនោះទេ ប៉ុន្តែក៏ដើម្បីបម្រើឧត្តមប្រយោជន៍នៃភាពយុត្តិធម៌ផងដែរ។[60]

សម្រាប់ជនជាប់ចោទជានីតិជន ច្បាប់កម្ពុជាមិនមានបញ្ញត្តិណាមួយចែងអំពីរយៈពេលជាក់លាក់ដែលសាលាឧទ្ធរណ៍ត្រូវចាត់ការលើបណ្តឹងឧទ្ធរណ៍របស់ខ្លួនឡើយ។ សម្រាប់ជនជាប់ចោទជាអនីតិជន មាត្រា ៥៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា បណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយកុមារទំនាស់នឹងច្បាប់ តុលាការត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ ខែ យ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹង លើកលែងតែក្នុងករណីមានមូលហេតុសត្យានុម័តមិនអាចជម្នះបាន។ គោលបំណងនៃការវិភាគនេះ ម.ស.ម.ក នឹងចាត់ទុកថា សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានគោរពតាម ប្រសិនបើតុលាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីសាលាឧទ្ធរណ៍បានទទួលបណ្តឹងឧទ្ធរណ៍។

នេះជាលើកដំបូង ដែលតុលាការគោលដៅទាំងបួនបានគោរពសិទ្ធិនេះ ដោយបានជំនុំជម្រះក្នុងអំឡុងពេលតិចជាង ៦ខែ បន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ ដែលមានចំនួន ៩១,៥% (៣៧៩ ក្នុងចំណោម ៤១៤) នៃសំណុំរឿងសរុប។ ចំណុចនេះគឺជាភាពល្អប្រសើរគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០២៤ ដែលមានតួលេខមានត្រឹមតែ ៨៦% (៤៥៦ ក្នុងចំណោម ៥៣០) ក្នុងចំណោមសំណុំរឿងទាំងអស់នៅក្នុងតុលាការឧទ្ធរណ៍ទាំងបួន។

តួលេខទី៧៖ ចន្លោះពេលរវាងការទទួលបានបណ្តឹងឧទ្ធរណ៍ រហូតដល់ថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងនោះរបស់តុលាការគោលដៅ[61]

---

[59] កម្រងមេរៀនរបស់ ម.ស.ម.ក ៖ សិទ្ធិមានសេរីភាព សិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមស្រប (ឬត្រូវដោះលែងខ្លួន) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/CCHR-Module-FTR
ម.ស.ម.ក កំណត់ត្រាសង្ខេប៖ ការរំលោភបំពានដែលអាចកើតមានទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់សកម្មជនមាតាធម្មជាតិកម្ពុជាចំនួនប្រាំនាក់ (ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥), https://tinyurl.com/CCHR-MNC-FTR

[60] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅលេខ ៣២ (CCPR/C/GC/32) ផ្នែក៣៥, https://tinyurl.com/HRC-GC-32

[61] ទិន្នន័យនេះផ្អែកលើចំនួនសំណុំរឿង ៤២២ ដែលត្រូវបានសង្កេតនៅឆ្នាំ២០២៥។

រយៈពេល	សាលាឧទ្ធរណ៍ភ្នំពេញ	សាលាឧទ្ធរណ៍បាត់ដំបង	សាលាឧទ្ធរណ៍តួងឃ្មុំ	សាលាឧទ្ធរណ៍សីហនុ	សរុបសំណុំរឿង
តិចជាង ៦ ខែ	២០៥	៦៤	៩៨	១២	៣៧៩
ចាប់ពី ៦ ខែដល់ ១ ឆ្នាំ	១៨	០	១	០	១៩
លើសពី ១ ឆ្នាំ ដល់ ២ ឆ្នាំ	១១	០	០	០	១១
លើសពី ២ ឆ្នាំ ដល់ ៣ ឆ្នាំ	២	០	០	០	២
លើសពី ៣ ឆ្នាំ	៣	០	០	០	៣
មិនមានទិន្នន័យ	៦	០	០	២	៨
សរុប	២៤៥	៦៤	៩៩	១៤	៤២២

សាលាឧទ្ធរណ៍ភ្នំពេញ

ក្នុងឆ្នាំ២០២៥ សំណុំរឿងដែលសាលាឧទ្ធរណ៍ភ្នំពេញបានជំនុំជម្រះក្នុងអំឡុងពេលតិចជាង ៦ ខែ បន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ មានចំនួន ៨៦% (២០៥ ក្នុងចំណោម ២៣៩) នៃសំណុំរឿងដែលបានសង្កេត ដែលនេះមានន័យថា សិទ្ធិនេះត្រូវបានគោរព។ នេះជាការល្អប្រសើរ គួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ ២០២៤ ដែលមានត្រឹមតែ ៧៨% ប៉ុណ្ណោះ ហើយនៅឆ្នាំ២០២៣ មាន ៦២% ។

នេះគឺជាឆ្នាំដំបូងដែលសាលាឧទ្ធរណ៍ភ្នំពេញបានគោរពសិទ្ធិនេះ ហើយសូមលើកទឹកចិត្តឱ្យបន្តរក្សា វឌ្ឍនភាពបន្ថែមទៀតនៅឆ្នាំបន្តបន្ទាប់ខាងមុខ។ ដោយឡែក នៅឆ្នាំ២០២៥ មានការកត់ត្រាថាមានសំណុំរឿង ចំនួន ១១ ដែលជនជាប់ចោទត្រូវរង់ចាំ ១-២ ឆ្នាំ ដើម្បីទទួលបានការជំនុំជម្រះ មានសំណុំរឿងចំនួន ២ ដែល ជនជាប់ចោទត្រូវរង់ចាំ ២-៣ ឆ្នាំ ដើម្បីទទួលបានការជំនុំជម្រះ ហើយករណីចំណាយពេលច្រើនជាងនេះគឺ មាន សំណុំរឿងចំនួន ៣ ដែលជនជាប់ចោទត្រូវរង់ចាំយូរជាង ៣ ឆ្នាំ។ ទោះបីជាតួលេខនេះជារួមមានលក្ខណៈល្អ ប្រសើរឡើងគិតចាប់ពីឆ្នាំ២០២៤ មកក៏ដោយ ក៏នៅតែមានការឆ្លុះបញ្ចាំងអំពីសំណុំរឿងមួយចំនួនដែលជន ជាប់ចោទត្រូវរង់ចាំដ៏យូរទើបទទួលបានការជំនុំជម្រះ។ ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាង សាលាឧទ្ធរណ៍ភ្នំពេញបានកត់សម្គាល់ថា ការពន្យារពេលមួយចំនួន គឺដោយហេតុថាជនជាប់ចោទបដិសេធមិន

ទទួលយកមេធាវីដែលតុលាការបានចាត់តាំងជូនខ្លួន។[62] ជាលទ្ធផល យោងតាមការលើកឡើងរបស់តំណាងសាលាឧទ្ធរណ៍ តុលាការត្រូវពន្យារពេលការជំនុំជម្រះ និងអនុញ្ញាតឱ្យជនជាប់ចោទស្វែងរកមេធាវីដោយខ្លួនឯង នេះហើយជាផ្នែកមួយនាំឱ្យមានការពន្យារពេលការជំនុំជម្រះ ហើយមូលហេតុផ្សេងទៀត រួមមាន អវត្តមានមេធាវី និងជនជាប់ចោទស្នើសុំពន្យារពេលការជំនុំជម្រះ។[63] តំណាងសាលាឧទ្ធរណ៍បានលើកឡើងថា តុលាការបានអនុលោមតាមច្បាប់ដើម្បីជានាថា សេចក្តីសម្រេចមានប្រសិទ្ធភាព តម្លាភាព និងអាចទទួលយកបានហើយ សេចក្តីសម្រេចផ្តល់ដល់ភាគីក្នុងពេលឆាប់រហ័សដែលស្របតាមយុទ្ធនាការរបស់ក្រសួងយុត្តិធម៌ ហើយតុលាការក៏បានផ្តល់អាទិភាពទៅលើសំណុំរឿងមួយចំនួន រួមមាន សំណុំរឿងដែលពាក់ព័ន្ធនឹងអនីតិជន បទល្មើសចរាចរណ៍ ក្មេងទំនើង និងគ្រឿងញៀន ព្រមទាំងសំណុំរឿងដែលជនជាប់ចោទត្រូវបានឃុំខ្លួនផងដែរ។[64] តុលាការមានវឌ្ឍនភាពល្អប្រសើរ ដូច្នោះតុលាការគួររក្សាបន្តការខិតខំដើម្បីពន្លឿនដំណើរការបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ បន្ថែមទៀត។

សាលាឧទ្ធរណ៍បាត់ដំបង

គួរឱ្យលើកទឹកចិត្ត និងកត់សម្គាល់ជាវិជ្ជមាន ដែលសវនាការលើបណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងក្នុងអំឡុងពេលតិចជាងប្រាំមួយខែគិតចាប់ពីពេលទទួលបានបណ្តឹងឧទ្ធរណ៍មានចំនួន១០០% (៦៤ ក្នុងចំណោម ៦៤) នៃសំណុំរឿងដែលបានជំនុំជម្រះនៅចំពោះមុខសាលាឧទ្ធរណ៍បាត់ដំបងនៅឆ្នាំ២០២៥។ សាលាឧទ្ធរណ៍បាត់ដំបងសម្រេចបានលទ្ធផល គួរឱ្យកត់សម្គាល់ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលជាប្រចាំ នៅឆ្នាំ២០២២ ទទួលបាន ៩៦,៤% នៅឆ្នាំ ២០២៣ មានចំនួន ៩៥,៣% និងនៅឆ្នាំ២០២៤ មានចំនួន ៩៦%។ នេះជាលទ្ធផលគួរឱ្យលើកទឹកចិត្ត សង្ឃឹមថាតុលាការនឹងរក្សាការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលបន្តទៀត។

សាលាឧទ្ធរណ៍ព្រះសីហនុ

នៅសាលាឧទ្ធរណ៍ព្រះសីហនុនៅឆ្នាំ២០២៥ ការជំនុំជម្រះដែលបានធ្វើឡើងក្នុងអំឡុងពេលតិចជាងប្រាំមួយខែបន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍ មានចំនួន ១០០% (១២ ក្នុងចំណោម១២ សំណុំរឿង) ដែលបានសង្កេត គឺកើនឡើងគួរឱ្យកត់សម្គាល់ជាវិជ្ជមានផងដែរ បើធៀបនឹងឆ្នាំ២០២៤ មានត្រឹម ៩១% និងធៀបនឹងឆ្នាំ២០២៣ មានចំនួន ៩៩%។ តំណាងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុបានបញ្ជាក់កាលពីមុននៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក ថា ការជំនុំជម្រះលើជនជាប់ចោទដែល

---

[62] នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[63] ដូចខាងលើ

[64] ដូចខាងលើ

ស្ថិតក្នុងឃុំត្រូវបានពន្លឿន ដោយមានការលើកទឹកចិត្ត និងការគាំទ្រពីក្រសួងយុត្តិធម៌។[65] ទោះបីជាយ៉ាងណាក៏ដោយ ករណីខ្លះអាចមានការយឺតយ៉ាវដោយសារកត្តាមួយចំនួន ដូចជា ករណីជនជាប់ចោទនៅក្រៅឃុំ ជនជាប់ចោទបានប្តឹងទាស់នឹងសាលដីកាកំបាំងមុខ ឬជនជាប់ចោទត្រូវបានកោះហៅច្រើនដងតែមិនចូលរួមក្នុងសវនាការ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ត្បូងឃ្មុំបានបន្តរក្សាវឌ្ឍនភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំពាក់ព័ន្ធនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល។ មានតួលេខ ៩៩% (៩៨ ក្នុងចំណោម ៩៩) នៃសំណុំរឿងដែលបានសង្កេតដែលការជំនុំជម្រះបានធ្វើឡើងក្នុងអំឡុងពេលតិចជាងប្រាំមួយខែគិតចាប់ពីថ្ងៃទទួលបានបណ្តឹងឧទ្ធរណ៍។ នេះជាការកើនឡើងគួរឱ្យកត់សម្គាល់ពី ៩២% នៅឆ្នាំ២០២៤ និង ៨៣,៣% នៅឆ្នាំ២០២៣។ មានសំណុំរឿងចំនួនមួយដែលតុលាការបានជំនុំជម្រះក្នុងអំឡុងពេល ៦-១២ ខែ បន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍។ សង្ឃឹមថាតុលាការនឹងបន្តនូវកិច្ចខិតខំប្រឹងប្រែងរក្សាតួលេខនេះដើម្បីធានាថាសិទ្ធិនេះត្រូវបានគោរព។

នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងតុលាការបានលើកឡើងពីបញ្ហាដែលអាចជាកត្តារួមចំណែកក្នុងការពន្យារពេលសវនាការ ដូចជាសំណុំរឿងដែលត្រូវការអ្នកបកប្រែ និងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ តុលាការតម្រូវឱ្យមានវត្តមានមេធាវីការពារក្តី ភ្នាក់ងារសង្គមកិច្ច និងឪពុកម្តាយ ឬអាណាព្យាបាលនៅក្នុងសវនាការ។[66] ប្រសិនបើភាគីណាមួយដូចដែលបានរៀបរាប់អវត្តមាន នោះសវនានការនឹងត្រូវបានពន្យារពេល។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានអះអាងថា ពេលតុលាការបានទទួលបណ្តឹងឧទ្ធរណ៍លើសំណុំរឿងព្រហ្មទណ្ឌណាមួយ តុលាការតែងតែរៀបចំកម្មវិធីសវនាការភ្លាមផ្អែកតាមពេលវេលា និងសាលសវនាការសមស្រប។ តុលាការព្យាយាមមានចំណាត់ការឱ្យបានលឿន លើកលែងតែមានការស្នើសុំពន្យារពេលពីមេធាវីការពារ ករណីសាក្សីមិនចូលបំភ្លឺតាមការកោះហៅដូច្នោះតម្រូវឱ្យតុលាការកោះហៅច្រើនដង និងសំណុំរឿងមួយចំនួនត្រូវការពេលវេលាសិក្សាស្រាវជ្រាវបន្ថែមដើម្បីមានមូលដ្ឋានមុននឹងចេញនូវសេចក្តីសម្រេច។[67] ជាលទ្ធផល សាលាឧទ្ធរណ៍ត្បូងឃ្មុំបានរក្សានូវកំណត់ត្រាដ៏គួរឱ្យកត់សម្គាល់ជាវិជ្ជមានក្នុងការគោរពសិទ្ធិនេះ។

---

[65] នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[66] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[67] នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

៣.៦ ការប្រតិបត្តិវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា		
ក.អ.ស.ព.ន	រដ្ឋធម្មនុញ្ញ	ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា	ក្រមសីលធម៌ចៅក្រមកម្ពុជា
មាត្រា ១៤(១) និង ១៤(៥)	មាត្រា ១២៨ និង ១៣២	មាត្រា ៨, ៥០ និង ៧៧	មាត្រា ២ និង ៨

មាត្រា ១៤(១) នៃ ក.អ.ស.ព.ន ជានាសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង គឺជាសរសេរស្តម្ភនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[68] ប្រសិនបើគ្មានការគោរពសិទ្ធិនេះទេ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្សេងទៀត លែងមានប្រយោជន៍ហើយ។ ជាការពិត សាលាជម្រះក្តីដែលមិនមានសមត្ថកិច្ច ឯករាជ្យ និងលម្អៀង មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងការគ្រប់គ្រងយុត្តិធម៌ឱ្យបានត្រឹមត្រូវនោះទេ។ ដូចនេះ ចៅក្រមត្រូវតែប្រកាន់ខ្ជាប់វិជ្ជាជីវៈគ្រប់ពេលដើម្បីបង្ហាញថាមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង។

វិសាលភាពដែលតុលាការបំពេញកាតព្វកិច្ចនៃភាពមិនលំអៀងនេះ ត្រូវបានលើកឡើងថាជាចំណុចនៃការព្រួយបារម្ភដោយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ទោះបីជារដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីពង្រឹងឯករាជ្យភាពរបស់ខ្លួនក៏ដោយ។ [69] ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងវដ្តទីបួននៃ «យូកឺអ» នាពេលថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍ចំនួនបីទាក់ទងនឹងប្រព័ន្ធតុលាការ និងឯករាជភាពតុលាការ ដែលជាការបង្ហាញអំពីការលើកទឹកចិត្តថា រដ្ឋាភិបាលមានបំណងបន្តធ្វើការដើម្បីដោះស្រាយបញ្ហានេះ។[70]

នៅកម្ពុជា ការប្រតិបត្តិរបស់ចៅក្រម គឺមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងក្រមសីលធម៌ចៅក្រមកម្ពុជា ដែលតម្រូវឱ្យចៅក្រមមិនរងសម្ពាធពីគ្រប់ទម្រង់នៃឥទ្ធិពលណាមួយពីសំណាក់គូភាគី ឬបុគ្គល ក្រុម ឬស្ថាប័នណាមួយ និងធ្វើសេចក្តីសម្រេចលើសំណុំរឿងដោយមនសិការ ការគោរព ការអត់ធ្មត់ សុជីវធម៌ និងសីលធម៌បំផុត ដើម្បីធានានូវយុត្តិធម៌ជូនដល់ភាគី។ ហេតុដូច្នេះហើយ តុលាការត្រូវចំណាយពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីសិក្សាសំណុំរឿងឱ្យបានហ្មត់ចត់ ក្នុងគោលបំណងធានាថាសំណុំរឿងត្រូវ

---

[68] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/3s3n2489

[69] គណៈកម្មាធិការសិទ្ធិមនុស្ស "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ" វាក្យខណ្ឌ ៣២

[70] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, របាយការណ៍របស់ក្រុមការងារស្តីពីការពិនិត្យឡើងវិញជាសកលតាមកាលកំណត់សម្រាប់កម្ពុជា A/HRC/57/17/Add.1,(១៥ សីហា ២០២៤), https://tinyurl.com/UPR-Recs

បានវិនិច្ឆ័យយ៉ាងត្រឹមត្រូវ និងច្បាស់លាស់ ហើយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរពយ៉ាងពេញលេញ។

សម្រាប់បួនឆ្នាំជាប់ៗគ្នានេះ ពុំមានចៅក្រម តំណាងមហាអយ្យការ និងមេធាវីការពារណាម្នាក់ប្រើពាក្យសម្តីដែលមានការរើសអើងលើភាគីណាមួយ រួមទាំងជនជាប់ចោទ នៅក្នុងដំណើរការជំនុំជម្រះឡើយ។ ចំណុចដែលគួរឱ្យកត់សម្គាល់ជាវិជ្ជមាន គឺពុំមានករណីដែលចៅក្រម តំណាងមហាអយ្យការ ឬមេធាវីការពារ បង្ហាញពីការបំភិតបំភ័យដល់ភាគីណាមួយទេ។

ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មិនមានករណីការសន្ទនាតាមទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិចក្នុងអំឡុងពេលសវនាការដោយចៅក្រម តំណាងមហាអយ្យការ ឬមេធាវីការពារនៅតុលាការគោលដៅទាំងបួនទេ ដែលបង្ហាញពីការបានគោរពនូវវិជ្ជាជីវៈរបស់ខ្លួន។

ពាក់ព័ន្ធនឹងរយៈពេលសវនាការ ដោយហេតុថា ពុំមានបទដ្ឋានបច្ចេកទេសណាមួយដែលណែនាំអំពីរយៈពេលសវនាការឡើយ ដូច្នេះ ម.ស.ម.ក មិនចាត់ទុករយៈពេលសវនាការជាកត្តាកំណត់ជាផ្លូវការក្នុងការវាយតម្លៃថាតើ សិទ្ធិទទួលបានការជំនុំជម្រះដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ត្រូវបានគោរព ឬយ៉ាងណាឡើយ។ ទោះបីយ៉ាងណា គេចាត់ទុកថាចំណុចនេះនៅតែមានភាពពាក់ព័ន្ធដែលគួរតែលើកឡើងក្នុងរបាយការណ៍នេះផងដែរ ជាពិសេសដោយសារតែ សវនាការភាគច្រើននៅតុលាការគោលដៅមានរយៈពេលខ្លីគួរកត់សម្គាល់។

តួលេខទី៨៖ រយៈពេលនៃសវនាការដែលបានសង្កេត នៅតាមតុលាការគោលដៅ[71]

ទិន្នន័យជារួម

រយៈពេលសវនាការ	១៥នាទីចុះក្រោម	១៦-៣០ នាទី	៣១នាទី-១ ម៉ោង	លើសពី១ ម៉ោង	សរុប
បទឧក្រិដ្ឋ	៣៦	៥១	៥៣	១៤	១៥៤
បទមជ្ឈិម	១០៨	៩៤	៤៤	១៧	២៧១
បទលហុ	១	១	៣	០	៥
សរុប	១៤៥	១៤៦	១០០	៣១	៤២២
សរុបជា %	៣៤%	៣៥%	២៤%	៧%	១០០%

[71] ទិន្នន័យនេះ ផ្អែកលើរយៈពេលនៃសវនាការដែលបានកត់ត្រាក្នុងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅឆ្នាំ២០២៥។

សាលាឧទ្ធរណ៍ភ្នំពេញ

រយៈពេលសវនាការ	១៥នាទីចុះក្រោម	១៦-៣០ នាទី	៣១នាទី–១ ម៉ោង	លើសពី១ ម៉ោង	សរុប
បទឧក្រិដ្ឋ	២៩	៣៥	៣៣	៨	១០៥
បទមជ្ឈិម	៧៣	៣៨	២១	៦	១៣៨
បទល្មើស	១	០	១	០	២
សរុប	១០៣	៧៣	៥៥	១៤	២៤៥
សរុបជា%	៤២%	៣០%	២២%	៦%	១០០%

សាលាឧទ្ធរណ៍បាត់ដំបង

រយៈពេលសវនាការ	១៥នាទីចុះក្រោម	១៦-៣០ នាទី	៣១នាទី–១ ម៉ោង	លើសពី១ ម៉ោង	សរុប
បទឧក្រិដ្ឋ	៥	៨	៤	៣	២០
បទមជ្ឈិម	១៩	២៣	២	០	៤៤
បទល្មើស	០	០	០	០	០
សរុប	២៤	៣១	៦	៣	៦៤
សរុបជា%	៣៨%	៤៨%	៩%	៥%	១០០%

សាលាឧទ្ធរណ៍ព្រះសីហនុ

រយៈពេលសវនាការ	១៥នាទីចុះក្រោម	១៦-៣០ នាទី	៣១នាទី–១ ម៉ោង	លើសពី ១ ម៉ោង	សរុប
បទឧក្រិដ្ឋ	១	០	៣	០	៤
បទមជ្ឈិម	២	៣	២	២	៩
បទល្មើស	០	០	១	០	១

សរុប	៣	៣	៦	២	១៤
សរុបជា%	២១%	២១%	៤៣%	១៤%	១០០%

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

រយៈពេលសវនាការ	១៥នាទីចុះក្រោម	១៦-៣០ នាទី	៣១នាទី–១ ម៉ោង	លើសពី ១ ម៉ោង	សរុប
បទឧក្រិដ្ឋ	១	៨	១៣	៣	២៥
បទមជ្ឈិម	១៤	៣០	១៩	៩	៧២
បទលហុ	០	១	១	០	២
សរុប	១៥	៣៩	៣៣	១២	៩៩
សរុបជា%	១៥%	៣៩%	៣៩%	១២%	១០០%

យោងតាមគោលការណ៍ណែនាំរបស់គណៈកម្មាធិការសិទ្ធិមនុស្ស សិទ្ធិទទួលបានការពិនិត្យឡើងវិញលើការកាត់ទោសរបស់បុគ្គលម្នាក់ដោយសាលាក្តីជាន់ខ្ពស់មួយ កំណត់ឱ្យរដ្ឋភាគីមានកាតព្វកិច្ចពិនិត្យយ៉ាងហ្មត់ចត់ផ្អែកលើភស្តុតាង និងច្បាប់ ការផ្តន្ទាទោស និងការកាត់ទោសដែលនីតិវិធីនេះអនុញ្ញាតឱ្យមានការពិចារណាយ៉ាងត្រឹមត្រូវលើលក្ខណៈនៃសំណុំរឿង។ មុននឹងសម្រេចថា តើមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃការរកឃើញថាមានពិរុទ្ធភាព ឬយ៉ាងណា តុលាការជាន់ខ្ពស់ត្រូវពិនិត្យមើលការចោទប្រកាន់ដែលប្រឆាំងនឹងជនជាប់ចោទឱ្យបានលម្អិត ហើយពិចារណាលើភស្តុតាងដែលបានដាក់ជូននៅពេលសវនាការ និងការបញ្ជូនបន្តនៅពេលមានការប្តឹងឧទ្ធរណ៍។[72] ទោះបីជាមិនមានបទដ្ឋានណាមួយកំណត់ក៏ដោយ ប៉ុន្តែគេអាចឆ្លុះបញ្ចាំងថា សវនាការដែលមានរយៈពេលតិចជាង ៣០ នាទី ជាពិសេសនៅពេលដែលសវនាការនោះ គឺពាក់ព័ន្ធនឹងបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ជាការលំបាកយ៉ាងខ្លាំងក្នុងការផ្តល់បរិយាកាសអំណោយផលពេញលេញក្នុងសវនាការដល់ភាគីនៃសំណុំរឿង ហើយចៅក្រមក៏អាចលំបាកក្នុងការពិនិត្យ និងដេញដោលលើសំណុំរឿងឱ្យបានគ្រប់ជ្រុងជ្រោយផងដែរ។

ឆ្នាំ២០២៥ សវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញបានធ្វើឡើងក្នុងរយៈពេល ១៥ នាទី ឬតិចជាងនេះមាន ៤២% (១០៣ ក្នុងចំណោម ២៤៥) នៃសវនាការសរុប។ ទោះបីជាតួលេខនេះបង្ហាញពីភាពល្អប្រសើរ បើ

[72] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣២។

ធៀបនឹងឆ្នាំ២០២៤ យ៉ាងណាក្តី នៅពេលដែលជិតពាក់កណ្តាលនៃសំណុំរឿងដែលបានសង្កេត សវនាការមានរយៈពេល ១៥ នាទី ឬតិចជាងនេះ បង្ហាញពីការការអនុវត្តគួរពិនិត្យឡើងវិញ។ ៣០% នៃសវនាការដែលមានរយៈពេលចាប់ពី ១៦ ដល់ ៣០ នាទី ច្រើនជាងមួយភាគបួននៃសវនាការដែលបានសង្កេត។ ជារួមសវនាការដែលមានរយៈពេលតិចជាង ៣០ នាទី (១៧៦ ក្នុងចំណោម ២៤៥ សវនាការ) ហើយមាន ៣៦% (៦៤ ក្នុងចំណោម ១៧៦ សវនាការ) ជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋ។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក កាលពីលើកមុនៗ សាលាឧទ្ធរណ៍ភ្នំពេញ និងតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍នេះ បានលើកឡើងថា សវនាការជាទូទៅមានរយៈពេលខ្លី នៅពេលដែលជនជាប់ចោទមានតែម្នាក់ ជនជាប់ចោទអវត្តមាន ឬជនជាប់ចោទបានសារភាព ឬនៅពេលដែលមានភស្តុតាងស៊ីចង្វាក់ច្បាស់លាស់ ដើម្បីឈានទៅដល់ការសម្រេចដោយពុំចាំបាច់មានការជជែកដេញដោលច្រើន។[73] តុលាការបានបញ្ជាក់ថា សវនាការដែលមានរយៈពេល ១៥ នាទី ឬតិចជាងនេះ គឺផ្អែកលើស្ថានភាពសំណុំរឿង ដូចជា បណ្តឹងឧទ្ធរណ៍ដែលពុំស្របតាមនីតិវិធី ការដកបណ្តឹងឧទ្ធរណ៍ អវត្តមានគូភាគី ឬបទល្មើសមជ្ឈិម។[74]

ឆ្នាំ២០២៥ សាលាឧទ្ធរណ៍បាត់ដំបងមានតួលេខថយចុះគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងរយៈពេលនៃសវនាការ។ មាន ៣៨% (២៤ ក្នុងចំណោម ៦៤) នៃសវនាការមានរយៈពេល ១៥ នាទី ឬតិចជាងនេះ និង ៤៨% (៣១ ក្នុងចំណោម ៦៤) នៃសវនាការមានរយៈពេល ១៦ - ៣០ នាទី។ នេះមានន័យថា ៨៦% (៥៥ ក្នុងចំណោម ៦៤) នៃសវនាការមានរយៈពេលកន្លះម៉ោង ឬតិចជាងនេះ ដែលជាតួលេខគួរឱ្យពិចារណា និងពិនិត្យឡើងវិញ។ ជាការកើនឡើងបើធៀបនឹងឆ្នាំ២០២៤ មានតែ ៧៩% ប៉ុណ្ណោះ។ មួយវិញទៀត ក្នុងចំណោមសវនាការដែលមានរយៈពេល ៣០ នាទី ឬតិចជាងនេះ មាន ២៣,៦% (១៣ ក្នុងចំណោម ៥៥) គឺជាសំណុំរឿងបទឧក្រិដ្ឋ ដែលជាចំណុចល្អប្រសើរ បើធៀបទៅនឹងឆ្នាំមុនដោយមានតួលេខ ២៧% (៣៩ ក្នុងចំណោម ១៤៤) នៅសាលាឧទ្ធរណ៍បាត់ដំបង។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានអះអាងថា សំណុំរឿងដែលចៅក្រមប្រើរយៈពេលវែង ឬខ្លីមិនអាស្រ័យលើសំណុំរឿងជាបទឧក្រិដ្ឋ ឬមជ្ឈិមនោះទេ ដូច្នោះវាផ្អែកលើស្ថានភាពជាក់ស្តែងនៃសំណុំរឿង បើមានរយៈពេលខ្លី អាចថាជនជាប់ចោទបានសារភាពកំហុស ហើយបណ្តឹងឧទ្ធរណ៍របស់គាត់ គឺសុំតែបន្ធូរបន្ថយទោសតែប៉ុណ្ណោះ ទោះជាបែបនេះក្តី ចៅក្រមក៏អាចសួរបញ្ជាក់ពីអង្គហេតុខ្លះៗដែរ ដើម្បីមានមូលដ្ឋានក្នុងការសម្រេចសេចក្តីថាត្រូវសម្រាលទោស ឬយ៉ាងណា។[75]

---

[73] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[74] លិខិតលេខ ៧០៦/២៤ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៤ ដោយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ឆ្លើយតបទៅនឹងរបកគំហើញក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៣ របស់ ម.ស.ម.ក ស្តីពីសិទ្ធិជំនុំជម្រះដោយយុត្តិធម៌។

[75] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

សាលាឧទ្ធរណ៍ព្រះសីហនុបង្ហាញអំពីភាគរយនៃសវនាការដែលមានរយៈពេល ១៥ នាទី ឬតិចជាងនេះ មានការកើនឡើង ហើយភាគរយនៃសវនាការដែលមានរយៈពេលពី ៣១ ដល់ ៦០ នាទី ក៏មានការកើនឡើងផងដែរ។ នៅឆ្នាំ២០២៥ មាន ២១% (៣ ក្នុងចំណោម ១៤) នៃសវនាការមានរយៈពេល ១៥ នាទី ឬតិចជាងនេះកើនឡើងពី ១៤% បើធៀបនឹងឆ្នាំ២០២៤ ក្នុងចំណោម២១ % នេះ មានមួយសំណុំរឿងជាបទឧក្រិដ្ឋដែលចៅក្រមចំណាយពេល១៥ នាទី ឬតិចជាងនេះ គឺជាសំណុំរឿងប្តឹងសុំបន្ធូរបន្ថយទោសដែលជនជាប់ចោទបានសារភាពកំហុស ចំណែកឯ សវនាការមានរយៈពេល ៣១ នាទី ទៅមួយម៉ោង មានតួលេខ ៤៣% (៦ ក្នុងចំណោម ១៤) ដែលកើនឡើងគួរឱ្យកត់សម្គាល់ជាវិជ្ជមាន បើធៀបនឹងឆ្នាំ២០២៤ មានត្រឹម១៧%។ សវនាការដែលមានរយៈពេល ១៦ ទៅ ៣០ នាទី មានចំនួន ២១% នៃសំណុំរឿងដែលបានសង្កេត ដែលថយចុះបើធៀបនឹងឆ្នាំ២០២៤ មានដល់ ៤៤% ។ ទោះបីយ៉ាងណា នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ព្រះសីហនុនៅតែមានតួលេខខ្ពស់ជាងគេ ក្នុងចំណោមតុលាការគោលដៅទាំងបួនពាក់ព័ន្ធនឹងសំណុំរឿងដែលសវនាការមានរយៈពេលលើសពីមួយម៉ោងចំនួន ១៤%។ យ៉ាងណាមិញ តួលេខ ១៤% នេះ គឺថយចុះដ៏បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ២៥%។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា ចំពោះសវនាការធ្វើឡើងក្នុងរយៈពេលខ្លី គឺដោយសារតែចៅក្រមមានកស្តុតាងគ្រប់គ្រាន់ ហើយជនជាប់ចោទបានសារភាពកំហុស និងបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ គឺគ្រាន់តែសុំការបន្ធូរបន្ថយទោសដែលសាលាដំបូងបានផ្តន្ទាទោស។[76]

សាលាឧទ្ធរណ៍ត្បូងឃ្មុំ មានការថយចុះនូវការអនុវត្តពាក់ព័ន្ធនឹងរយៈពេលសវនាការ ១៥ នាទី ឬតិចជាងនេះដែលមានចំនួន ១៥% (១៥ ក្នុងចំណោម ៩៩ សំណុំរឿង) នៅឆ្នាំ២០២៥ ដែលមានការកើនឡើងបើធៀបឆ្នាំ២០២៤ មានត្រឹម៦% ប៉ុណ្ណោះ។ ចំណែកឯសំណុំរឿងដែលសវនាការមានរយៈពេល ៣១ ដល់ ៦០ នាទី មាន ៣៣% (៣៣ ក្នុងចំណោម ៩៩) ថយចុះពី ៤៤% រីឯសវនាការមានរយៈពេលលើសពីមួយម៉ោងមាន ១២% (១២ ក្នុងចំណោម ៩៩) បើធៀបនឹងឆ្នាំ២០២៤ មានដល់ ១៨%។ ក្នុងចំណោមសំណុំរឿងចំនួន ៥៤ ដែលសវនាការមានរយៈពេលកន្លះម៉ោង ឬតិចជាងនេះ ក្នុងនោះមានសំណុំរឿងចំនួន ៩ ជាសំណុំរឿងបទឧក្រិដ្ឋ។ តំណាងតុលាការបានបញ្ជាក់ថា ទោះបីជាជនជាប់ចោទសារភាពក៏ដោយ ចៅក្រមនឹងបន្តសួរចម្លើយដើម្បីផ្ទៀងផ្ទាត់ថាតើការសារភាពនោះពិត ឬយ៉ាងណា។ លើសពីនេះ តុលាការបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនថានឹងធ្វើការកែលម្អបន្ថែមទៀត ដើម្បីលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដោយផ្អែកលើរបកគំហើញពីការសង្កេតសវនាការរបស់ ម.ស.ម.ក។[77]ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាង

---

[76] នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៦ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[77] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

សាលាឧទ្ធរណ៍ត្បូងឃ្មុំបានអះអាងថា ចៅក្រមសួរដេញដោលភាគីនៃសំណុំរឿងក្នុងពេលសវនាការមានរយៈពេលខ្លី ឬវែងគឺវាអាស្រ័យលើទិដ្ឋភាពនៃសំណុំរឿងជាក់ស្តែងថាតើជាសំណុំរឿងស្មុគស្មាញ ឬមិនស្មុគស្មាញ។[78]

[78] នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលតុលាការមួយចំនួនបានគោរព

៤.១ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	ក្រមនីតិវិធីព្រហ្មទណ្ឌ	ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
មាត្រា ១៤(១)	មាត្រា ៣៩២	មាត្រា ៧

ជនគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានពិរុទ្ធភាព ឬគ្មានទោស នៅក្នុងការជំនុំជម្រះជាសាធារណៈ។[79] ករណីលើកលែងតែសវនាការសាធារណៈនោះអាចបង្ក "ការប៉ះពាល់យ៉ាងច្បាស់" ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ ឬសីលធម៌ ផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគី (ជាពិសេស ក្នុងសំណុំរឿងរំលោភផ្លូវភេទមួយចំនួន) ឬវត្តមានកុមារដែលទំនាស់នឹងច្បាប់។[80] ក្នុងករណីទាំងនេះ ការកាត់ក្តីនឹងប្រព្រឹត្តទៅដោយអសាធារណៈ។

ការធានានៅក្នុងករណីនៃសវនាការអសាធារណៈ:

ទោះបីជាសាធារណជនទាំងអស់ ឬសាធារណជនមួយចំនួនមិនត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងសវនាការដោយសារកាល:ទេស:ពិសេសក៏ដោយ ក៏ភាពជាសាធារណៈនៅតែធានាការពារឱ្យមានដំណែងដែរ។ ក្នុងស្ថានភាពបែបនេះ សេចក្តីសម្រេច រួមទាំងការរកឃើញសំខាន់ៗ កស្តុតាង និងសំអាងហេតុផ្លូវច្បាប់ត្រូវតែធ្វើឡើងជាសាធារណៈ។ មានតែក្នុងករណីមួយចំនួនតូចប៉ុណ្ណោះ (ឧទាហរណ៍ៈ ប្រសិនបើមានភាពចាំបាច់ដើម្បីជាប្រយោជន៍របស់កុមារ) ទើបមានការលើកលែងចំពោះការធានានូវភាពជាសាធារណៈនេះ។

មានតែក្នុងកាល:ទេស:ពិសេសដែលច្បាប់កំណត់ប៉ុណ្ណោះ ទើបសាធារណជនទាំងអស់ ឬមួយផ្នែកមិនអាចត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងសវនាការបាន។[81] នៅក្នុងកាល:ទេស:ផ្សេងទៀត សវនាការត្រូវតែធ្វើឡើងជាសាធារណៈដោយរាប់បញ្ចូលទាំងសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយផងដែរ ហើយមិនគួរមានក្រុមមនុស្សជាក់លាក់ណាមួយត្រូវបានដាក់ចេញឡើយ។[82] ជាផ្នែកមួយនៃសិទ្ធិនេះ តុលាការមានកាតព្វកិច្ចផ្សព្វផ្សាយព័ត៌មានអំពីពេលវេលា និងទីកន្លែងនៃសវនាការជាសាធារណៈ និងផ្តល់មធ្យោបាយគ្រប់គ្រាន់ក្នុងកម្រិតសមរម្យ

---

[79] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/2c67u8sn

[80] គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (អ.ស.ក) សេចក្តីពន្យល់ទូទៅលេខ ២៤ ស្តីពីសិទ្ធិកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ (ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៩) អ.ស.ក/C/GC/២៤ វាក្យខណ្ឌ ៦៧ https://tinyurl.com/2s4kka66

[81] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៩។

[82] ដូចខាងលើ

សម្រាប់សាធារណជនបានចូលរួម។[83] គួរមានការធានាថា សាធារណជន និងអ្នកសារព័ត៌មានដែលចង់ចូលរួមសវនាការដែលធ្វើឡើងជាសាធារណៈ មិនចាំបាច់មានការស្នូរនាំអំពីហេតុផលនៃការចូលរួមនោះទេ និងការតម្រូវឱ្យមានការចុះឈ្មោះចូលរួមសវនាការគួរតែជៀសវាងនៅគ្រប់ករណីទាំងអស់។ គួរកត់សម្គាល់ថា មានការហាមឃាត់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយមួយចំនួនចូលរួមសង្កេតសវនាការនៃសំណុំរឿងអ្នកការពារសិទ្ធិមនុស្ស និងសមាជិកនៃគណៈបក្សនយោបាយ។[84]

ក្លេខទី៩៖ ភាគរយនៃសំណុំរឿងដែលមានការបិទផ្សាយកាលវិភាគសវនាការសរុប[85]



ការបិទផ្សាយកាលវិភាគសវនាការ ដែលបង្ហាញអំពីកាលបរិច្ឆេទ ទីតាំង និងពេលវេលាចាប់ផ្តើមសវនាការនៅខាងក្រៅបន្ទប់សវនាការ ឬផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ គឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការលើកកម្ពស់ការជំនុំជម្រះជាសាធារណៈ និងផ្តល់ព័ត៌មានដល់សាធារណជន និងជួយសម្រួលដល់ការចូលទៅកាន់បន្ទប់សវនាការដែលត្រូវជំនុំជម្រះនោះ។

គួរឱ្យកត់សម្គាល់ជាវិជ្ជមាននូវការអនុវត្តច្រើនឆ្នាំជាប់គ្នា ពុំមានការរារាំងការចូល ឬការបណ្តេញសាធារណជន ឬសមាជិកនៃប្រព័ន្ធផ្សព្វផ្សាយចេញពីបន្ទប់សវនាការ ក្នុងសំណុំរឿងដែលបានសង្កេតនៅសាលាឧទ្ធរណ៍ទាំងបួន នៅឆ្នាំ២០២៥ ឡើយ។ មានសវនាការចំនួន ៩៣% បានសង្កេតនៅតាមតុលាការគោលដៅទាំងបួន បានបិទផ្សាយកាលវិភាគសវនាការនៅខាងក្រៅបន្ទប់សវនាការ និង/ឬបង្ហោះតាមអនឡាញ។ នេះ

---

[83] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ២៨ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ២១៥/១៩៨៦, *រវាង* Van Meurs *និងប្រទេសហូឡង់ (ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០)* CCPR/C/៣៩/D/២១៥/១៩៨៦, វាក្យខណ្ឌ ៦.២, https://tinyurl.com/2nc55r5f

[84] វិទ្យុអាស៊ីសេរី សកម្មជនមាតាធម្មជាតិកម្ពុជាបដិសេធមិនចូលរួមសវនាការ (៣ មិថុនា ២០២៤) https://tinyurl.com/RFI-MNC-Media

[85] ទិន្នន័យនេះ ផ្អែកលើចំនួនសំណុំរឿងសរុបចំនួន ៤២២ ដែលត្រូវបានសង្កេតនៅឆ្នាំ២០២៥។

គឺជាឆ្នាំទីបីជាប់ៗគ្នា ដែលការអនុវត្តនេះមានការកើនឡើងពី៨៨% នៅឆ្នាំ២០២៤ និង៨៤% នៅឆ្នាំ២០២៣។ ទោះជាយ៉ាងនេះក្តី ការអនុវត្តរបស់សាលាឧទ្ធរណ៍ភ្នំពេញ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ត្បូងឃ្មុំ មានភាពប្រសើរឡើងក៏ដោយ ក៏សិទ្ធិនេះមិនទាន់អាចចាត់ថ្នាក់ថាត្រូវបានគោរពពេញលេញដោយសាលាឧទ្ធរណ៍ទាំងបួនដែរ ដោយសារការអនុវត្តរបស់សាលាឧទ្ធរណ៍ព្រះសីហនុ មិនទាន់លើកកម្ពស់សិទ្ធិនេះបានពេញលេញនៅឡើយ ហើយនេះគឺជាឆ្នាំទីពីរជាប់គ្នាដែលសាលាឧទ្ធរណ៍ព្រះសីហនុមិនទាន់បានអនុវត្តពេញលេញ។

សាលាឧទ្ធរណ៍ភ្នំពេញ

នៅឆ្នាំ២០១៨ និង២០១៩ សាលាឧទ្ធរណ៍ភ្នំពេញបានទទួលស្គាល់ថា មានកង្វះខាតពាក់ព័ន្ធនឹងការបិទផ្សាយកាលវិភាគសវនាការ ហើយបានប្រាប់ ម.ស.ម.ក ថា ខ្លួននឹងមានវិធានការដើម្បីកែលម្អការផ្តល់ព័ត៌មានដល់សាធារណជនអំពីការចូលស្តាប់សវនាការ។[86] តុលាការយល់ឃើញថា ការបង្ហាញកាលវិភាគសវនាការជាសាធារណៈ គឺជាបញ្ហារដ្ឋបាល ហើយមិនមែនជាលក្ខខណ្ឌដែលមានកំណត់នៅក្នុងច្បាប់ទេ ប៉ុន្តែតុលាការបានប្តេជ្ញាផ្តល់អាទិភាពចំពោះបញ្ហានេះ ហើយបានបង្កើតគេហទំព័រមួយដើម្បីបង្ហោះព័ត៌មានអំពីសំណុំរឿងនាពេលខាងមុខ ក៏ដូចជាកាលវិភាគសវនាការផងដែរ។ បច្ចុប្បន្ន ព័ត៌មានដែលផ្តល់ជូន រួមមានដូចជា កាលបរិច្ឆេទ ពេលវេលា និងទីតាំងសវនាការ លេខសំណុំរឿង បទចោទប្រកាន់ និងឈ្មោះចៅក្រម។

តួលេខទី១០៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ[87]



នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ភ្នំពេញ បានបិទផ្សាយកាលវិភាគសវនាការសម្រាប់សំណុំរឿងចំនួន ៩៣% (២២៨ ក្នុងចំណោម ២៤៥) ដែលបង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៤ ត្រឹមតែ ៨៨% ប៉ុណ្ណោះ។ ទិន្នន័យនេះ មានប្រសើរដូចនឹងឆ្នាំ២០២៣ ដែលតុលាការបានបិទផ្សាយកាលវិភាគសវនាការមានតួលេខ ៩៥,២%។ នៅឆ្នាំ២០២៥ តុលាការបានអនុវត្តល្អក្នុងការបិទផ្សាយកម្មវិធីសវនាការ ទាំងតាម

[86] នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨ និងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ក្រុមការងារគម្រោងសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការនៅឆ្នាំ២០១៦/២០១៧ និងរបាយការណ៍ឆ្នាំ២០១៧/២០១៨។

[87] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ២៤៥ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញនៅឆ្នាំ២០២៥។

អនឡាញ និងនៅលើបញ្ជរព័ត៌មាន នៅក្នុងសំណុំរឿងចំនួន ៩៤% (២១៥ ក្នុងចំណោម ២២៨) ដែលចំនួននេះជាការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៤ មានត្រឹមតែ ៦១%។

តួលេខទី១១៖ ការប្រៀបធៀបភាគរយនៃសំណុំរឿងដែលកាលវិភាគសវនាការត្រូវបានបិទផ្សាយនៅខាងក្រៅបន្ទប់សវនាការ (រហូតដល់ឆ្នាំ២០២២) និងនៅខាងក្រៅបន្ទប់សវនាការ ឬតាមអនឡាញ (ពីឆ្នាំ២០២២) នៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០២៥)[88]

សាលាឧទ្ធរណ៍បាត់ដំបង

តួលេខទី១២៖ ភាគរយនៃសំណុំរឿងមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍បាត់ដំបង[89]



នេះជាឆ្នាំទីពីរជាប់ៗគ្នា ដែលការអនុវត្តរបស់សាលាឧទ្ធរណ៍បាត់ដំបងពាក់ព័ន្ធនឹងសិទ្ធិនេះមានភាពប្រសើរឡើង ដោយបានផ្សព្វផ្សាយកាលវិភាគសវនាការតាមអនឡាញ ឬនៅលើបញ្ជរព័ត៌មានជាសាធារណៈ ១00% (៦៤ ក្នុងចំណោម ៦៤) នៃសំណុំរឿងដែលបានសង្កេត។ តួលេខនេះកើនឡើងពី ៩៣% នៅឆ្នាំ២០២៤ និង៧៥,១% នៅឆ្នាំ២០២៣ ដែលនៅពេលនោះសិទ្ធិនេះមិនត្រូវបានចាត់ថ្នាក់ថាត្រូវបានគោរពពេញលេញទេ។ នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍បាត់ដំបងមាន

[88] ទិន្នន័យនេះ គឺផ្អែកលើសំណុំរឿងសរុបចំនួន ១២៨ បានសង្កេតនៅឆ្នាំ២០១៤/២០១៥, សំណុំរឿងសរុបចំនួន ៣៤0 បានសង្កេតនៅឆ្នាំ២០១៦/២០១៧ សំណុំរឿងសរុបចំនួន ២១៣ បានសង្កេតនៅឆ្នាំ២០១៧/២០១៨ សំណុំរឿងសរុបចំនួន ២៣៩ បានសង្កេតនៅឆ្នាំ២០១៨/២០១៩ សំណុំរឿងសរុបចំនួន ២0៣ បានសង្កេតនៅឆ្នាំ២០១៩/២0២0 សំណុំរឿងសរុបចំនួន ៨៥ បានសង្កេតនៅឆ្នាំ ២0២១ សំណុំរឿងសរុបចំនួន ២៥៧ បានសង្កេតនៅឆ្នាំ២0២២ សំណុំរឿងសរុបចំនួន ៣៣៦ បានសង្កេតនៅឆ្នាំ២0២៣ សំណុំរឿងសរុបចំនួន ២៧៦ បានសង្កេតនៅឆ្នាំ២0២៤ និងសំណុំរឿងសរុបចំនួន ២៤៥ បានសង្កេតនៅឆ្នាំ២0២៥។

[89] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៦៤ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍បាត់ដំបងនៅឆ្នាំ២0២៥។

ការថយចុះបន្តិចក្នុងការអនុវត្តនៃការផ្សព្វផ្សាយកាលវិភាគសវនាការទាំងតាមអនឡាញ និងបញ្ជរព័ត៌មានមានចំនួន ៦២,៥% (៤០ ក្នុងចំណោម ៦៤ សំណុំរឿង) បើធៀបនឹងឆ្នាំ២០២៤ មានដល់ ៧០%។ ការកើនឡើងគួរឱ្យកត់សម្គាល់នៃការផ្សព្វផ្សាយកាលវិភាគសវនាការតាមអនឡាញពី ១៥% នៅឆ្នាំ២០២៤ ទៅដល់ ៥៨% នៅឆ្នាំ២០២៥។ ទោះបីជាមានការកើនឡើងកាន់តែច្រើនក្នុងការផ្សព្វផ្សាយតាមអនឡាញ ក៏នៅតែលើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយកាលវិភាគសវនាការនេះតាមបញ្ជរព័ត៌មានបន្ថែមទៀត ព្រោះការធ្វើបែបនេះកាន់តែផ្តល់ភាពងាយស្រួលក្នុងការទទួលបានព័ត៌មាន ជាពិសេស សម្រាប់ប្រជាពលរដ្ឋដែលមិនសូវមានការយល់ដឹងអំពីការប្រើអនឡាញដោយសារតែវ័យ ឬការសិក្សារបស់ពួកគាត់។

នៅក្នុងការពិគ្រោះយោបល់មុនៗជាមួយ ម.ស.ម.ក មន្ត្រីសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា សាលាឧទ្ធរណ៍បាត់ដំបងបានប្តេជ្ញាចិត្តធ្វើការបិទផ្សាយកាលវិភាគសវនាការឱ្យបានទៀងទាត់ ហើយសម្រេចបានលទ្ធផលដូចដែលបង្ហាញនៅឆ្នាំ២០២៥។[90] គួរឱ្យកត់សម្គាល់នូវភាពប្រសើរនៃការបិទផ្សាយកាលវិភាគសវនាការរបស់សាលាឧទ្ធរណ៍បាត់ដំបងដែលបានអនុវត្តល្អជាងឆ្នាំ២០២២ ដែលមានចំនួន ៩៣,៧% (១៣៤ ក្នុងចំណោម ១៤៣ សំណុំរឿង)។ ជាការលើកទឹកចិត្តចំពោះកិច្ចខិតខំប្រឹងប្រែងឱ្យមានវឌ្ឍនភាពនេះ និងជានាថាការអនុវត្តល្អក្នុងការផ្សព្វផ្សាយទាំងតាមអនឡាញ និងនៅលើបញ្ជរព័ត៌មានជាសាធារណៈនៅតែបន្ត។

សាលាឧទ្ធរណ៍ព្រះសីហនុ

នៅឆ្នាំ២០២៥ ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈដែលបានសង្កេត មិនមានសំណុំរឿងណាមួយ ដែលបានបិទផ្សាយកាលវិភាគសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ព្រះសីហនុនោះទេ។ ដោយសារហិរញ្ញវត្ថុ និងធនធានមនុស្សមានកម្រិត ដូច្នេះ ម.ស.ម.ក អាចសង្កេតសវនាការបានតែ ១៤ សំណុំរឿងប៉ុណ្ណោះ នៅសាលាឧទ្ធរណ៍ព្រះសីហនុដែលនេះជាសំណាកតិចតួចសម្រាប់ធ្វើការវិភាគ។ ទោះបីមានសំណុំរឿងដែលបានសង្កេតតិចតួចក៏ដោយ ជាលទ្ធផលមិនមានការបិទផ្សាយកាលវិភាគសវនាការជាសាធារណៈនោះទេក្នុងសំណុំរឿងទាំងនោះ ទាំងនៅលើបញ្ជរព័ត៌មាន និងអនឡាញនៅសាលាឧទ្ធរណ៍នេះ។

ការអនុវត្តនេះបង្ហាញពីការថយចុះគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៤ ការផ្សព្វផ្សាយកាលវិភាគសវនាការតាមអនឡាញ ឬនៅលើបញ្ជរព័ត៌មាន មានចំនួន ៣៦% និង៣៧% នៅឆ្នាំ២០២៣។ សាលាឧទ្ធរណ៍ព្រះសីហនុ គួរខិតខំប្រឹងប្រែងផ្សព្វផ្សាយកាលវិភាគសវនាការជាសាធារណៈ ដើម្បីសាធារណជនអាចទទួលបានព័ត៌មានទាំងនេះ។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បានអះអាងថាការបិទផ្សាយកាលវិភាគសវនាការ ដោយមានឈ្មោះជនជាប់ចោទនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមអាចប៉ះពាល់ដល់សិទ្ធិឯកជនភាពរបស់ពួកគេ ព្រោះថាពេលខ្លះ សាធារណជនមិនដឹងអំពីភាពខុសគ្នារវាងបុគ្គល

[90] ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ម.ស.ម.ក បានជួបប្រជុំពិគ្រោះយោបល់ជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ដែលប្រឈមមុខនឹងការចោទប្រកាន់ និងបុគ្គលដែលត្រូវបានផ្តន្ទាទោសឡើយ។[91]ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា ការបិទកម្មវិធីសវនាការនៅលើបញ្ជរព័ត៌មានហាក់ដូចជាមិនសូវចាំបាច់ទេ ដោយសារតែសាធារណជនកម្រនឹងមកមើលព័ត៌មាននេះ។[92]

តួលេខទី១៣៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ព្រះសីហនុ[93]



សាលាឧទ្ធរណ៍ត្បូងឃ្មុំ

គួរឱ្យកត់សម្គាល់ជាវិជ្ជមានដែលសាលាឧទ្ធរណ៍ត្បូងឃ្មុំបានរក្សាតួលេខ ១០០% របស់ខ្លួន (៩៩ ក្នុងចំណោម ៩៩) ក្នុងការបិទផ្សាយកាលវិភាគសវនាការជាសាធារណៈបីឆ្នាំជាប់ៗគ្នា។ ចំពោះការអនុវត្តល្អក្នុងការផ្សព្វផ្សាយកាលវិភាគសវនាការទាំងតាមអនឡាញ និងនៅលើបញ្ជរព័ត៌មានដោយសាលាឧទ្ធរណ៍ត្បូងឃ្មុំ មានចំនួន ៨២% (៨១ ក្នុងចំណោម ៩៩ សំណុំរឿង)។ ភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំនេះ គឺជាលទ្ធផលគួរឱ្យកត់សម្គាល់ចំពោះសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានបន្តគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដ៏សំខាន់នេះ។

តួលេខទី១៤៖ ភាគរយនៃសំណុំរឿងដែលមានបិទផ្សាយអំពីកាលវិភាគសវនាការនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ[94]

---

[91] នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[92] នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីបង្ហាញអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[93] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ១៤ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ព្រះសីហនុនៅឆ្នាំ២០២៥។

[94] ទិន្នន័យនេះផ្អែកលើសំណុំរឿងចំនួន ៩៩ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំនៅឆ្នាំ២០២៥។



៤.២ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	រដ្ឋធម្មនុញ្ញ	ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
មាត្រា ១៤ (២)	មាត្រា ៣៨	មាត្រា ៥

ការសន្មតទុកជាមុនថាគ្មានទោស គឺជាសិទ្ធិជាមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានអនុវត្តនៅអំឡុងពេលស៊ើបអង្កេតសំណុំរឿងព្រហ្មទណ្ឌ និងដំណើរការជំនុំជម្រះទាំងមូល រហូតដល់បណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ។[95] យោងតាមន័យនេះ បុគ្គលម្នាក់ត្រូវបានសន្មតទុកជាមុនថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានបង្ហាញតាមច្បាប់ និងតាមរយៈសេចក្តីសម្រេចស្ថាពរ។ ជាគោលការណ៍ បន្ទុកភស្តុតាងស្ថិតនៅលើស្មាប័នតំណាងអយ្យការ មិនមែនជាបន្ទុករបស់ជនជាប់ចោទទេ។[96] ទោះបីជាជនជាប់ចោទមិននិយាយអ្វី និងមិនបង្ហាញភស្តុតាងអ្វីក៏ដោយ ក៏ពួកគេត្រូវតែបានឱ្យរួចទោសដែរ ប្រសិនបើអយ្យការមិនបានបង្ហាញភស្តុតាងដាក់បន្ទុកចាំបាច់គ្រប់គ្រាន់សម្រាប់ការផ្តន្ទាទោសម្យ៉ាងវិញទៀត ជនជាប់ចោទមិនមែនជាអ្នកដែលត្រូវបង្ហាញភស្តុតាងដើម្បីបញ្ជាក់ថាខ្លួនគ្មានទោសនោះទេ។[97]

កត្តាមួយចំនួនអាចត្រូវបានយកមកពិចារណាក្នុងការវាយតម្លៃថា តើមានការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទដែរឬទេ។ កត្តាដែលអាចប៉ះពាល់ដល់សិទ្ធិទទួលបានការ

---

[95] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី១) ជំពូកទី៦ ទំព័រ១២៩ https://tinyurl.com/35w2rrm6; អង្គការលើកលែងទោសអន្តរជាតិ "សៀវភៅណែនាំស្តីពីការជំនុំជម្រះដោយយុត្តិធម៌" (២០១៤) ទំព័រ១២៥ ផ្នែកទី ១៥.១។

[96] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០។

[97] សម្រាប់ព័ត៌មានលម្អិត សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិនៅស្ងៀម" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/4mj9dmre

សន្មតទុកជាមុនថាគ្មានទោស គឺជាលក្ខណៈដែលបង្ហាញថាជនជាប់ចោទមានពិរុទ្ធភាពក្នុងអំឡុងពេលសវនាការ ដូចជា ការដាក់ខ្នោះជើង ខ្នោះដៃ ជាប់ទ្រុង ឬឯកសណ្ឋានពន្ធនាគារជាដើម។[98] ការអនុវត្តល្អបំផុតជាអន្តរជាតិនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌបង្ហាញថា ជនជាប់ចោទគួរមានសម្លៀកបំពាក់របស់ខ្លួន នៅពេលបង្ហាញខ្លួនចំពោះមុខតុលាការ ជាសញ្ញានៃការគោរពសេចក្តីថ្លៃថ្នូរ និងឋានៈរបស់ពួកគេក្នុងនាមជាអ្នកគ្មានទោស។[99] នៅពេលដែលជនជាប់ចោទត្រូវបានតម្រូវឱ្យស្លៀកពាក់ឯកសណ្ឋានដូចគ្នាទៅនឹងទណ្ឌិត អាចឱ្យមានលក្ខណៈបុរេនិច្ឆ័យថាពួកគេពួកគេមានពិរុទ្ធភាពរួចហើយ ដែលការធ្វើបែបនេះជះឥទ្ធិពលអវិជ្ជមានលើសេចក្តីសម្រេចរបស់ចៅក្រម និងលទ្ធផលចុងក្រោយនៃសំណុំរឿង។

វិធានរបស់អង្គការសហប្រជាជាតិឆ្នាំ២០១៥ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (“វិធាននែលសាន់ម៉ាន់ដឺឡា”) ដែលតំណាងឱ្យការអនុវត្តល្អបំផុត ត្រូវបានទទួលស្គាល់ជាអន្តរជាតិលើការប្រព្រឹត្តទៅលើជនជាប់ឃុំចែងថា ជនជាប់ឃុំដែលមិនទាន់បានជំនុំជម្រះដែលមានសេចក្តីសម្រេចស្តាពរ គួរត្រូវបានអនុញ្ញាតឱ្យស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគេនៅពេលជំនុំជម្រះ ឬប្រសិនបើពួកគេពាក់ឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវតែមានលក្ខណៈខុសពីទណ្ឌិត។[100] ដូចគ្នានេះដែរ ជនជាប់ចោទដែលត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួននៅគ្រប់ដំណាក់កាលនៃការដំណើរការនីតិវិធីព្រហ្មទណ្ឌ រហូតដល់មានការផ្តន្ទាទោសជាស្តាពរ។

នៅកម្ពុជា បញ្ហាជនជាប់ឃុំបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារ គឺជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។ ឯកសណ្ឋានដែលអ្នកជាប់ទោសត្រូវប្រើប្រាស់មានចែងនៅក្នុងនិតិវិធីពន្ធនាគារ លេខ០៥ (៤.១) “ឯកសណ្ឋានអ្នកជាប់ទោស និងបរិក្ខារក្នុងបន្ទប់ឃុំឃាំង” នៃនីតិវិធីពន្ធនាគារ ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ៖ “មន្ត្រីពន្ធនាគារដែលទទួលជនជាប់ទោស ត្រូវធានាថា នៅពេលជនជាប់ទោសត្រូវបានទទួលឱ្យចូលក្នុងពន្ធនាគារ ពួកគេត្រូវទទួលបាននូវឯកសណ្ឋាន និងបរិក្ខារក្នុងបន្ទប់ឃុំឃាំងដូចតទៅ៖ អាវពណ៌ខៀវឆ្នូតសនៅកចំនួនពីរ ខោជើងវែងពណ៌ខៀវឆ្នូតសពីចំហៀងចំនួនពីរ”។ ប្រកាសឆ្នាំ២០១៣ បានកំណត់ថា បុគ្គលដែលមិនទាន់ត្រូវតុលាការបានកាត់ទោស ឬការកាត់ទោសរបស់គេមិនទាន់ចូលជាស្តាពរ ហើយដែលអ្នកទាំងនេះត្រូវអាជ្ញាធរឃុំខ្លួនត្រូវស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។[101] ថ្វីបើបទប្បញ្ញត្តិនៃការប្រើប្រាស់ឯកសណ្ឋានខុសគ្នាសម្រាប់បុគ្គលទណ្ឌិត និងបុគ្គលដែលការកាត់ទោសរបស់

---

[98] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣០, ECtHR, Samoila និង Cionca ទល់នឹង Romania (ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨) ពាក្យស្នើសុំ លេខ ៣៣០៦៥/០៣, វាក្យខណ្ឌ ៩៩-១០១, https://tinyurl.com/yaebnffc

[99] ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក៖ *ឯកសណ្ឋានជនជាប់ឃុំ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស* (ឆ្នាំ២០១៧), https://tinyurl.com/FTR-Prison-Uniforms-2017

[100] មហាសន្និបាតអង្គការសហប្រជាជាតិ វិធានបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ សេចក្តីសម្រេចលេខ ៧០/១៧៥ (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥) វិធានលេខ ១៩៖ សម្លៀកបំពាក់ និងការដេក https://tinyurl.com/3hrbhupp

[101] កាសែតភ្នំពេញប៉ុស្តិ៍ *ជនសង្ស័យស្លៀកពាក់ពណ៌ទឹកក្រូចចាស់* ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។ https://web.archive.org/web/20131018080921/https://www.phnompenhpost.com/national/suspects-wear-saffron

គេមិនទាន់ចូលជាស្ថាពរ មានភាពប្រសើរឡើងក្តី ដើម្បីធានាថាសិទ្ធិទទួលការសន្មតជាមុនថាគ្មានទោសត្រូវបានគោរពពេញលេញ ជនជាប់ចោទទាំងអស់ដែលការកាត់ទោសរបស់គេមិនទាន់ចូលជាស្ថាពរ អាចស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនចូលរួមក្នុងដំណើរការសវនាការបាន។[102] ការកាត់ទោសលើជនជាប់ចោទដែលសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពរ ហើយបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាទណ្ឌិតគឺវាមិនស្របនឹងរដ្ឋធម្មនុញ្ញ ប្រកាសឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងនីតិវិធីពន្ធនាគារលេខ៥។ ការអនុវត្តបែបនេះក៏មិនអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលធានាដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងបទដ្ឋានអន្តរជាតិ ដូចជា វិធាននៃលសាន់ម៉ាន់ដឹឡា ជាពិសេស វិធានលេខ១៩ ដែលចែងអំពីសម្លៀកបំពាក់ និងការដេក។

ទម្រង់ខ្លះដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស:



- ជនជាប់ចោទមិនគួរត្រូវបានជាប់ខ្នោះដៃពេលសវនាការ
- ប្រាប់អំពីសិទ្ធិនៅស្ងៀម
- ជនជាប់ចោទត្រូវស្លៀកពាក់ឯកសណ្ឋានផ្ទាល់ខ្លួន
- ចៅក្រមមិនត្រូវធ្វើបុរេនិច្ឆ័យ

ធាតុផ្សេងទៀតនៃសិទ្ធិនេះរួមមាន ថាតើមានការអានប្រាប់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគេដែរឬទេ មានការទាញសេចក្តីសន្និដ្ឋានថាមានពិរុទ្ធពីការនៅស្ងៀមរបស់ជនជាប់ចោទដែរឬទេ និងមានសេចក្តីថ្លែងអំពីពិរុទ្ធភាពណាមួយរបស់ចៅក្រមមុនពេលចេញសេចក្តីសម្រេច/សាលដីកាដែរឬទេ។ សម្រាប់សិទ្ធិនៅស្ងៀម ច្បាប់កម្ពុជាបានដាក់បន្ទុកនេះទៅលើចៅក្រមស៊ើបសួរអំឡុងពេលជួនដំណឹងអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យ។[103] ទោះជាយ៉ាងណាក៏ដោយ ម.ស.ម.ក លើកទឹកចិត្តឱ្យចៅក្រមសាលាឧទ្ធរណ៍អនុវត្តនូវការប្រតិបត្តិល្អជាប្រចាំ ដោយមិនត្រឹមតែអានប្រាប់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់អំពីសិទ្ធិនោះដល់ជនជាប់ចោទផងដែរ ដើម្បីឱ្យពួកគេអាចធ្វើការសម្រេចចិត្តបានល្អិតល្អន់អំពីការនិយាយនៅក្នុងសវនាការ។

កត្តាទាំងបួនដែលរួមមាន ការដាក់ខ្នោះដៃ ឱ្យប្រើប្រាស់ឯកសណ្ឋានពន្ធនាគារ ការខកខានអានប្រាប់និងពន្យល់អំពីសិទ្ធិនៅស្ងៀម និងបុរេនិច្ឆ័យថាមានពិរុទ្ធភាពណាមួយដោយចៅក្រម ត្រូវបានយកមកពិចារណា

---

[102] ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ ម.ស.ម.ក៖ *ឯកសណ្ឋានជនជាប់ទោស ខែធ្នូ ឆ្នាំ ២០២៤* https://www.cchrcambodia.org/en/publications/factsheets/newsletter-on-right-to-presumption-of-innocence-uniform-for-prisoners

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៣។

នៅក្នុងសំណុំរឿងដែលបានសង្កេតនៅក្នុងតុលាការនីមួយៗ ក្នុងចំណោមតុលាការគោលដៅទាំងបួន ដើម្បីវាយតម្លៃអំពីការគោរពសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។

មានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ ចំពោះតុលាការគោលដៅចំនួនបីក្នុងចំណោមតុលាការគោលដៅទាំងបួនបានគោរពសិទ្ធិនេះនៅឆ្នាំ២០២៥។ នៅឆ្នាំ២០២៤ មានតុលាការចំនួនពីរដែលបានអនុវត្តល្អប្រសើរបែបនេះ ក្នុងនោះមាន សាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍ព្រះសីហនុ។ នេះគឺជាវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅឆ្នាំ២០២៣ មានតែសាលាឧទ្ធរណ៍ព្រះសីហនុតែមួយប៉ុណ្ណោះបានគោរពសិទ្ធិនេះ (ហើយបើធៀបនឹងឆ្នាំ ២០២២ ពុំមានតុលាការណាមួយបានគោរពសិទ្ធិនេះទេ។

សរុបជារួម ពុំមានករណីថា ជនជាប់ចោទត្រូវបានដាក់ខ្នោះដៃនៅក្នុងអំឡុងពេលសវនាការឡើយ។ ហើយក៏ពុំមានករណីចៅក្រមបានទាញសេចក្តីសន្និដ្ឋានថា មានពិរុទ្ធដោយសារតែជនជាប់ចោទរក្សាសិទ្ធិនៅស្ងៀម ឬធ្វើសេចក្តីថ្លែងអំពីពិរុទ្ធភាពណាមួយរបស់ជនជាប់ចោទមុនពេលចេញសេចក្តីសម្រេច/សាលដីកានោះទេ។ នៅក្នុងតុលាការគោលដៅទាំងបួន មានចំនួន ៣៣% (១៣៤ ក្នុងចំណោម ៤០២ សំណុំរឿង) ចៅក្រមមិនបានអានប្រាប់ ឬពន្យល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀម។ ការប្រតិបត្តិបែបនេះមានការកើនឡើង បើធៀបនឹងឆ្នាំ២០២៤មានតែ ២៥% ប៉ុណ្ណោះ។

តារាងទី ១៥៖ ចំនួនជនជាប់ចោទដែលចៅក្រមបានអានប្រាប់ និងពន្យល់ អំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ[104]



ពាក់ព័ន្ធនឹងឯកសណ្ឋានពន្ធនាគារ ម.ស.ម.ក ស្នើឱ្យតុលាការទាំងអស់ប្រកាន់យកការអនុវត្តល្អបំផុតដែលអនុញ្ញាត និងសម្របសម្រួលឱ្យជនជាប់ចោទប្រើប្រាស់សម្លៀកបំពាក់ផ្ទាល់ខ្លួននៅក្នុងសវនាការ។ ការស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន មិនត្រឹមតែជាកត្តាសំខាន់ក្នុងការធានាសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរបស់ពួកគេប៉ុណ្ណោះទេ ថែមទាំងផ្តល់ឱ្យជនចាប់ចោទទទួលបាននូវសេចក្តីថ្លៃថ្នូរនៅពេលមានវត្តមានចំពោះមុខតុលាការដើម្បីការពារខ្លួនផងដែរ ដោយសារឯកសណ្ឋានពន្ធនាគារអាចមានឥទ្ធិពលជាអវិជ្ជមាន ដូចជា ការទទួលបានមាក់ងាយទាំងដឹងខ្លួន ឬមិនដឹងខ្លួន។ ម.ស.ម.ក លើកទឹកចិត្តតុលាការទាំងបួនខិតខំប្រឹងប្រែងលើកកម្ពស់សិទ្ធិនេះ និងអនុញ្ញាតឱ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួន មានវត្តមានក្នុងសវនាការដោយស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួន។

[104] ទិន្នន័យនេះ គឺផ្អែកលើសំណុំរឿងចំនួន ៤០២ (ក្នុងចំណោម ៤២២) ដែលជនជាប់ចោទមានវត្តមានពេលសវនាការ។

ដើម្បីកំណត់ថា តើសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសត្រូវបានគោរពដោយតុលាការគោលដៅដែរឬទេ ប្រសិនបើជនជាប់ចោទស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធនាគារចូលរួមក្នុងសវនាការ ចំពោះករណីនេះ សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសមានភាពប្រសើរជាងជនជាប់ចោទស្លៀកឯកសណ្ឋានពណ៌ខៀវ(ទណ្ឌិត)។ នៅឆ្នាំ២០២៥ មានចំនួន ១២% (៦១ ក្នុងចំណោម ៤៩៦ នាក់) នៃជនជាប់ចោទដែលត្រូវបានឃុំខ្លួន ស្លៀកឯកសណ្ឋានពន្ធនាគារពណ៌ខៀវនៅសាលាឧទ្ធរណ៍ទាំងបួន។ នេះមានការថយចុះគួរឱ្យកត់សម្គាល់ជាងពាក់កណ្តាលបើធៀបនឹងឆ្នាំ២០២៤ មានដល់ចំនួន ២៩% នៃជនជាប់ចោទដែលត្រូវបានឃុំខ្លួនស្លៀកឯកសណ្ឋានពន្ធនាគារពណ៌ខៀវ និងបានថយចុះបីដងបើធៀបនឹងឆ្នាំ២០២២ មានចំនួនដល់ ៣៦,៥%។ ជនជាប់ចោទដែលជាប់ឃុំក្រៅពីនេះស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ (៤៣៥ ក្នុងចំណោម ៤៩៦ នាក់) គ្មានជនជាប់ចោទណាម្នាក់ស្លៀកពាក់ឯកសណ្ឋានផ្ទាល់ខ្លួនរបស់ពួកគេ ឬស៊ីវិលឡើយ។ ភាពប្រសើរឡើងបែបនេះ ត្រូវបានលើកទឹកចិត្ត និងគួរតែត្រូវបានអនុវត្តបន្តទៅមុខទៀត។ យ៉ាងណាមិញ គួរតែអនុញ្ញាត និងឱ្យជនជាប់ចោទដែលកំពុងជាប់ឃុំនេះ អាចស្លៀកពាក់ស៊ីវិល ឬផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធានាថាសិទ្ធិនេះត្រូវបានគោរពពេញលេញស្របតាមការអនុវត្តល្អបំផុត។

តារាងលេខទី១៦៖ ការគោរពសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសដោយតុលាការគោលដៅ[105]

	សាលាឧទ្ធរណ៍ភ្នំពេញ			សាលាឧទ្ធរណ៍បាត់ដំបង			សាលាឧទ្ធរណ៍ត្បូងឃ្មុំ			សាលាឧទ្ធរណ៍ព្រះសីហនុ		
	មាន	គ្មាន	មិនពាក់ព័ន្ធ	មាន	គ្មាន	មិនពាក់ព័ន្ធ	មាន	គ្មាន	មិនពាក់ព័ន្ធ	មាន	គ្មាន	មិនពាក់ព័ន្ធ
តើជនជាប់ចោទត្រូវបានដាក់ខ្នោះនៅអំឡុងពេលសវនាការដែរឬទេ?	០	២៩៣	៤៤	០	៧២	១០	០	១១២	២០	០	១៩	៣
តើចៅក្រមបានធ្វើសេចក្តីថ្លែងណាមួយអំពីពិរុទ្ធភាពរបស់ជនជាប់ចោទមុន	០	៣៣៧	០	០	៨២	០	០	១៣២	០	០	២២	០

[105] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទសរុប (៥៧៣ នាក់) ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេត។ មិនពាក់ព័ន្ធ មានន័យថា ជនជាប់ចោទអវត្តមាន ឬមិនជាប់ពន្ធនាគារ។

ពេលចេញសាលដីកាដែរឬទេ ?												
តើមានអ្វីមួយដែលបង្ហាញថា ចៅក្រមទាញការសន្និដ្ឋានអំពីពិរុទ្ធភាពដោយផ្អែកលើការនៅស្ងៀមរបស់ជនជាប់ចោទឬដែរឬទេ ?	០	៣២១	១៦	០	៧៣	៩	០	១២៤	៨	០	២០	២

សាលាឧទ្ធរណ៍ភ្នំពេញ

មានសំណុំរឿងចំនួន ២៩% បានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញដែលចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគាត់។ ចំណុចនេះ បង្ហាញពីការថយចុះធៀបនឹងឆ្នាំមុនដែលសាលាឧទ្ធរណ៍ភ្នំពេញបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទ មានចំនួន ៤១% នៃសំណុំរឿងសរុប។ ចំណែកឯតួលេខនៃសំណុំរឿងដែលចៅក្រមមិនបានបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ខ្លួន មានការកើនឡើងពី ២៧% នៅឆ្នាំ២០២៤ ដល់ ៣៥% នៅឆ្នាំ២០២៥ (៨៣ ក្នុងចំណោម ២៣៦ សំណុំរឿង)។ ទោះបីជាមានវឌ្ឍនភាពនៅឆ្នាំ២០២៤ ក្តី តែលទ្ធផលឆ្នាំ២០២៥ ហាក់ដូចមានភាពខុសគ្នាជាមួយនឹងការលើកឡើង នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ថានឹងណែនាំឱ្យចៅក្រមអនុវត្តជាប្រព័ន្ធក្នុងការអានប្រាប់អំពីសិទ្ធិនេះដល់ជនជាប់ចោទ។[106]

[106] នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

តួលេខទី១៧៖ ការវិវត្តនៃភាគរយសំណុំរឿងពាក់ព័ន្ធដែលចៅក្រមអានប្រាប់ និងពន្យល់ជនជាប់ចោទពីសិទ្ធិនៅស្ងៀមរបស់ខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២៥)[107]



នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ភ្នំពេញមានការថយចុះបន្តិចលើការអនុវត្តរបស់ខ្លួនទាក់ទងនឹងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស។ ជនជាប់ចោទដែលជាប់ឃុំស្ងៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់មានចំនួន ៩៣% (២៧៣ ក្នុងចំណោម ២៩៣ សំណុំរឿង) មានថយចុះបើធៀបនឹងឆ្នាំ២០២៤ មានដល់ ៩៦%។ ទោះជាយ៉ាងណា នេះជាតួលេខខ្ពស់ក្នុងការធានាដល់ជនជាប់ចោទដែលជាប់ឃុំមិនបង្ហាញខ្លួនឯកសណ្ឋានពន្ធនាគារពណ៌ខៀវ (ជាទណ្ឌិត)។ ក្រៅពីនេះ មានជនជាប់ចោទចំនួន ២០ នាក់បានស្ងៀកឯកសណ្ឋានពន្ធនាគារពណ៌ខៀវ នេះបង្ហាញពីចំនួនតិចតួចដែលអាចឆ្លុះបញ្ចាំងពីភាពប្រសើរ និងការកិច្ចខិតខំប្រឹងប្រែងរបស់តុលាការ តែយ៉ាងណាក្តី សិទ្ធិរបស់ជនជាប់ចោទដែលទទួលបានការសន្មតជាមុនថាគ្មានទោសរបស់ពួកគេត្រូវរងផលប៉ះពាល់។

តួលេខទី១៨៖ ភាគរយនៃជនជាប់ចោទដែលបានបង្ហាញនៅសាលាឧទ្ធរណ៍ភ្នំពេញដោយឯកសណ្ឋានពន្ធនាគារពណ៌ខៀវ (ឆ្នាំ២០២១-២០២៥)[108]

---

[107] ទិន្នន័យដែលបង្ហាញក្នុងតារាងនេះផ្អែកលើចំនួនសំណុំរឿងដែលជនជាប់ចោទបានចូលរួមសវនាការដែលត្រូវបានសង្កេតក្នុងអំឡុងពេលរបាយការណ៍នីមួយៗ។

[108] ទិន្នន័យបង្ហាញនៅក្នុងតារាងនេះ ផ្អែកលើចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួន និងបានចូលរួមសវនាការដែលបានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញអំឡុងពេលធ្វើរបាយការណ៍នីមួយៗ។



សាលាឧទ្ធរណ៍បាត់ដំបង

នៅឆ្នាំ២០២៥ ចៅក្រមបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ជនជាប់ចោទចំនួន ៤៩% (២៩ ក្នុងចំណោម ៥៩ សំណុំរឿង) ដែលសង្កេត។ តួលេខនេះបង្ហាញអំពីការថយចុះពីមួយឆ្នាំទៅមួយឆ្នាំរបស់សាលាឧទ្ធរណ៍បាត់ដំបងពាក់ព័ន្ធនឹងសិទ្ធិនេះ បើធៀបនឹងឆ្នាំ២០២៤ មានដល់ ៥៩% និងឆ្នាំ២០២៣ មានដល់ចំនួន ៧០% ដែលកាលនោះសាលាឧទ្ធរណ៍បាត់ដំបងទទួលបានភាគរយខ្ពស់ជាងគេក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន។ នៅឆ្នាំ២០២៥ មានចំនួន ២២% នៃសំណុំរឿងដែលជនជាប់ចោទមិនទទួលបានការអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមរបស់ពួកគាត់គេ។

តួលេខទី១៩៖ សំលៀកបំពាក់ជនជាប់ឃុំដែលបង្ហាញខ្លួនក្នុងសវនាការសាលាឧទ្ធរណ៍បាត់ដំបង[109]

ពាក់ព័ន្ធនឹងឯកសណ្ឋានពន្ធនាគារ សាលាឧទ្ធរណ៍បាត់ដំបងបានអនុវត្តល្អប្រសើរជាងឆ្នាំ២០២៤ ប៉ុន្តែការអនុវត្តនេះ នៅមិនទាន់បានជានាក្នុងការកម្ចស់សិទ្ធិនៅឡើយ។ នៅឆ្នាំ២០២៥ ជនជាប់ចោទត្រូវបានឃុំខ្លួនហើយមានវត្តមាននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពណ៌ខៀវ ចំនួន ៤៦% (៣៣ ក្នុងចំណោម ៧២ ជនជាប់ចោទ) ដែលថយចុះគួរឱ្យកត់សម្គាល់ពី ៥៨% នៅឆ្នាំ២០២៤ និង៦៥,១% នៅឆ្នាំ២០២៣ នេះបង្ហាញពីវឌ្ឍនភាពជាបន្តបន្ទាប់ ។



ជាលទ្ធផល សិទ្ធិនេះមិនទាន់អាចចាត់ថ្នាក់ថាត្រូវបានគោរពពេញលេញនៅឡើយ ក្នុងរយៈពេលច្រើនឆ្នាំបន្តបន្ទាប់មកនេះ។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងតុលាការបានអះអាងថា ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌

[109]ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលជាបឃុំដែលបានចូលរួមក្នុងដំណើរការសវនាការសាលាឧទ្ធរណ៍បាត់ដំបងនៅឆ្នាំ ២០២៥ (៧២ នាក់)

ខៀវនៅពេលសវនាការ មិនមែនជាទំនួលខុសត្រូវរបស់តុលាការទេ ប៉ុន្តែវាស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រសួងមហាផ្ទៃ។[110] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា ករណីមានទិន្នន័យថាជនជាប់ចោទស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវ (សម្រាប់ទណ្ឌិត) តុលាការនឹងជជែកជាមួយខាងពន្ធនាគារបន្ថែមទៀត ហើយករណីនេះអាចនឹងមិនមានបន្តទៀតនោះទេ។[111] ដូច្នេះ តុលាការគួរខិតខំប្រឹងប្រែងបន្ថែមទៀត និងធ្វើការជាមួយក្រសួងមហាផ្ទៃ ដើម្បីដោះស្រាយបញ្ហានេះ។

សាលាឧទ្ធរណ៍ព្រះសីហនុ

នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ព្រះសីហនុបានបង្ហាញអំពីលទ្ធផលពាក់ព័ន្ធនឹងការអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមមានចំនួនតិចតួចប៉ុណ្ណោះ គឺ ១៧% នៃសំណុំរឿង (២ ក្នុងចំណោម ១២)។ តួលេខនេះមានការថយចុះរួចទៅហើយនៅឆ្នាំ២០២៤ ចំនួន ៩១% នៃសំណុំរឿង ដែលចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមនេះ ហើយនៅឆ្នាំ២០២៣ មានចំនួន ៨៧%។ នៅពេលដែលជនជាប់ចោទមិនទទួលបានអានប្រាប់ និងពន្យល់ឱ្យដឹងអំពីសិទ្ធិនៅស្ងៀមជាសារវន្តរបស់ខ្លួន ការណ៍នេះអាចមានហានិភ័យក្នុងការធ្វើឱ្យជនជាប់ចោទឆ្លើយដាក់បន្ទុកលើខ្លួនឯង។ ដូច្នេះជាការសំខាន់ណាស់ដែលតុលាការគួរមានវិធានការបន្ថែម ដើម្បីដោះស្រាយបញ្ហានេះ។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានអះអាងថា ដើម្បីឱ្យតុលាការអាចឈានដល់សេចក្តីសម្រេច តុលាការត្រូវតែទទួលបានព័ត៌មានពីជនជាប់ចោទ ដោយសួរនាំថា តើការវិនិច្ឆ័យលើសំណុំរឿងអាចដំណើរការទៅដោយរបៀបណា ប្រសិនបើមិនមានព័ត៌មានពីជនជាប់ចោទ។[112] គួរឭកផងដែរថា ប្រសិនបើជនជាប់ចោទជ្រើសរើសប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ខ្លួន នោះមិនអាចសន្និដ្ឋានពីការនៅស្ងៀមរបស់គាត់ថា គាត់មានពិរុទ្ធភាពនោះបានឡើយ។ គ្មានជនណាម្នាក់ត្រូវរងការបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាពឡើយ។[113]

បើទោះបីជាមានតួលេខពាក់ព័ន្ធនឹងសិទ្ធិនៅស្ងៀមបែបនេះក្តី គួរមានការលើកទឹកចិត្តដែលតុលាការបានធានានូវការស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ដល់ជនជាប់ចោទ ដែលជាប់ឃុំដែលបង្ហាញខ្លួនក្នុងសវនាការមានចំនួន ១០០% (១៩ នាក់ ក្នុងចំណោម ១៩ នាក់)។ តួលេខនេះ គឺជាអត្រាដ៏ខ្ពស់បំផុតដែលសាលាឧទ្ធរណ៍ព្រះសីហនុសម្រេចបាន គិតតាំងពីគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.

---

[110] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[111] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[112] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍សីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍សីហនុ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[113] ក.អ.ស.ព.ន មាត្រា ១៤ (3)(ឆ)

ស.ម.ក បានសង្កេតសវនាការនៅតុលាការនេះ។ នៅឆ្នាំ២០២៤ ជនជាប់ចោទដែលត្រូវបានឃុំខ្លួនបានស្នើកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ចំនួន ៩០% ហើយនៅឆ្នាំ២០២៣ មានចំនួន ៩៨%។ នៅក្នុងកិច្ចប្រជុំខែមីនា ឆ្នាំ២០២៣ ជាមួយតំណាងសាលាឧទ្ធរណ៍ព្រះសីហនុបានលើកឡើងថា តុលាការបានណែនាំឱ្យមន្ត្រីពន្ធនាគារសម្រួលធ្វើយ៉ាងណាឱ្យជនជាប់ចោទបង្ហាញខ្លួននៅពេលសវនាការក្នុងសម្លៀកបំពាក់ស៊ីវិល។ ដូច្នោះ តុលាការគួរបន្តការប្រតិបត្តិល្អនេះ និងធានាឱ្យបាននូវការប្រាស្រ័យទាក់ទងជាមួយមន្ត្រីពន្ធនាគារ ដើម្បីសម្រេចកិច្ចការនេះ។ ទន្ទឹមគ្នានេះ លើកទឹកចិត្តដល់តុលាការត្រូវអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគាត់ ដើម្បីធានាថាសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសត្រូវបានគោរពពេញលេញ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍ត្បូងឃ្មុំបានអនុវត្តល្អប្រសើរច្រើនពាក់ព័ន្ធនឹងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស ដែលជាលើកដំបូង ចាប់តាំងពីសង្កេតសវនាការនៅតុលាការនេះពីឆ្នាំ២០២២។ ចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀមរបស់ពួកគាត់ មានចំនួន ៧១% (៦៧ ក្នុងចំណោម ៩៥ សំណុំរឿង) មានការការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៤ មានត្រឹម ៤៨% និងកើនឡើងទ្វេដង បើធៀបនឹងឆ្នាំ២០២៣ មានតែចំនួន ៣៥% ។

វឌ្ឍនភាពគួរឱ្យកត់សម្គាល់នេះ ក៏បង្ហាញឱ្យឃើញយ៉ាងច្បាស់ផងដែរពាក់ព័ន្ធនឹងឯកសណ្ឋានពន្ធនាគារ ដោយក្នុងនោះជនជាប់ចោទដែលជាប់ឃុំបានស្លៀកឯកសណ្ឋានពណ៌ទឹកក្រូចចាស់ក្នុងចំនួន ៩៣% ដែលនេះជាតួលេខខ្ពស់ជាងមុនពីរដងបើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៤៥%ប៉ុណ្ណោះ។ តុលាការគួរបន្តការអនុវត្តបែបនេះ និងពង្រឹងបន្ថែមទៅលើវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់នេះពាក់ព័ន្ធនឹងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស ដើម្បីធានាថាសិទ្ធិនេះត្រូវបានគោរពពេញលេញ និងអនុវត្តសម្រាប់ជនជាប់ចោទទាំងអស់ដែលនឹងបង្ហាញខ្លួននៅចំពោះមុខតុលាការ។ តំណាងសាលាឧទ្ធរណ៍បានបញ្ជាក់ថា ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការស្លៀកឯកសណ្ឋានទណ្ឌិតមិនមែនជាទំនួលខុសត្រូវរបស់តុលាការទេ។ ផ្ទុយទៅវិញ បញ្ហានេះស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រសួងមហាផ្ទៃ។[114]ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានអះអាងថា ការរៀបចំសំលៀកបំពាក់របស់ជនជាប់ចោទ គឺខាងពន្ធនាគារជាអ្នករៀបចំ តុលាការមិនបានចាត់ចែងលើការងារនេះទេ ទោះបីយ៉ាងណា តុលាការនឹងប្រាប់ដល់ពន្ធនាគារមិនត្រូវនាំជនជាប់ចោទមកសវនាការជាមួយនឹងឯកសណ្ឋានពន្ធនាគារពណ៌ខៀវ(សម្រាប់ទណ្ឌិត)នោះទេ។ លើសពីនេះ តុលាការបញ្ជាក់ថា សាលាឧទ្ធរណ៍ត្បូងឃ្មុំនឹងផ្ញើលិខិតទៅពន្ធនាគារ ដើម្បីជម្រាបដល់ពន្ធនាគារឱ្យនាំជនជាប់

[114] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន ។

ចោទមកសវនាការនៅសាលាឧទ្ធរណ៍ត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូចចាស់ ហើយត្រូវជៀសវាងស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវ។[115]

តួរលេខទី២០: សំលៀកបំពាក់ជនជាប់ឃុំដែលបង្ហាញខ្លួនក្នុងសវនាការសាលាឧទ្ធរណ៍ត្បូងឃ្មុំ[116]



៤.៣ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង

ច្បាប់អន្តរជាតិ			ច្បាប់កម្ពុជា		
ស.ស.ស.ម	**ក.អ.ស.ព.ន**	**អនុសញ្ញាប្រឆាំងទារុណកម្ម**	**រដ្ឋធម្មនុញ្ញ**	**ក្រមនីតិវិធីព្រហ្មទណ្ឌ**	**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
មាត្រា ៥	មាត្រា ១៤ (៣)(ឆ) និង មាត្រា ៧	មាត្រា ១៥	មាត្រា ៣៨	មាត្រា ១៤៥ និងមាត្រា ៣២១	មាត្រា ៥ និង មាត្រា ៦

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដែលត្រូវបានធានាដោយមាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន មានសមាសធាតុមួយចំនួន។[117] ទីមួយ មាត្រានេះ មានន័យថា គ្មានការបង្ខិតបង្ខំទាំងផ្លូវកាយ ឬផ្លូវចិត្តដោយផ្ទាល់ ឬដោយប្រយោលដើម្បីបង្ខំជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទក្នុងសំណុំរឿងព្រហ្មទណ្ឌឱ្យផ្តល់កស្តុតាងប្រឆាំងនឹងខ្លួនឯងឡើយ។[118] ទីពីរ មាត្រានេះ មានន័យថា

---

[115] នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[116] ទិន្នន័យនេះផ្អែកលើចំនួនជនជាប់ចោទដែលជាប់ឃុំដែលបានចូលរួមក្នុងដំណើរការសវនាការសាលាឧទ្ធរណ៍ត្បូងឃ្មុំនៅឆ្នាំ២០២៥ (១១២នាក់)

[117] សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/8jy3ynnj

[118] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៩១២/២០០០, *Deolall* ទល់នឹងប្រទេសហ្គីយ៉ាន (ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤) CCPR/C/៨២/D/៩១២/២០០ វាក្យខណ្ឌ ៥.១,

បុគ្គលទាំងនេះ មិនអាចត្រូវបានបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯងតាមរយៈការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ហើយមិនត្រូវផ្តល់កស្តុតាងដែលអាចប្រើប្រាស់ប្រឆាំងនឹងខ្លួនឯងបានឡើយ[119] ប្រសិនបើជនណាម្នាក់បដិសេធក្នុងការផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ឬរក្សាសិទ្ធិនៅស្ងៀម សេចក្តីសន្និដ្ឋានអវិជ្ជមានណាមួយដែលធ្វើឡើងដោយចៅក្រមចេញពីស្ថានភាពនេះ ត្រូវបានហាមឃាត់។[120] ការប្រើប្រាស់សិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទអាចមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសនោះទេ ប៉ុន្តែព្រះរាជអាជ្ញាអាចត្រូវបានយកមកពិចារណានៅពេលវាយតម្លៃកស្តុតាង។[121] ក្នុងករណីសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ ច្បាប់សិទ្ធិមនុស្សអន្តរជាតិគឺទូទៅចែងថាកុមារទំនាស់នឹងច្បាប់មិនត្រូវបានបង្ខិតបង្ខំ "ឱ្យផ្តល់សក្ខីកម្ម" ឡើយ។[122]

ជាតុផ្សំសំខាន់ផ្សេងទៀតនៃសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងគឺជាការហាមឃាត់ដាច់ខាតចំពោះការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួនឯង ឬដាក់ទណ្ឌកម្មឯទៀតដែលមានលក្ខណៈយោរយៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប។ សិទ្ធិនេះ មានចែងនៅក្នុងមាត្រា ៧ នៃ ក.អ.ស.ព.ន មាត្រា ៥ នៃ ស.ស.ស.ម និងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្មរបស់អង្គការសហប្រជាជាតិដែលកម្ពុជាបានធ្វើសច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ការហាមឃាត់ការធ្វើទារុណកម្មត្រូវបានចាត់ទុកថាជា "បទដ្ឋានដាច់ខាត" នៅក្នុងច្បាប់អន្តរជាតិ ឬបទដ្ឋានជូស ខូហ្សិន (jus cogens) ដែលមានន័យថា មិនមានកាលៈទេសៈណាមួយ សិទ្ធិនេះមិនត្រូវបានដកហូត មិនថានៅក្នុងបរិបទណាក៏ដោយ បដិប្បញ្ញត្តិគឺមិនត្រូវបានអនុញ្ញាតឡើយ មិនថាក្នុងគ្រាមានជម្លោះ ឬក្នុងគោលបំណងរក្សាសន្តិសុខជាតិ ហើយមិនថាបុគ្គលនោះស្ថិតក្នុងឋានៈជាឧក្រិដ្ឋជន ឬសង្ស័យជាភេរវកររនោះទេ គ្មានកាលៈទេសៈណាដែលការធ្វើទារុណកម្ម និងអំពើទុច្ចរិតត្រូវបានផ្តល់ភាពត្រឹមត្រូវឡើយ។ លើសពីនេះ សេចក្តីថ្លែង ឬកស្តុតាងណាមួយដែលទទួលបានតាមរយៈការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើទុក្ខទោសផ្សេងទៀត ត្រូវតែបដិសេធចោល។[123] ផ្ទុយទៅវិញ នេះជាកស្តុតាងដែលអាចប្រើជាមូលដ្ឋាន ដើម្បីបញ្ជាក់ថាមានអំពើបង្ខិតបង្ខំធ្វើទារុណកម្ម ឬធ្វើទុក្ខទោសផ្សេងៗ។[124]

---

https://tinyurl.com/9ch8r85e គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ១២៦៣/២០០៤ និង ១២៦៤/២០០៤, *Khuseynova* និង *Butaeva* ទល់នឹងប្រទេសតាហ្ស៊ីគីស្ថាន (ថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨) CCPR/C/៩៤/D/១២៦៣–១២៦៤/២០០៤ វាក្យខណ្ឌ ៨.៣, https://tinyurl.com/3768t8cd, អ.វ.ត.ក, កាំង ហ្គេកអ៊ាវ ហៅ ឌុច (សំណុំរឿងលេខ ០០១) អង្គជំនុំជម្រះសាលាដំបូង (ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២) វាក្យខណ្ឌ ៣៦០។

[119] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឆ), អ.ស.ក មាត្រា ៤០(២)(ខ)(iv)

[120] *ECtHR*, Condron និងចក្រភពអង់គ្លេស (ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០០) ពាក្យស្នើសុំលេខ ៣៥៧១៨/៩៧ វាក្យខណ្ឌ ៥៦ https://tinyurl.com/yc4tphd8;

ECtHR, *Beckles* និងចក្រភពអង់គ្លេស (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២) ពាក្យស្នើសុំលេខ ៤៤៦៥២/៩៨ វាក្យខណ្ឌ ៥៨ https://tinyurl.com/3bw72a74

[121] ដូចខាងលើ

[122] អ.ស.ក មាត្រា ៤០(២)(ខ)(iv)

[123] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤១

[124] ដូចខាងលើ

ដូចដែលបានកំណត់ក្នុងបទដ្ឋាន និងការអនុវត្តសិទ្ធិមនុស្សអន្តរជាតិ ក្នុងការទទួលបានមេធាវីភ្លាមៗ បន្ទាប់ពីបុគ្គលម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់ពួកគេ គឺជាការការពារជាមូលដ្ឋានមួយប្រឆាំងនឹងការប្រើប្រាស់ការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬការធ្វើទុក្ខទោសលើបុគ្គលដែលត្រូវបានឃាត់ ឬឃុំខ្លួន។[125] យោងតាមច្បាប់កម្ពុជា ជាពិសេស មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "បន្ទាប់ផុតរយៈពេលម្តែបួនម៉ោងនៃការឃាត់ខ្លួននៅដំណាក់កាលនគរបាល អ្នកជាប់ឃុំអាចស្នើសុំសន្ទនាជាមួយមេធាវី ឬអ្នកផ្សេងទៀតដែលខ្លួនចង់ជួបបាន"។ ដូច្នេះ បញ្ញត្តិនេះមិនស្របនឹងកាតព្វកិច្ចរបស់កម្ពុជាចំពោះច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ ដោយសារវាធ្វើឱ្យបុគ្គលម្នាក់ៗប្រឈមនឹងហានិភ័យនៃការបង្ខិតបង្ខំ ការធ្វើទារុណកម្ម និង/ឬការធ្វើទុក្ខទោស ដោយសារតែអំឡុងពេលឃាត់ខ្លួន ២៤ម៉ោងដំបូងនេះ គឺពិតជាសារៈសំខាន់បំផុតសម្រាប់ការទប់ស្កាត់ពីការធ្វើទារុណកម្ម ដោយហេតុថា នេះគឺជាពេលដែលបុគ្គលនោះស្ថិតក្នុងភាពងាយរងគ្រោះបំផុត។[126] ដូចដែលអនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិដ៏ឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាបបានបញ្ជាក់ថា "ការធ្វើទារុណកម្ម និងការធ្វើទុក្ខទោសនៅកន្លែងឃុំឃាំងមិនមែនកើតឡើងតែក្នុងស្ថានភាពបែបនេះទេ តែជាងនេះទៅទៀត គឺដោយសារការខ្វះចន្លោះនូវបទប្បញ្ញត្តិ និងភាពអសកម្មរបស់តុលាការដែលបង្កើតឱ្យមានការអនុវត្តជាក់ស្តែងបែបនេះ"។[127] អនុគណៈកម្មាធិការបានផ្តល់អនុសាសន៍ជូនថា

---

[125] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២, ទ៣៤ គណៈកម្មាធិការអង្គការសហប្រជាជាតិប្រឆាំងការធ្វើទារុណកម្ម (UNCAT) សេចក្តីពន្យល់ទូទៅលេខ ២, CAT/C/GC/២ (ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨) ទ១៣ https://tinyurl.com/UNCAT-GC-2 ,UNGA, "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប, A/៧១/២៩៨, (ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦) https://tinyurl.com/UNSR-Torture-2016 *ECtHR,* Salduz នឹងប្រទេសតួកគី (ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨) ៣៦៣៩១/០២ វាក្យខណ្ឌ ៥៥ https://tinyurl.com/ECHR-Salduz-v-Turkey, គណៈកម្មការអាហ្វ្រិកសម្រាប់សិទ្ធិមនុស្ស និងប្រជាជន "គោលការណ៍ និងឯកសារណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជំនួយផ្នែកច្បាប់នៅអាហ្វ្រិក" (ឆ្នាំ២០០៣) M(១)(F) https://tinyurl.com/ACHPR-Guidelines, UNGA, "គោលការណ៍ និងឯកសារណែនាំរបស់អង្គការសហប្រជាជាតិស្តីពីការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ៖ សេចក្តីសម្រេច/អនុម័តដោយមហាសន្និបាត" A/RES/៦៧/១៨៧, (ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៣), https://tinyurl.com/UNGA-Res-67-187 , គណៈកម្មាធិការអឺរ៉ុបស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប"ការទទួលបានមេធាវីដើម្បីជាមធ្យោបាយនៃការបង្ការការធ្វើបាប" CPT/Inf (ឆ្នាំ២០១១) ២៨-ផ្នែកទី ១ (ឆ្នាំ២០១១), https://tinyurl.com/CPTAccesstoLawyer

[126] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តិ ឬការដាក់ទោសឃោរឃៅ អមនុស្សធម៌ ឬការបន្ថោកបន្ទាប *Manfred Nowak",* A/HRC/១៣/៣៩, (ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០), ៥២ https://tinyurl.com/UNSR-Torture-2010, UNGA, "របាយការណ៍បណ្តោះអាសន្នរបស់អ្នករាយការណ៍ពិសេសស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប" A/៦៨/២៩៥, (ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣), ទ៧៣ https://tinyurl.com/UNSR-Torture-rep-2013, ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំងសំណួរនៃការធ្វើទារុណកម្ម និងការឃុំខ្លួន" E/CN.4/២០០៣/៦៨, (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០២) ទ ២៦(ឆ) https://tinyurl.com/គណៈកម្មាធិការសិទ្ធិមនុស្ស-Torture-2002

[127] អនុគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប"សេចក្តីថ្លែងការណ៍បណ្តោះអាសន្នស្តីពីតួនាទីនៃការត្រួតពិនិត្យប្រព័ន្ធតុលាការ និងដំណើរការត្រឹមត្រូវក្នុងការទប់ស្កាត់ការធ្វើទារុណកម្មនៅក្នុងពន្ធនាគារ ដែលអនុម័តដោយអនុគណៈកម្មាធិការស្តីពីការទប់ស្កាត់ការធ្វើទារុណកម្ម

រដ្ឋភាគីនៃពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលប្រទេសកម្ពុជាជាប្រទេសហត្ថាលេខីមួយតាំងពីឆ្នាំ២០០៧ មក ត្រូវអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការអនុម័ត "វិធានការច្បាប់ រដ្ឋបាលតុលាការ ឬវិធានការផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ដើម្បីទប់ស្កាត់អំពើទារុណកម្មលើដែនដីណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន"។[128]

វាក្យសព្ទច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ៖

- **សិទ្ធិមិនអាចធ្វើបដិប្បញ្ញត្តិបាន៖** សិទ្ធិដែលរដ្ឋាភិបាលមិនអាចព្យួរការអនុវត្តបានក្នុងកាលៈទេសៈនៃ "ការដាក់ប្រទេសក្នុងគ្រាអាសន្ន" ក្រោមមាត្រា៤ នៃ ក.អ.ស.ព.ន។
- ***សិទ្ធិដាច់ខាត៖*** សិទ្ធិដែលមិនត្រូវបានអនុញ្ញាតឱ្យមានការរឹតត្បិតណាមួយ។
- **បទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិទូទៅ (ជូស ខូស្យិន)៖** "បទដ្ឋានដែលត្រូវបានសហគមន៍អន្តរជាតិនៃបណ្តារដ្ឋទាំងអស់ទទួលយក និងទទួលស្គាល់ថាជាបទដ្ឋានមួយដែលមិនអាចធ្វើបដិប្បញ្ញត្តិបាន ហើយអាចកែប្រែបានតាមរយៈបទដ្ឋានដែលនៅក្រោមច្បាប់អន្តរជាតិទូទៅដែលមានលក្ខណៈដូចគ្នាតែប៉ុណ្ណោះ"។[129]

គួរព្រឺកផងដែរថា នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់ខ្លួនសម្រាប់ការពិនិត្យលើប្រទេសកម្ពុជាក្នុងឆ្នាំ២០២២ គណៈកម្មាធិការសិទ្ធិមនុស្សបានសម្តែងការព្រួយបារម្ភថា ទោះបីជាមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌ ហាមឃាត់ការធ្វើទារុណកម្ម និងអំពើឃោរឃៅ ប៉ុន្តែច្បាប់នេះ មិនបានផ្តល់និយមន័យផ្លូវច្បាប់ណាមួយអំពីការធ្វើទារុណកម្ម និងការធ្វើបាបនោះឡើយ។[130] គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរនូវការព្រួយបារម្ភរបស់ខ្លួនពាក់ព័ន្ធនឹងសមត្ថភាពដែលគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ដើម្បីចុះទស្សនកិច្ចទៅកាន់ពន្ធនាគារ និងសម្ភាសន៍អ្នកជាប់ឃុំ ក៏ដូចជាឯករាជ្យភាពរបស់ខ្លួន។[131] លើសពីនេះ គណៈកម្មាធិការក៏មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការចោទប្រកាន់ធ្ងន់ធ្ងរអំពីទារុណកម្ម និងការធ្វើបាបដែលកើតឡើងនៅក្នុងមណ្ឌលឃាត់ខ្លួនរបស់នគរបាល និងកន្លែងឃុំឃាំងផ្សេងទៀតដែលក្នុងករណីខ្លះបានបណ្តាលឱ្យស្លាប់ផងដែរ។[132]

និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប CAT/OP/១ (ថ្ងៃទី០១ ខែតុលា ឆ្នាំ ២០១២)&១៨ https://tinyurl.com/CAT-OP-2012

[128] ដូចខាងលើ

[129] គណៈកម្មការច្បាប់អន្តរជាតិ "របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិស្តីពីការងារនៅសម័យប្រជុំលើកទី ៧១ របស់ខ្លួន" សេចក្តីបន្ថែមលេខ ១០ (A/៧៤/១០) (ឆ្នាំ២០១៩) វាក្យខណ្ឌ ៥៦, https://tinyurl.com/42tkj27m

[130] គណៈកម្មាធិការសិទ្ធិមនុស្ស (HRC) "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយលើរបាយការណ៍តាមកាលកំណត់របស់កម្ពុជា (CCPR/C/KHM/CO/៣), វាក្យខណ្ឌទី ២២, https://tinyurl.com/HRC-Concluding-Obs-2022

[131] ដូចខាងលើ

[132] គណៈកម្មាធិការសិទ្ធិមនុស្ស "សេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ" វាក្យខណ្ឌ ២២

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ នៅក្នុងចំណោមជនជាប់ចោទទាំង ៥៧៣ នាក់ ពុំមានជនជាប់ចោទណាម្នាក់បានបង្ហាញថា ពួកគាត់ត្រូវបានស្តាប់ចម្លើយដោយគ្មានវត្តមានមេធាវីរបស់ពួកគាត់នោះទេ។ ដូច្នេះ អស់រយៈពេលបីឆ្នាំជាប់ៗគ្នាដែលពុំមានរបាយការណ៍អំពីករណីបែបនេះ គឺជាវឌ្ឍនភាពគួរឱ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០២២ ដែលកាលឆ្នាំនោះមានចំនួនប្រាំមួយករណី។ នៅឆ្នាំ២០២៥ សាលាឧទ្ធរណ៍គោលដៅទាំងបួន មិនមានជនជាប់ចោទណាម្នាក់បានរាយការណ៍ថា ពួកគាត់បានរងការគំរាមកំហែងឱ្យសារភាពនោះទេ ខណៈពេលដែលជនជាប់ចោទចំនួនពីរនាក់បានរាយការណ៍អំពីបញ្ហានេះកាលពីឆ្នាំមុន មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ជាវិជ្ជមាន បើធៀបនឹងឆ្នាំ២០២៣ មានចំនួនប្រាំនាក់។

តួលេខទី២១៖ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង[133]



នៅឆ្នាំ២០២៥ ជនជាប់ចោទចំនួនបួននាក់បានរាយការណ៍ថាខ្លួនបានទទួលរងនូវអំពើហិង្សា ឬការធ្វើទារុណកម្ម ដើម្បីឱ្យផ្តល់ចម្លើយសារភាពក្នុងអំឡុងពេលស៊ើបអង្កេតដោយមន្ត្រីនគរបាលយុត្តិធម៌។ មានចំនួនពីរនាក់នៅសាលាឧទ្ធរណ៍ភ្នំពេញ និងចំនួនពីរនាក់នៅសាលាឧទ្ធរណ៍ព្រះសីហនុ។ តួលេខនេះ គឺបង្ហាញពីចំនួនថយចុះគួរឱ្យកត់សម្គាល់ជាវិជ្ជមាននៅប៉ុន្មានឆ្នាំចុងក្រោយនេះ បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ១៥ នាក់ ឆ្នាំ ២០២៣ មានចំនួន ១៦ នាក់ និងឆ្នាំ២០២២ មានចំនួន ១៧ នាក់ ។ សាលាឧទ្ធរណ៍ទាំងបួនត្រូវលើកទឹកចិត្តឱ្យសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីធានាថា មិនមានបុគ្គលណាម្នាក់ដែលត្រូវទទួលរងការគំរាមកំហែង អំពើហិង្សា ឬការធ្វើទារុណកម្មនោះទេ។ ទោះជាយ៉ាងនេះក្តី ចំនួនជនជាប់ចោទនេះ នៅតែជាបញ្ហាគួរត្រូវយកចិត្តទុកដាក់ និងគោរពនូវសេចក្តីថ្លៃថ្នូររបស់បុគ្គលដែលសិទ្ធិនេះមិនអាចធ្វើបដិប្បញ្ញត្តិបាន។

[133] ទិន្នន័យនេះផ្អែកទៅលើចំនួនសរុបនៃជនជាប់ចោទ ៥៧៣ នាក់ក្នុងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេត។

តួលេខទី២២៖ និន្នាការពាក់ព័ន្ធនឹងការលើកឡើងរបស់ជនជាប់ចោទពីអំពើហិង្សា ឬការធ្វើទារុណកម្មពីសំណាក់នគរបាលយុត្តិធម៌ ដើម្បីបង្កឹតបង្កំឱ្យសារភាពនៅចំពោះមុខសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅទាំងបួន (ចាប់ពីឆ្នាំ២០២២)[134]



សាលាឧទ្ធរណ៍ភ្នំពេញ

នៅឆ្នាំ២០២៥ មានជនជាប់ចោទចំនួនពីរនាក់បានរាយការណ៍ថា ខ្លួនបានទទួលរងនូវការធ្វើទារុណកម្ម ឬអំពើហិង្សា អំឡុងពេលត្រូវបាននគរបាលឃាត់ខ្លួន។ នេះមានន័យថាសិទ្ធិនេះមិនទាន់ត្រូវបានគោរពពេញលេញ ប៉ុន្តែតួលេខនេះគឺជាការថយចុះគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២៤ មានរហូតដល់ចំនួនដប់មួយនាក់។ តួលេខនេះក៏បង្ហាញពីការថយចុះផងដែរ បើធៀបនឹងឆ្នាំ២០២៣ មានចំនួនបួននាក់។ អ្វីដែលគួរឱ្យកត់សម្គាល់ជាវិជ្ជមានដែរនោះនៅឆ្នាំ២០២៥ ពុំមានសំណុំរឿងណាមួយដែលបង្ហាញថាជនជាប់ចោទបានរងការគំរាមកំហែងដើម្បីបង្កឹតបង្កំឱ្យសារភាពនោះទេ អំឡុងពេលឃាត់ខ្លួនដោយនគរបាលយុត្តិធម៌។

ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក ពាក់ព័ន្ធនឹងលទ្ធផលរកឃើញ តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា ជាធម្មតា ពួកគាត់ស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើការផ្ទៀងផ្ទាត់បញ្ជាក់ថាតើជនត្រូវចោទបានអះអាងថាមានការធ្វើទារុណកម្ម អំពើហិង្សា ឬការគំរាមកំហែង ដូចជា មានស្លាកស្នាម ឬភស្តុតាងផ្សេងៗ

---

[134] ទិន្នន័យនេះផ្អែកលើភាគរយនៃជនជាប់ចោទដែលបានលើកឡើងថា មានការប្រើអំពើហិង្សា ឬការធ្វើទារុណកម្មមកលើពួកគេដើម្បីបង្កឹតបង្កំពួកគេឱ្យសារភាពចំពោះបទល្មើសដែលចោទប្រកាន់មកលើពួកគេនៅសាលាឧទ្ធរណ៍ភ្នំពេញ (រហូតដល់ឆ្នាំ២០២១) និងភាគរយជនជាប់ចោទដែលបានលើកឡើងដូចគ្នានៅចំពោះមុខតុលាការគោលដៅទាំងបួន ក្នុងសំណុំរឿងដែលជនជាប់ចោទ ឬមេធាវីរបស់ពួកគេមានវត្តមានចូលរួមសវនាការ(ចាប់ពីឆ្នាំ២០២២ទៅមុខ)។ ដោយហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្តប់ទូទាំងប្រទេស មុនពេលដែល សាលាឧទ្ធរណ៍ទាំងបីចាប់ផ្តើមដំណើរការ ក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការទាំងមូល។ និន្នាការនេះក៏ត្រូវអនុវត្តចំពោះតួលេខចាប់ពីឆ្នាំ២០២២ ទៅមុខដែរ ក្នុងពេលដែល ម.ស.ម.ក បានចាប់ផ្តើមសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីនោះ។ តួលេខក្នុងឆ្នាំ២០២១ ត្រូវបានបង្ហាញពីចន្លោះទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពដែលស្ថិតក្រោមយុត្តាធិការរបស់សាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។

ដែរឬទេ។[135] តំណាងសាលាឧទ្ធរណ៍បានបន្ថែមថាតុលាការមិនអាចផ្អាកដំណើរការនីតិវិធីបានទេ លុះត្រាតែមានភស្តុតាងគ្រប់គ្រាន់ថាមានការធ្វើទារុណកម្ម ឬការគំរាមកំហែង។[136] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានឆ្លើយតបថា សាលាឧទ្ធរណ៍នឹងប្រាប់ដល់សាលាដំបូងទាំងអស់ដែលក្រោមយុត្តាធិការរបស់ខ្លួនអំឡុងពេលចុះអធិការកិច្ច ឱ្យសាលាដំបូងត្រូវសួរនាំឱ្យបានល្អិតល្អន់ បើសិនមានការលើកឡើងថា មានការបង្ខិតបង្ខំ ឬធ្វើទារុណកម្មលើជនជាប់ចោទ និងត្រូវធ្វើការកោះហៅអ្នកព័ន្ធពាក់មកសាកសួរតាមនីតិវិធី ដើម្បីធានាករណីនេះត្រូវបានដោះស្រាយ។ ចំពោះសាលាឧទ្ធរណ៍ភ្នំពេញនឹងធ្វើការចាត់របៀបលើសំណុំរឿងដែលមានការលើកឡើងដោយជនជាប់ចោទថា មានការបង្ខិតបង្ខំ ឬធ្វើទារុណកម្ម បើមានមូលដ្ឋានគ្រប់គ្រាន់អាចពិចារណាបាន ហើយករណីនេះមិនទាន់ត្រូវបានដោះស្រាយដោយសាលាដំបូងនៅឡើយ។[137] យោងតាមការសិក្សាផ្នែកសិទ្ធិមនុស្ស និងច្បាប់បានឱ្យដឹងថា ជារឿយៗ ការធ្វើទារុណកម្មបានកើតមានឡើងដោយមិនបន្សល់ទុកស្លាកស្នាម ដែលអាចមើលឃើញនៅលើរាងកាយរបស់ជនរងគ្រោះឡើយ ហើយការធ្វើទារុណកម្មក៏បង្កផលប៉ះពាល់ជាច្រើនលើទាំងផ្លូវចិត្តផង ឬលើរាងកាយផង។[138] ដូច្នេះ ករណីមានការធ្វើទារុណកម្ម ការស៊ើបអង្កេតមិនគួរផ្តោតតែទៅលើស្លាកស្នាម ដែលអាចមើលឃើញនៅលើរាងកាយតែប៉ុណ្ណោះនោះទេ។

សាលាឧទ្ធរណ៍បាត់ដំបង

គួរឱ្យកត់សម្គាល់ជាវិជ្ជមាន នៅឆ្នាំ២០២៥ មិនមានសំណុំរឿងណាមួយថាមានជនជាប់ចោទណាម្នាក់បានលើកឡើងថាបានទទួលរងការធ្វើទារុណកម្ម ឬអំពើហិង្សា អំឡុងពេលឃាត់ខ្លួនដោយនគរបាលនោះទេនៅចំពោះមុខសាលាឧទ្ធរណ៍បាត់ដំបង។ នេះគឺជាការប្រសើរឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆ្នាំ២០២៤ មានជនជាប់ចោទចំនួនពីរនាក់ ហើយបើធៀបនឹងឆ្នាំ២០២៣ ដែលមានជនជាប់ចោទចំនួនប្រាំបីនាក់។ ជាលទ្ធផល សាលាឧទ្ធរណ៍បាត់ដំបងបានលើកកម្ពស់សិទ្ធិនេះ។

---

[135] នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[136] ដូចខាងលើ

[137] នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[138] Natasa Mavronicola *ការធ្វើទារុណកម្ម ភាពអមនុស្សធម៌ និងការបន្ទោកបន្ទាប ក្រោមមាត្រា ៣ របស់តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR)៖ សិទ្ធិដាច់ខាត និងកំហុសដាច់ខាត* (Bloomsbury Academic ឆ្នាំ២០២១) ទំព័រ ៤៧ ដោយ Darius Rejali, *ការធ្វើទារុណកម្ម និងលទ្ធិប្រជាធិបតេយ្យ* (Princeton University Press ឆ្នាំ២០០៧)

http://ebookcentral.proquest.com/lib/universityofessex-ebooks/detail.action?docID=457889 ទំព័រ ៤។

Amanda C de C Williams និង Jannie van der Merwe "ផលប៉ះពាល់ផ្លូវចិត្តពីការធ្វើទារុណកម្ម (The Psychological Impact of Torture)" (ឆ្នាំ២០១៣), 7 British Journal of Pain ទំព័រ១០១។

ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានលើកឡើងថា ក្នុងសំណុំរឿងមួយចំនួន ជនជាប់ចោទមិនបានរាយការណ៍ថាបានទទួលរងអំពើហិង្សា ការធ្វើទារុណកម្ម ឬការគំរាមកំហែងណាមួយនៅចំពោះមុខសាលាដំបូងទេ រហូតទាល់តែដល់ដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍ ទើបពួកគាត់លើកពីបញ្ហានេះ ហើយបានបដិសេធសេចក្តីថ្លែងការណ៍ពីមុនរបស់ខ្លួន។[139] គួរកត់សម្គាល់ថា បើតាមកាតព្វកិច្ចរបស់កម្ពុជាចំពោះច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ កម្ពុជាត្រូវតែ "ធានាថាអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនត្រូវស៊ើបអង្កេតយ៉ាងរហ័ស និងមិនលម្អៀង ក្នុងករណីមានមូលដ្ឋានសមហេតុផលដែលជឿថាមានអំពើធ្វើទារុណកម្មត្រូវបានប្រព្រឹត្តស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន"។[140]

សាលាឧទ្ធរណ៍ព្រះសីហនុ

នៅឆ្នាំ២០២៥ និង២០២៤ សាលាឧទ្ធរណ៍ព្រះសីហនុមានទិន្នន័យដូចគ្នាពាក់ព័ន្ធនឹងសិទ្ធិនេះ ដោយក្នុងនោះមានជនជាប់ចោទពីរនាក់ក្នុងរយៈពេលពីរឆ្នាំជាប់គ្នា ជនជាប់ចោទបានលើកឡើងថាខ្លួនបានទទួលរងការធ្វើទារុណកម្ម ឬអំពើហិង្សាក្នុងអំឡុងពេលឃាត់ខ្លួនដោយនគរបាល។ ជារួម គឺមិនមានវឌ្ឍនភាពចំពោះការអនុវត្តនៅឆ្នាំ២០២៥ ទោះជាយ៉ាងណា គួរឱ្យកត់សម្គាល់ជាវិជ្ជមានដែលមិនមានសំណុំរឿងណាមួយពាក់ព័ន្ធនឹងការគំរាមកំហែងលើជនជាប់ចោទនោះទេ ដូចគ្នាឆ្នាំ២០២៤ ដែរ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

មិនមានសំណុំរឿងណាមួយដែលបង្ហាញថាជនជាប់ចោទបានទទួលរងការធ្វើទារុណកម្ម ឬអំពើហិង្សា ឬការគំរាមកំហែងណាមួយឡើយ។ សម្រាប់ពីរឆ្នាំជាប់ៗគ្នា មានតែសាលាឧទ្ធរណ៍ត្បូងឃ្មុំមួយប៉ុណ្ណោះក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួន ដែលបានលើកកម្ពស់ពេញលេញនូវសិទ្ធិមិនត្រូវបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ នេះជាលទ្ធផលគួរឱ្យកត់សម្គាល់ជាវិជ្ជមាន ដែលសាលាឧទ្ធរណ៍ត្បូងឃ្មុំបានបន្តនូវគោរពពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដ៏សំខាន់នេះ។

---

[139] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន ។

[140] អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទោបង្ខាប(អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧) មាត្រា ១២។ https://tinyurl.com/UNCAT-1984

៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរពពេញលេញ

៥.១ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

ច្បាប់កម្ពុជា
ក្រមនីតិវិធីព្រហ្មទណ្ឌ
មាត្រា ៣៥៧ & មាត្រា ៤០៣

ដូចមានចែងនៅក្នុងច្បាប់កម្ពុជា សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុជានាថា សេចក្តីសម្រេចព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាម្នាក់ ត្រូវតែមានការពន្យល់អំពីមូលហេតុ និងមូលដ្ឋានក្នុងការសម្រេច និងមូលហេតុដែលបង្ហាញថាបុគ្គលនោះត្រូវបានរកឃើញថាមានពិរុទ្ធភាព ឬគ្មានទោស។[141] ដើម្បីសម្រេចគោលបំណងនេះ សាលក្រម/សាលដីកា ត្រូវតែបង្ហាញឱ្យបានលម្អិតគ្រប់គ្រាន់អំពីអង្គហេតុនៃសំណុំរឿង (កាលបរិច្ឆេទ ទីកន្លែង ហេតុការណ៍ជាក់ស្តែង) ចៅក្រមត្រូវសំអាងលើកស្តុតាង ដើម្បីឈានដល់ការចេញសាលក្រម/សាលដីកា និងត្រូវមានការពន្យល់អំពីសំអាងហេតុ និងច្បាប់ (ឧ. បទល្មើស និងរបៀបនៃការទទួលខុសត្រូវ៖ ចារីអ្នកសមគំនិត ។ល។) សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ គឺជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងមាននៅក្នុងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ សិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុមិនត្រឹមតែការពារជនជាប់ចោទប្រឆាំងនឹងសេចក្តីសម្រេចមិនត្រឹមត្រូវនោះទេ ប៉ុន្តែថែមទាំងការពារសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងការប្តឹងឧទ្ធរណ៍ផងដែរ។ យោងតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដើម្បីអនុវត្តសិទ្ធិនេះប្រកបដោយប្រសិទ្ធភាព ពិរុទ្ធជនមានសិទ្ធិទទួលបាននូវការពិនិត្យឡើងវិញលើការផ្តន្ទាទោស និងការកាត់ទោសដោយសាលាជម្រះក្តីជាន់ខ្ពស់ ហើយពិរុទ្ធជនមានសិទ្ធិទទួលបាននូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលមានសំអាងហេតុត្រឹមត្រូវនៅក្នុងពេលវេលាសមរម្យមួយសម្រាប់បណ្តឹងឧទ្ធរណ៍។[142] នៅក្នុងបរិបទកម្ពុជា ទាំងភាគីជនជាប់ចោទ និងតំណាងមហាអយ្យការ មានសិទ្ធិប្តឹងសារទុក្ខលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទៅកាន់តុលាការកំពូល ដើម្បីឱ្យពិនិត្យមើលលើសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ឡើងវិញ។

---

[141] សម្រាប់ព័ត៌មានលម្អិតអំពីសិទ្ធិនេះ សូមមើលនៅក្នុងកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ" (ខែកញ្ញា ឆ្នាំ២០២២), https://tinyurl.com/5ssncyyy

[142] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៤៩ គណៈកម្មាធិការសិទ្ធិមនុស្ស បណ្តឹងលេខ ៣២០/១៩៨៨, V. Francis v. Jamaica (ថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣), *GAOR*, A/៤៨/៤០ (vol. II), វាក្យខណ្ឌ ១២,២, https://tinyurl.com/275fa3sr

តួលេខទី២៣៖ ភាគរយនៃសវនាការបានសង្កេត ដែលចៅក្រមបានផ្តល់សំអាងហេតុពេលប្រកាសសាលដីកា[143]



ក្នុងចំណោមសាលដីកាទាំងអស់ ដែលបានស្តាប់នៅតាមសាលាឧទ្ធរណ៍គោលដៅទាំងបួននៅឆ្នាំ ២០២៥ ចៅក្រមបានប្រាប់ពីសំអាងហេតុមានចំនួន ២៤% (៨ ក្នុងចំណោម ៣៣ សំណុំរឿង)។ ការណ៍នេះមានន័យថា ៧៦% នៃសំណុំរឿងទាំងនោះ ជនជាប់ចោទមិនបានទទួលការប្រាប់អំពីសំអាងហេតុរបស់ខ្លួននោះទេ។ តួលេខនេះមានការកើនបន្តិច បើធៀបនឹងឆ្នាំ២០២៤ ដែលមាន ៧៣%។ ផ្នែកមួយនៃការវាយតម្លៃសិទ្ធិនេះ វត្តមានមេធាវីរបស់ជនជាប់ចោទជាកត្តាមានសារៈសំខាន់ណាស់ក្នុងការជួយជនជាប់ចោទឱ្យយល់ច្បាស់នៅពេលចៅក្រមប្រកាសអំពីសេចក្តីសម្រេចជាសាលដីកា។ នៅឆ្នាំ២០២៥ មានវត្តមានមេធាវីរបស់ជនជាប់ចោទក្នុងពេលប្រកាសសាលដីកា មានចំនួន ៦០% (១៨ ក្នុងចំណោម ៣០ សំណុំរឿង)។ តួលេខនេះគឺគួរឱ្យកត់សម្គាល់ជាវិជ្ជមាន បើធៀបនឹងឆ្នាំមុនៗ ដោយក្នុងនោះមេធាវីមានវត្តមានពេលប្រកាសសាលដីកាចំនួន ៣១% នៅឆ្នាំ២០២៤ និង១១% ប៉ុណ្ណោះ នៅឆ្នាំ២០២៣។

សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះការអានប្រាប់អំពីសំអាងហេតុពេលប្រកាសសាលដីការបស់ខ្លួននៅឆ្នាំ២០២៥ មានចំនួនត្រឹមតែ១៧% ប៉ុណ្ណោះដែលចៅក្រមអានប្រាប់សំអាងហេតុដោយសង្ខេបដល់ភាគីសំណុំរឿង (៥ ក្នុងចំណោម ៣០ សំណុំរឿង)។ ចំនួននេះមានការថយចុះគួរឱ្យកត់សម្គាល់ បន្ទាប់ពីមានលទ្ធផលល្អប្រសើរនៅឆ្នាំ២០២៤ ចំនួន ៦២,៥% និងចំនួន ២៩,៦% នៅឆ្នាំ២០២៣។ ការប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានអះអាងថា ប្រសិនបើជនជាប់ចោទមានវត្តមាន ហើយចៅក្រមមិនបានអានប្រាប់ពីសំអាងហេតុដល់ជនជាប់ចោទ សូមប្រាប់ឈ្មោះរបស់ចៅក្រមទៅកាន់ថ្នាក់ដឹកនាំរបស់សាលាឧទ្ធរណ៍។ តំណាងសាលាឧទ្ធរណ៍ក៏បានបញ្ជាក់ដែរថា ក្នុងសំណុំរឿងដែលមានវត្តមានមេធាវីក្នុងពេលប្រកាសសាលដីកា ចៅក្រម

[143] ទិន្នន័យនេះ គឺផ្អែកលើសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅឆ្នាំ២០២៥។ (មិនបានស្តាប់) មានន័យថាអ្នកសង្កេតសវនាការមិនមានវត្តមាននៅថ្ងៃប្រកាសសាលដីកា។

អាចផ្តល់សំអាងហេតុខ្លីៗបាន។[144] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា តុលាការនឹងរម្លឹកដល់ចៅក្រមទាំងអស់ ត្រូវសង្ខេបអំពីសំអាងហេតុនៅពេលប្រកាសសាលដីការបស់ខ្លួន តែកន្លងមក មានករណីខកខានអានសំអាងនោះដោយសារជនជាប់ចោទអវត្តមានក្នុងពេលប្រកាសសាលដីកា ដូច្នោះហើយ ចៅក្រមអានប្រាប់តែផ្នែកនៃសេចក្តីសម្រេចប៉ុណ្ណោះ។[145] ដើម្បីធានាបាននូវសង្គតិភាព និងលើកកម្ពស់នូវការអនុវត្តល្អ សាលាឧទ្ធរណ៍ធានាថា ការអានប្រាប់ពីសំអាងហេតុត្រូវផ្តល់គ្រប់សំណុំរឿងទាំងអស់ មិនថាសំណុំរឿងនោះមានវត្តមានមេធាវី ឬគ្មាននោះទេ។ គួរឱ្យកត់សម្គាល់ជាវិជ្ជមាន ក្នុងចំណោមសាលដីកាបានស្តាប់នៅសាលាឧទ្ធរណ៍ភ្នំពេញ សាលដីកាត្រូវបានប្រកាសជាសាធារណៈគ្រប់សំណុំរឿងទាំងអស់ មានអានប្រាប់ពីកាលបរិច្ឆេទ ប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធ និងកស្តុតាងដែលបានបង្ហាញក្នុងអំឡុងពេលជំនុំជម្រះ។ ពុំមានករណីណាមួយដែលបង្ហាញថាចៅក្រមបានចេញសាលដីកាដោយផ្អែកលើកស្តុតាងដែលមិនមានក្នុងឯកសារសំណុំរឿងនោះទេ។

សាលាឧទ្ធរណ៍បាត់ដំបង

នៅឆ្នាំ២០២៥ ម.ស.ម.ក បានស្តាប់សាលដីកាចំនួនពីរប៉ុណ្ណោះនៅសាលាឧទ្ធរណ៍បាត់ដំបង។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿងទាំងពីរ ចៅក្រមបានអានប្រាប់សង្ខេបពីសំអាងហេតុ បានប្រកាសជាសាធារណៈ ប្រាប់ពីមាត្រាច្បាប់ពាក់ព័ន្ធ និងកស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ។ នៅឆ្នាំ២០២៤ ចៅក្រមបានផ្អែកលើចម្លើយសារភាពរបស់ជនជាប់ចោទជាកស្តុតាងចំនួន ២៥,៥% នៃសំណុំរឿង។ ទោះបីជានៅឆ្នាំ២០២៥ ម.ស.ម.ក បានស្តាប់សាលដីកាមានចំនួនតែពីរក្តី ក៏សង្ឃឹមថាតុលាការនឹងដើម្បីធានាថា មិនផ្អែកលើចម្លើយសារភាពទាំងស្រុងនោះទេ ដោយហេតុថា ចម្លើយសារភាពខ្លះមិនគួរឱ្យទុកចិត្តបាន ដូចជាការបង្ខិតបង្ខំ ឬអំពើហិង្សាជាដើម។ សាលដីកាគួរតែផ្អែកលើកស្តុតាងទាំងអស់ដែលមានក្នុងសំណុំរឿង និងបានបង្ហាញនៅចំពោះមុខតុលាការ។ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបង បានអះអាងថា ករណីអវត្តមានជនជាប់ចោទពេលប្រកាសសាលដីកា ចៅក្រមមិនអានប្រាប់ពីសំអាងហេតុទេ គឺចៅក្រមអានប្រាប់តែផ្នែកនៃសេចក្តីសម្រេចតែប៉ុណ្ណោះ។[146]

មានតែសាលដីកាចំនួនមួយប៉ុណ្ណោះដែលបានស្តាប់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមិនបានស្តាប់សាលដីកាណាមួយទេនៅសាលាឧទ្ធរណ៍ព្រះសីហនុ។ សាលាឧទ្ធរណ៍ត្បូងឃ្មុំ ចៅក្រមបានអានប្រាប់ពីសំអាងហេតុដោយសង្ខេប ប្រាប់មាត្រាច្បាប់ពាក់ព័ន្ធ និងកស្តុតាងដែលបានបង្ហាញនៅសវនាការ។ យ៉ាងណាមិញ ចៅក្រម

---

[144] នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយតំណាងសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[145] នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[146] នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ផ្អែកលើការសារភាពរបស់ជនជាប់ចោទជាភស្តុតាងថាមានពិរុទ្ធភាព។ ការមិនផ្អែកទាំងស្រុងលើចម្លើយសារភាពរបស់ជនជាប់ចោទជាកត្តាសំខាន់។ សាលដីកាមួយដែលបានស្តាប់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ នៅឆ្នាំ ២០២៤ ចៅក្រមមិនបានយកចម្លើយសារភាពរបស់ជនជាប់ចោទជាភស្តុតាងនោះទេ។ ដូចនេះ តុលាការត្រូវបានលើកទឹកចិត្តនូវប្រកាន់ខ្ជាប់ការប្រតិបត្តិល្អបន្តទៅមុខទៀត ដោយមិនផ្អែកទាំងស្រុងលើចម្លើយសារភាពនោះទេ។

៥.២ សិទ្ធិទទួលបានមេធាវី

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា		
ក.អ.ស.ព.ន	**រដ្ឋធម្មនុញ្ញ**	**ក្រមនីតិវិធីព្រហ្មទណ្ឌ**	**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
មាត្រា ១៤(៣)(ឃ)	មាត្រា ៣៨	មាត្រា ១៤៣ មាត្រា ៣០០ មាត្រា ៣០១ និងមាត្រា ៣៨៩	មាត្រា ៦ មាត្រា ៥០ និងមាត្រា ៥១

ការចោទប្រកាន់ពីបទល្មើសណាមួយ តម្រូវឱ្យមានការធ្វើតាមនីតិវិធីច្បាប់ ដែលករណីខ្លះអាចមានលក្ខណៈស្មុគស្មាញ និងពិបាក។ ដើម្បីធានាថា សិទ្ធិរបស់ជនរងការចោទប្រកាន់ ត្រូវបានការពារយ៉ាងពេញលេញក្នុងអំឡុងពេលដំណើរការនីតិវិធីព្រហ្មទណ្ឌ ពួកគេគួរត្រូវមានមេធាវីការពារសិទ្ធិដែលមានសមត្ថភាពពន្យល់អំពីសិទ្ធិ និងការចោទប្រកាន់មកលើពួកគេ ណែនាំពួកគេឱ្យយល់អំពីដំណើរការនីតិវិធីទាំងមូល និងការពារផលប្រយោជន៍របស់ពួកគេនៅក្នុងតុលាការ។ ប្រសិនបើជនរងការចោទប្រកាន់មិនអាចមានលទ្ធភាពជួលមេធាវីទេនោះ អាជ្ញាធរពាក់ព័ន្ធគួរតែផ្តល់មេធាវីដោយឥតគិតថ្លៃ និងជាផលប្រយោជន៍យុត្តិធម៌តម្រូវដូច្នោះ។[147] នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការទទួលបានមេធាវីការពារសិទ្ធិ គឺជាកាតព្វកិច្ចរបស់រដ្ឋដែលត្រូវផ្តល់ឱ្យសម្រាប់តែបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបើជននោះជាអនីតិជនប៉ុណ្ណោះ។ ដូច្នេះហើយ មិនមែនជាកាតព្វកិច្ចរបស់រដ្ឋត្រូវផ្តល់ឱ្យដល់បុគ្គលដែលត្រូវចោទប្រកាន់ពីបទមជ្ឈិមនោះទេ (លើកលែងតែពួកគេជាអនីតិជន) ប៉ុន្តែបុគ្គលទាំងនោះនៅតែអាចជួលមេធាវីដោយខ្លួនឯងបានប្រសិនបើពួកគេត្រូវការ តែនេះមិនមែនជាកាតព្វកិច្ចរបស់តុលាការនោះទេ។ ទោះបានចែងជាយ៉ាងនេះក្តី រដ្ឋនៅតែជាប់កាតព្វកិច្ចក្នុងការផ្តល់មេធាវីដល់ជនជាប់ចោទដោយឥតគិតកម្រៃ។

ក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួននៅឆ្នាំ២០២៥ មានជនជាប់ចោទចំនួន ៥៦% (៣២៣ ក្នុងចំណោម ៥៧៣ នាក់) ប៉ុណ្ណោះដែលមានមេធាវីការពារ។ ចំណុចនេះបង្ហាញពីការកើនឡើងបន្តិច បើធៀបនឹងឆ្នាំ២០២៤ មានចំនួនតែ ៥៥,៨%។ ទោះបីជាមានភាពប្រសើរគួរកត់សម្គាល់ក្តី តែតួលេខនេះនៅតែទាបជាងឆ្នាំ២០២៣ មានចំនួន ៥៨,៧% និងឆ្នាំ២០២២ មាន ៦៦,៧%។ នេះគឺជាឆ្នាំទីពីរហើយដែលតុលាការទាំងបួននៅមិនទាន់បានលើកកម្ពស់សិទ្ធិនេះនៅឡើយ ទោះយ៉ាងនេះក្តី សាលាឧទ្ធរណ៍ព្រះសីហនុបានគោរព

[147] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឃ) គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ៣៨។

សិទ្ធិនេះនេះនៅឆ្នាំ២០២៣ មានចំនួន ៨១,៦%។ ជាការប្រសើរដែលជនជាប់ចោទពីបទឧក្រិដ្ឋទាំងអស់នៅសាលាឧទ្ធរណ៍ទាំងបួនមានមេធាវីការពារ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

តួលេខទី២៤៖ ភាគរយនៃជនជាប់ចោទមានមេធាវីការពារនៅឆ្នាំ២០២៥ នៅតាមតុលាការគោលដៅ[148]



ជនជាប់ចោទគ្រប់រូបមានសិទ្ធិទទួលបានព័ត៌មានអំពីជំនួយផ្នែកច្បាប់ ប្រសិនបើពួកគាត់មិនមានជំនួយផ្នែកច្បាប់នោះទេ។[149] ទោះបីជា ច្បាប់កម្ពុជាដាក់ការទទួលខុសត្រូវនេះ លើមន្ត្រីនគរបាលយុត្តិធម៌ចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាក៏ដោយ[150] ម.ស.ម.ក លើកទឹកចិត្តដល់ចៅក្រមសាលាឧទ្ធរណ៍ឱ្យអនុវត្តតាមការប្រតិបត្តិល្អជាប្រព័ន្ធ ពេលគឺមិនត្រឹមតែផ្តល់ព័ត៌មានអំពីសិទ្ធិទទួលបានមេធាវីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពន្យល់ដល់ជនជាប់ចោទដែលមិនមានមេធាវីផងដែរ។ បន្ទាប់ពីបានពន្យល់រួចហើយ ចៅក្រមគួរតែទទួលការយល់ព្រមថា តើជនជាប់ចោទព្រមបន្តដំណើរការនីតិវិធីសំណុំរឿងដោយគ្មានមេធាវីដែរឬទេ។ ការបន្តនីតិវិធីដោយគ្មានមេធាវីអាចមានផលប៉ះពាល់ជាច្រើនលើសំណុំរឿងរបស់ជនជាប់ចោទ ក៏ដូចជាលទ្ធផលចុងក្រោយផងដែរ។

បើយោងតាមមាត្រា៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងការពិនិត្យឯកសារសំណុំរឿង គឺថាមានតែមេធាវី ឬលេខាធិការមេធាវីប៉ុណ្ណោះ ដែលអាចពិនិត្យមើលសំណុំរឿងមុនពេលសវនាការ និងថតចម្លងឯកសារដែលមាននៅក្នុងនោះបាន។ នេះមានន័យថា ជនជាប់ចោទដែលគ្មានមេធាវី នឹងមិនអាចចូលមើល

---

[148] ទិន្នន័យនេះគឺផ្អែកលើជនជាប់ចោទសរុបចំនួន ៥៧៣ នាក់ ដែលពាក់ព័ន្ធក្នុងសំណុំរឿងចំនួន៤២២ ដែលបានសង្កេតនៅឆ្នាំ ២០២៥។

[149] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ឃ)។

[150] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៦, ៤៨, ៩៧, ១៤៣, ៣០៤។

សំណុំរឿងដែលព្រះរាជអាជ្ញានឹងប្រើដើម្បីចោទប្រកាន់ពួកគាត់បាននោះឡើយ។ ដូចនេះហើយទើបប៉ះពាល់ដល់លទ្ធភាពរបស់ពួកគាត់ក្នុងការរៀបចំការពារក្តីដោយខ្លួនឯង។

នៅក្នុងសាលាឧទ្ធរណ៍គោលដៅទាំងបួន ក្នុងឆ្នាំ២០២៥ ចៅក្រមមិនបានអានប្រាប់ ឬពន្យល់អំពីសិទ្ធិការពារដោយខ្លួនឯងដល់ជនជាប់ចោទចំនួន ១៥% ដែលបានសង្កេត (២៩ ក្នុងចំណោម ១៨៨ សំណុំរឿង)។ នេះជាការថយបន្តិច បើធៀបនឹងឆ្នាំ២០២៤ ចំនួន ១៤% ប៉ុន្តែជាការល្អប្រសើរច្រើន បើធៀបនឹងឆ្នាំ២០២៣ មានរហូតដល់ ២៤% និង ៤៨,៦% នៅឆ្នាំ២០២២។ ទោះបីជានៅឆ្នាំ២០២៥ មានភាគរយតិចតួចក្តី ការមិនបានយល់ដឹងអំពីសិទ្ធិនេះនៅតែជាបញ្ហាគួរដោះស្រាយ ដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់គ្នា។

តួលេខទី២៥៖ ភាគរយនៃជនជាប់ចោទដែលចៅក្រមបានអានប្រាប់ និងពន្យល់អំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានមេធាវី ឬការពារខ្លួនឯងនៅតុលាការទាំងបួន[151]



មានការកើនឡើងនៅក្នុងចំណោមតុលាការទាំងបួន គឺទាក់ទងនឹងមេធាវីការពារសិទ្ធិជាប់ចោទលើសពីម្នាក់នៅក្នុងសំណុំរឿងតែមួយ។ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះមាន ៣១% ដែលមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើសពីម្នាក់ (៩៩ ក្នុងចំណោម ៣២៣ នាក់)។ នៅឆ្នាំ២០២៤ មានចំនួន ២៤% និង ២៤% នៅឆ្នាំ២០២៣។ នៅឆ្នាំ២០២៥ មិនមានសំណុំរឿងណាមួយដែលបង្ហាញថាមានទំនាស់ផលប្រយោជន៍ពាក់ព័ន្ធនឹងមេធាវីការពារជនជាប់ចោទលើសពីម្នាក់នោះទេ។ ទោះជាយ៉ាងណា ការការពារជនជាប់ចោទលើសពី

---

151 ផ្អែកលើទិន្នន័យនៃជនជាប់ចោទចំនួន ៥៧៣ នាក់ ដែលយ៉ាងហោចណាស់មានជនជាប់ចោទម្នាក់មានវត្តមានក្នុងសវនាការ (៣៣៧ នាក់នៅសាលាឧទ្ធរណ៍ភ្នំពេញ ៨២ នាក់ នៅសាលាឧទ្ធរណ៍បាត់ដំបង ២២ នាក់ នៅសាលាឧទ្ធរណ៍ព្រះសីហនុ និង១៣២ នាក់ នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ)

ម្នាក់ក៏អាចប៉ះពាល់ដល់សមត្ថភាពរបស់មេធាវីការការពារ និងផលប្រយោជន៍ឱ្យបានពេញលេញផងដែរ។ លើសពីនេះ ក្នុងករណីជនជាប់ចោទមានការឆ្លើយដាក់គ្នា ឬផ្ទុយគ្នា មានន័យថា មេធាវីការពារមិនអាចការពារជនជាប់ចោទណាម្នាក់ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទម្នាក់ទៀតបានទេ។

សាលាឧទ្ធរណ៍ភ្នំពេញ

នៅឆ្នាំ២០២៥ មានចំនួន ៦៥% នៃជនជាប់ចោទមានមេធាវីការពារ (២២០ ក្នុងចំណោម ៣៣៧ នាក់)។ ទិន្នន័យនេះកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំ២០២៤ មានត្រឹម ៥៨% និង៦០,៩% នៅឆ្នាំ ២០២៣ ទោះជាយ៉ាងនេះក្តី គួរលេខនេះនៅតែទាបជាងឆ្នាំ២០២២ មានរហូតដល់ចំនួន ៧៥,៦%។ នៅឆ្នាំ ២០២៥ ជនជាប់ចោទពីបទឧក្រិដ្ឋមានមេធាវីការពារចំនួន ១០០% ជនចាប់ចោទពីបទមជ្ឈិម មានមេធាវីការពារចំនួន ៣៦% (៦៥ ក្នុងចំណោម ១៨២ នាក់)។ នៅឆ្នាំ ២០២៤ ជនជាប់ចោទពីបទមជ្ឈិមដែលមានមេធាវីការពារមានត្រឹម ២៣,៩%។ ទោះយ៉ាងណា បើធៀបនឹងឆ្នាំ២០២៣ ជនជាប់ចោទពីបទមជ្ឈិមមានមេធាវីការពារតែ ៧,២%ប៉ុណ្ណោះ។ ទោះបីជាមេធាវីការពារឱ្យជនជាប់ចោទលើសពីម្នាក់មាន ៣១% (៦៨ ក្នុងចំណោម ២២០ នាក់) ក៏មិនមានទំនាស់ផលប្រយោជន៍ណាមួយនៅក្នុងសំណុំរឿងទាំងនេះទេ លើសពីនេះ មានសំណុំរឿងចំនួនពីរនៅឆ្នាំ២០២៤ ថាមានទំនាស់ផលប្រយោជន៍។

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ សាលាឧទ្ធរណ៍ភ្នំពេញមានការថយចុះទិន្នន័យពាក់ព័ន្ធនឹងចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទដែលមិនមានមេធាវីការពារ អំពីសិទ្ធិការពារខ្លួនឯងផ្ទាល់ ឬតាមរយៈមេធាវី។ មានចំនួន ៤៣% (៣៨ ក្នុងចំណោម ៨៩ នាក់) នៃជនជាប់ចោទដែលមិនមានមេធាវីការពារ ហើយចៅក្រមបានអានប្រាប់ដល់ ឬពន្យល់អំពីសិទ្ធិនេះដល់ពួកគេ បើធៀបនឹងឆ្នាំ២០២៤ ចំនួន ៤៨,៧%។ ទោះជាយ៉ាងណា គួរកត់សម្គាល់ផងដែរថា ចៅក្រមមិនបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះដល់ជនជាប់ចោទបានថយចុះពី ១៨,៨% នៅឆ្នាំ២០២៤ មកនៅត្រឹម ១០% នៅឆ្នាំ២០២៥។

តួលេខ២៦៖ ការប្រៀបធៀបតាមភាគរយនៃជនជាប់ចោទដែលមានមេធាវីការពារនៅសាលាឧទ្ធរណ៍ភ្នំពេញ (ឆ្នាំ២០១៤-២០១៥)[152]

---

[152] ទិន្នន័យនេះផ្អែកលើជនជាប់ចោទ ១៣៥ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ១៦១ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ១២៨ ដែលបានសង្កេតនៅឆ្នាំ២០១៤/២០១៥។ ជនជាប់ចោទ ៤៣៩ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៥៥៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៣៤០ ដែលបានសង្កេតនៅឆ្នាំ២០១៦/២០១៧។ ជនជាប់ចោទ ២៤១ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣១៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២១៣ ដែលបានសង្កេតនៅឆ្នាំ២០១៧/២០១៨។ ជនជាប់ចោទ ២៦២ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២៣៩ ដែលបានសង្កេតនៅឆ្នាំ២០១៨/២០១៩។ ជនជាប់ចោទ ១៨៣ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ២៥៥ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៣ ដែលបានសង្កេតនៅឆ្នាំ២០១៩/២០២០។ ជនជាប់ចោទ ៨៩ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ១១៨ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៨៥ ដែលបានសង្កេតនៅឆ្នាំ ២០២១។ ជនជាប់ចោទ ២៦៦ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៣៥២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿង



សាលាឧទ្ធរណ៍បាត់ដំបង

ជាឆ្នាំទីបួនជាប់ៗគ្នា ដែលសិទ្ធិទទួលបានមេធាវីមិនទាន់បានលើកកម្ពស់ពេញលេញនៅឡើយ។ ក្នុងអំឡុងពេលនៃរបាយការណ៍នេះ ជនជាប់ចោទដែលមានមេធាវីការពារមានចំនួន ៤៩% (៤០ នាក់ ក្នុងចំណោម ៨២ នាក់)។ តួលេខនេះថយចុះបន្តិច បើធៀបនឹងឆ្នាំ២០២៤ មានដល់ ៥៧,៦% និងឆ្នាំ២០២៣ មានចំនួន ៥៣,៨% ។ គួរឱ្យកត់សម្គាល់ជាវិជ្ជមានដែលជនជាប់ចោទពីបទឧក្រិដ្ឋមានមេធាវីការពារទាំងអស់ (២៥ នាក់ ក្នុងចំណោម ២៥ នាក់)។ រីឯជនជាប់ចោទពីបទមជ្ឈិមមានមេធាវីការពារចំនួន ២៦% (១៥ នាក់ ក្នុងចំណោម ៥៧ នាក់) មានការថយចុះបើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៣៥%។ សំណុំរឿងផ្សេងទៀត គឺជនជាប់ចោទមិនមានមេធាវីការពារនោះទេ អាចចាត់ទុកថា ចៅក្រមបានសួរ និងមានការយល់ព្រមពីជនជាប់ចោទដើម្បីបន្តសវនាការដោយគ្មានមេធាវី។ នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា សម្រាប់សំណុំរឿងបទមជ្ឈិម ឬបទលហុ ហើយជនជាប់ចោទមិនមានមេធាវីការពារ ចៅក្រមអាចដំណើរការជំនុំជម្រះបានប្រសិនបើជនជាប់ចោទយល់ព្រមការពារខ្លួនឯងដោយផ្ទាល់ ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[153] គួរឱ្យកត់សម្គាល់ជាវិជ្ជមានចំពោះការថយចុះចំនួនមេធាវីការពារជនជាប់ចោទលើស

ចំនួន ២៥៧ ដែលបានសង្កេតនៅឆ្នាំ២០២២។ ជនជាប់ចោទ ២៨០ នាក់ ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៤៦០ នាក់ដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿង ៣៣៦ ដែលបាន សង្កេតនៅឆ្នាំ២០២៣។ ជនជាប់ចោទ ៤៥៩ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៨២២ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៥៨២ ដែលបានសង្កេតនៅឆ្នាំ២០២៤ និងជនជាប់ចោទ ៣២៣ នាក់ដែលមានមេធាវីម្នាក់ការពារ ក្នុងចំណោមជនជាប់ចោទ ៥៧៣ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅឆ្នាំ២០២៥។

[153] នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ពីមួយនាក់ ពី ៣១,៧% នៅឆ្នាំ២០២៤ មក ២៨% នៅឆ្នាំ២០២៥ (១១ នាក់ ក្នុងចំណោម ៤០ នាក់) និងមិនមានទំនាស់ផលប្រយោជន៍ណាមួយនៅក្នុងសំណុំរឿងទាំងនេះទេ។

មានភាពប្រសើរឡើងពាក់ព័ន្ធនឹងចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិក្នុងការការពារខ្លួនឯង ឬទទួលបានមេធាវីការពារ។ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ ចៅក្រមសាលាឧទ្ធរណ៍បាត់ដំបង បានអានប្រាប់ និងពន្យល់សិទ្ធិនេះ ចំនួន ៦៩% នៃសំណុំរឿង (២២ ក្នុងចំណោម ៣២) មានការកើនឡើង បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៦៧,៤%។ ទោះបីជាមានស្ថានភាពប្រសើរឡើងបែបនេះក៏ដោយ តែករណីដែលចៅក្រមមិនបានអានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិនេះបានកើនឡើងដល់ ២៥% នៃសំណុំរឿង (៨ ក្នុងចំណោម ៣២) នៅឆ្នាំ២០២៥ បើធៀបនឹងឆ្នាំ២០២៤ មានតែ ៤,៥%។ ចំនួនករណីដែលចៅក្រមមិនបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិទទួលបានមេធាវីការពារ រួមទាំងសំណុំរឿងបទមជ្ឈិមដែលមិនគ្មានមេធាវីការពារ អាចបង្ហាញថាជនជាប់ចោទនឹងមិនយល់អំពីសិទ្ធិរបស់ខ្លួនក្នុងការទទួលបានមេធាវី។ ចៅក្រមត្រូវបានលើកទឹកចិត្តឱ្យអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិនេះ ដើម្បីធានាថាពួកគាត់ទទួលបានព័ត៌មានពេញលេញ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានគ្រប់ជ្រុងជ្រោយ។

សាលាឧទ្ធរណ៍ព្រះសីហនុ

សាលាឧទ្ធរណ៍ព្រះសីហនុ មានការប្រសើរឡើងបន្តិចពាក់ព័ន្ធនឹងសិទ្ធិទទួលបានមេធាវី ប៉ុន្តែនៅមិនទាន់អាចចាត់ទុកថាបានគោរពសិទ្ធិនេះនៅឡើយ។ នៅឆ្នាំ២០២៥ ចំនួន ៦៨% នៃជនជាប់ចោទនៅក្នុងសំណុំរឿងមានមេធាវីការពារ (១៥ នាក់ ក្នុងចំណោម ២២នាក់) មានការកើនឡើង បើធៀបនឹងឆ្នាំមុនមានចំនួន ៦៦%។ ទោះបីជាមានភាពប្រសើរគួរឱ្យកត់សម្គាល់ក៏ដោយ តែតួលេខនេះនៅទាបជាងអត្រា ៨១,៦% នៃជនជាប់ចោទដែលមានមេធាវីនៅឆ្នាំ២០២៣។ យ៉ាងណាមិញ សាលាឧទ្ធរណ៍ព្រះសីហនុមានភាគរយខ្ពស់ក្នុងចំណោមសាលាឧទ្ធរណ៍គោលដៅទាំងបួន ពាក់ព័ន្ធនឹងជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិមទទួលបានមេធាវីការពារចំនួន ៥៦% ដែលកើនឡើងពី ៥០% នៅឆ្នាំ២០២៤។ មានជនជាប់ចោទចំនួនបីនាក់មានមេធាវីការពារលើសពីម្នាក់ ប៉ុន្តែមិនមានទំនាស់ផលប្រយោជន៍ណាមួយឡើយ ដែលមានភាពប្រសើរបើធៀបនឹង២០២៣ ដែលមានជនជាប់ចោទចំនួនពីរមានទំនាស់ផលប្រយោជន៍។

មានសំណុំរឿងចំនួនពីរដែលជនជាប់ចោទមានវត្តមាននៅក្នុងសវនាការ ប៉ុន្តែគ្មានមេធាវី។ សំណុំរឿងមួយក្នុងចំណោមសំណុំរឿងទាំងពីរ ចៅក្រមបានអានប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគេក្នុងការការពារខ្លួនឯង ឬទទួលបានមេធាវីការពារ ហើយនៅក្នុងសំណុំរឿងមួយទៀត ចៅក្រមមិនបានអានប្រាប់ ឬពន្យល់ជនជាប់ចោទអំពីសិទ្ធិនេះទេ។ នៅក្នុងការពិគ្រោះយោបល់លើកមុនជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ព្រះសីហនុ បានអះអាងថា ដោយសារជនជាប់ចោទទំនងជាត្រូវបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះរួចហើយ ហេតុដូច្នេះ ចៅក្រមមិនចាំបាច់អានប្រាប់ ឬពន្យល់អំពីសិទ្ធិនេះនៅដំណាក់កាលសវនាការសាលាឧទ្ធរណ៍នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការប្រតិបត្តិល្អគួរត្រូវបានលើកទឹកចិត្ត។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

បួនឆ្នាំជាប់ៗគ្នា ភាគរយនៃជនជាប់ចោទដែលទទួលបានមេធាវីការពារមានចំនួនតិចជាងគេ។ នៅឆ្នាំ ២០២៥ មានចំនួន ៣៦% នៃជនជាប់ចោទទទួលបានមេធាវីការពារ (៤៧ នាក់ ក្នុងចំណោម ១៣២ នាក់) មានការថយចុះ បើធៀបនឹងឆ្នាំ២០២៤ មាន ៤១% ដែលជាចំនួនទាបរួចទៅហើយ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋត្រូវតែមានមេធាវីការពារ ដោយឡែកមានត្រឹម១១% តែប៉ុណ្ណោះនៃជនជាប់ចោទដែលត្រូវបានចោទពីបទមជ្ឈិមទទួលបានមេធាវីការពារ។ ក្នុងចំណោមជនជាប់ចោទដែលមានមេធាវីការពារ មានចំនួន ៣៦% នៃជនជាប់ចោទ (១៧ នាក់ ក្នុងចំណោម ៤៧ នាក់) មានមេធាវីការពារលើសពីម្នាក់។ ទោះជាយ៉ាងណា មិនមានទំនាស់ផលប្រយោជន៍នៅក្នុងសំណុំរឿងទាំងនេះទេ។

ទោះបីជានៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ សាលាឧទ្ធរណ៍ត្បូងឃ្មុំមានភាគរយទាបពាក់ព័ន្ធនឹងសិទ្ធិទទួលបានមេធាវីការពារក៏ដោយ តែចៅក្រមបានអនុវត្តល្អដោយបានអានប្រាប់ និងពន្យល់ជនជាប់ចោទអំពីសិទ្ធិរបស់ពួកគាត់ក្នុងការការពារដោយខ្លួនឯង ឬតាមរយៈមេធាវីការពារគួរឱ្យកត់សម្គាល់។ ចៅក្រមបានអានប្រាប់ និងពន្យល់អំពីសិទ្ធិនេះមានចំនួន ៨៣% នៃសំណុំរឿង(៥៤ ក្នុងចំណោម៦៥) កើនឡើងបើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៧៩,៦% និង៥៣,៨% នៅឆ្នាំ២០២៣ ពោលគឺមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

នៅក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំ បានអះអាងថា នៅក្នុងសំណុំរឿងដែលជនជាប់ចោទពីបទមជ្ឈិម ឬបទលហុ ហើយមិនមានមេធាវីការពារ គឺតុលាការពុំមានកាតព្វកិច្ចផ្តល់មេធាវីជូនឡើយ។ ប្រសិនបើជនជាប់ចោទបញ្ជាក់ថាពួកគាត់អាចការពារក្តីខ្លួនឯងបាន នោះតុលាការនឹងដំណើរការជំនុំជម្រះ បើមិនដូច្នេះទេ សវនាការនឹងត្រូវពន្យារពេល។[154]

៥.៣ សិទ្ធិមានសេរីភាព

ច្បាប់អន្តរជាតិ		ច្បាប់កម្ពុជា	
ស.ស.ស.ម	ក.អ.ស.ព.ន	រដ្ឋធម្មនុញ្ញ	ក្រមនីតិវិធីព្រហ្មទណ្ឌ
មាត្រា ៣	មាត្រា ៩ (១)	មាត្រា ៣២ និង មាត្រា ៣៨	មាត្រា ២០៣ មាត្រា មាត្រា ២០៤មាត្រា ២០៥ មាត្រា ២០៨ មាត្រា ២០៩ និងមាត្រា ២១១

[154] នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រុមការងាររបស់ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

មាត្រា ៩(១) នៃ ក.អ.ស.ព.ន ធានានូវសិទ្ធិមានសេរីភាព និងសុវត្ថិភាពរបស់ជនគ្រប់រូបពីការចាប់ខ្លួន ឬឃាត់ខ្លួនតាមអំពើចិត្ត។ ប៉ុន្តែសិទ្ធិមានសេរីភាពមិនមានលក្ខណៈជាដាច់ខាតទេ ហេតុដូចនេះ បុគ្គលម្នាក់ៗ អាចត្រូវបានដកហូតសេរីភាពដោយផ្អែកទៅលើ "មូលដ្ឋាន និងស្របទៅតាមនីតិវិធីដែលបានកំណត់ដោយច្បាប់" ការដកហូតសេរីភាពណាមួយដែលធ្វើឡើងក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ត្រូវតែស្របច្បាប់ ពោលគឺត្រូវអនុវត្តទៅតាមនីតិវិធីដែលច្បាប់កំណត់ និងដោយគោរពនីតិរដ្ឋ និងមិនត្រូវធ្វើតាមអំពើចិត្តឡើយ។[155] យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស "អំពើតាមទំនើងចិត្ត" មិនត្រឹមតែ "ខុសនឹងច្បាប់" នោះទេ តែថែមទាំង ជាការប្រព្រឹត្តិមិនសមរម្យ អយុត្តិធម៌ មិនអាចដឹងជាមុន និងមិនត្រឹមត្រូវតាមច្បាប់ ដែលនេះកង្វះនូវភាពសមហេតុផល ភាពចាំបាច់ និងសមាមាត្រផងដែរ។[156] ឧទាហរណ៍ ការឃុំខ្លួនជនណាមួយជាបណ្តោះអាសន្នត្រូវតែធ្វើឡើងទៅតាមភាពសមស្រប និងចាំបាច់នៅគ្រប់កាលៈទេសៈទាំងអស់ ម្យ៉ាងទៀត ការសម្រេចឃុំខ្លួនជាបណ្តោះអាសន្នលើបុគ្គលណាម្នាក់តាមអំពើចិត្ត ត្រូវតែមានការវាយតម្លៃឡើងវិញ ដើម្បីបញ្ជាក់ពីមូលហេតុត្រឹមត្រូវថាអាចបន្តឃុំខ្លួន។ ដោយសារតែសិទ្ធិមានសេរីភាព ជាពិសេស ការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិសន្មតទុកជាមុនថាគ្មានទោស ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធបំផុត ព្រោះថាការឃុំខ្លួនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសន្មតថាគ្មានទោស។ នេះជាមូលហេតុដែលការឃុំខ្លួនបណ្តោះអាសន្នត្រូវតែប្រើប្រាស់ជាវិធានការចុងក្រោយ នៅពេលដែលមានភាពចាំបាច់ និងក្នុងករណីពិសេសដែលបានចែងក្នុងច្បាប់តែប៉ុណ្ណោះ។

ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការពិសេសមួយ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា២០៣ បានបញ្ជាក់យ៉ាងច្បាស់ថា ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ហើយមានតែក្នុងករណី "ពិសេស" ប៉ុណ្ណោះ ដែលពួកគេអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន។[157] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនណាម្នាក់ ត្រូវតែធ្វើឡើងជាចាំបាច់ដើម្បី៖ (១) បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី។ (២) រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។ (៣) រក្សាទុកភស្តុតាង ឬតម្រុយសម្ភារៈ (៤) ធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី (៥)ការពារសន្តិសុខឱ្យជនត្រូវចោទ និង(៦) ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។[158] គួរកត់សម្គាល់ថាក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនមានការបែងចែកវិធានជាក់លាក់ក្នុងការអនុវត្តនីតីវិធីរវាងសាលាដំបូង និងសាលាឧទ្ធរណ៍ យោងតាមមាត្រា៣៩៦ បានចែងថា «វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូងត្រូវយកមកអនុវត្តចំពោះ

---

[155] ក.អ.ស.ព.ន. មាត្រា ៩(១)

[156] គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីពន្យល់ទូទៅលេខ ៣៥ (CCPR/C/GC/៣៥) វាក្យខណ្ឌ១២ https://tinyurl.com/HRC-GC-35

[157] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣

[158] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៥

សាលាឧទ្ធរណ៍» ដូចនេះមានន័យថា វិធានទាំងឡាយដែលមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺត្រូវអនុវត្តបានចំពោះតុលាការទាំងនេះ។

មាត្រា៣០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាបានផ្តល់អំណាចឱ្យតុលាការដោះលែងជនជាប់ចោទនៅគ្រប់ពេលវេលា ហើយមាត្រា៣០៥ ក៏ផ្តល់អំណាចដល់តុលាការស្រដៀងគ្នានេះដែរ។ មានបទប្បញ្ញត្តិមួយចំនួនបានផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមអាចដោះលែងជនជាប់ចោទឱ្យមានសេរីភាព។ការអនុវត្តអំណាចនេះ តុលាការត្រូវពិចារណាដោយផ្អែកលើមាត្រា២០៣ នៃក្រមនេះ ដែលចែងពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ដូចនេះ សិទ្ធិមានសេរីភាពគួរត្រូវបានលើកកម្ពស់ លើកលែងមានកំណត់ក្នុងមាត្រា២០៥ នៃក្រមនេះ។

ការលើកលែងលើការឃុំខ្លួនបណ្តោះអាសន្ន ក៏មានបញ្ជាក់នៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលថាការឃុំខ្លួនអនីតិជន គួរតែត្រូវបានប្រើប្រាស់ជាវិធានការចុងក្រោយបំផុត និងសម្រាប់រយៈពេលដ៏ខ្លីបំផុត។[159] លើសពីនេះ មាត្រា៤៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងយ៉ាងច្បាស់ថា៖ "ដើម្បីឧត្តមប្រយោជន៍របស់កុមារ ចៅក្រមត្រូវពិចារណាដោះលែងអនីតិជនដែលកំពុងជាប់ឃុំ ខណៈពេលកំពុងរង់ចាំសវនាការ"។ មាត្រានេះក៏មានចែងបន្ថែមទៀតថា "ក្នុងករណីមានការពន្យារពេលយូរ ចៅក្រមគួរតែពិចារណាឡើងវិញ ដើម្បីដោះលែងអនីតិជននោះឱ្យនៅក្រៅឃុំបណ្តោះអាសន្ន"។[160] មាត្រា៥៧ បានចែងថា ដើម្បីជា "ឧត្តមប្រយោជន៍របស់អនីតិជន" តុលាការពាក់ព័ន្ធគួរតែពិចារណាលើការដោះលែងពួកគេ ប្រសិនបើពួកគេកំពុងត្រូវបានឃុំខ្លួន។ គោលការណ៍ដ៏សំខាន់នេះ ក៏គួរតែអនុវត្តចំពោះជនជាប់ចោទដែលមិនមែនជាអនីតិជនផងដែរ ដោយយល់ឃើញពីប៉ះពាល់ធ្ងន់ធ្ងរដែលការឃុំខ្លួនអាចបង្កហេតុអវិជ្ជមានជាច្រើនលើជីវិតរបស់បុគ្គលម្នាក់ៗ ហើយក៏ប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសន្មតទុកជាមុនថាគ្មានទោសរបស់ជនជាប់ចោទផងដែរ។

គួរកត់សម្គាល់ថា ទោះបីជាមានបទប្បញ្ញត្តិច្បាប់ដែលបញ្ជាក់ពីការលើកលែងលើការឃុំខ្លួនជនជាប់ចោទក៏ដោយ មិនមានសំណុំរឿងណាមួយនៅឆ្នាំ២០២៥ ដែលបង្ហាញថា ចៅក្រមបានបង្គាប់ឱ្យជនជាប់ចោទណាម្នាក់ស្ថិតនៅក្រៅឃុំឡើយ នៅពេលដែលគាត់បានចូលរួមក្នុងដំណើរនីតិវិធីសវនាការរបស់សាលាឧទ្ធរណ៍ និងកំពុងរង់ចាំការប្រកាសសាលដីការបស់តុលាការ។

បើទោះបីជាមានបទប្បញ្ញត្តិច្បាប់ដែលបញ្ជាក់ពីការលើកលែងលើការឃុំខ្លួនក៏ដោយ ក៏លទ្ធផលបង្ហាញថា ការឃុំខ្លួននៅតែបន្តត្រូវបានប្រើប្រាស់ជាវិធានអនុវត្តទូទៅ ពោលគឺមិនមែនជាករណីលើកលែងនោះទេ។ ការណ៍នេះ គឺស្របពេលដែលមានការទទួលស្គាល់ជាបន្តបន្ទាប់ថាចំនួនជនជាប់ឃុំក្នុងពន្ធនាគារនៅប្រទេសកម្ពុជាមានអត្រាដ៏ខ្ពស់គួរឱ្យព្រួយបារម្ភ។[161] នៅខែកក្កដា ឆ្នាំ២០២៣ របាយការណ៍សង្ខេបនៃពន្ធនាគារពិភព

---

[159] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ឆ្នាំ២០១៦) មាត្រា ៥ https://tinyurl.com/Law-on-Juvenile-Justice

[160] ដូចខាងលើ មាត្រា ៤៥

[161] ខេមបូចា "បច្ចុប្បន្ន ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទីពីរក្នុងចំណោមប្រទេសមានការចង្អៀតណែនក្នុងពន្ធនាគារ និងមានការអំពាវនាវឱ្យមានកំណែទម្រង់" ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៥ https://tinyurl.com/cmyn4dsc

លោកបានវាយតម្លៃថា កម្ពុជាជាប់ចំណាត់ថ្នាក់ទីពីរក្នុងចំណោមប្រទេសមានអត្រាចង្អៀតណែនក្នុងពន្ធនាគារខ្ពស់បំផុតនៅលើពិភពលោក ដោយអត្រាប៉ាន់ប្រមាណ គឺលើសពី ៤០០% ទៅទៀត។[162] នៅក្នុងរបាយការណ៍ឆ្នាំ២០២៤-២០២៥ ស្តីពីប្រទេសកម្ពុជា ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានប៉ាន់ប្រមាណថា ចំនួនជនជាប់ចោទដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នមានប្រមាណ ៣០% នៃចំនួនជនជាប់ឃុំក្នុងពន្ធនាគារ។[163]

នៅឆ្នាំ២០២៥ ចំនួនជនជាប់ចោទដែលស្ថិតក្នុងការឃុំខ្លួនមានការកើនឡើងគួរកត់សម្គាល់។ នៅឆ្នាំ ២០២៤ មានចំនួនកើនឡើងដល់ ៨៥% ដែលជាចំនួនកើនពី ៧៥% នៅឆ្នាំ២០២៣ និង៧២,៦% នៅឆ្នាំ ២០២២ រីឯនៅឆ្នាំ២០២៥ ចំនួននេះបានកើនឡើងម្តងទៀតដល់ ៨៧% (៤៩៩ នាក់ ក្នុងចំណោម ៥៧៣ នាក់)។ រយៈពេលបួនឆ្នាំជាប់ៗគ្នា ដែលអត្រាកើនខ្ពស់នៃចំនួនជនជាប់ចោទដែលស្ថិតក្នុងការឃុំខ្លួនដែលនេះអាចមានផលប៉ះពាល់យ៉ាងខ្លាំង ជាពិសេសធ្វើឱ្យបញ្ហានៃការចង្អៀតណែនក្នុងពន្ធនាគារនៅកម្ពុជាកាន់តែធ្ងន់ធ្ងរ ក៏ដូចជាអាចប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សម្រាប់ជនជាប់ចោទដែលស្ថិតក្នុងការឃុំខ្លួនរងចាំយុត្តិធម៌ ជាពិសេសអាចប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរបស់បុគ្គលម្នាក់ៗ។

គួរឱ្យកត់សម្គាល់បន្ថែមទៀតនោះគឺថា បើទោះបីជាមានបទប្បញ្ញត្តិជាក់លាក់នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីលើកកម្ពស់សិទ្ធិមានសេរីភាពរបស់ជនជាប់ចោទជាអនីតិជន ជនជាប់ចោទជាអនីតិជនចំនួន ៨៩% (៨ នាក់ ក្នុងចំណោម ៩ នាក់) បានសង្កេតនៅឆ្នាំ២០២៥ ត្រូវបានឃុំខ្លួន។ ការណ៍នេះគឺមិនបានអនុវត្តនូវបទប្បញ្ញត្តិនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលចែងថាការឃុំខ្លួន គួរតែជាករណីលើកលែង មិនមែនជាវិធានអនុវត្តទូទៅនោះទេ។ គួរកត់សម្គាល់ថា ពាក់ព័ន្ធនឹងសិទ្ធិមានសេរីភាពសម្រាប់ជនជាប់ចោទជាអនីតិជន មិនមានការប្រែប្រួលទេ បើធៀបនឹងឆ្នាំ២០២៤ ហើយជាលទ្ធផលអាចនាំឱ្យប៉ះពាល់ដល់ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពួកគេ។

គួរកត់សម្គាល់ផងដែរថា មានការថយចុះនូវចំនួនជនជាប់ចោទ ដែលត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារនៅសាលាឧទ្ធរណ៍គោលដៅទាំងបួន។ នៅឆ្នាំ២០២៥ មានជនជាប់ចោទចំនួន ៨៧% ដែលត្រូវបាន

លីកាដូ "វិបត្តិកំណើនជនជាប់ឃុំក្នុងពន្ធនាគារនៅកម្ពុជា៖ ភាពចង្អៀតណែន និងតម្រូវការកំណែទម្រង់ប្រព័ន្ធពន្ធនាគារ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ https://tinyurl.com/LICADHO-prison-overcrowding

[162] របាយការណ៍សង្ខេបនៃពន្ធនាគារក្នុងពិភពលោក, "កម្រិតភាពចង្អៀតណែនមានពីខ្ពស់បំផុត មកទាបបំផុត (ដោយផ្អែកលើកំណើនជនជាប់ឃុំក្នុងពន្ធនាគារផ្លូវការ)" https://tinyurl.com/yhbftpuu

[163] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អគ្គលេខាធិការស្តីពីតួនាទីនិងសមិទ្ធផលនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយរដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស" (A/HRC/៦០/៨៧), https://docs.un.org/en/A/HRC/60/87 §68 ទ៦៨-៧៤។

តុលាការរកឃើញថាមានពិរុទ្ធភាព និងតម្រូវឱ្យជាប់ពន្ធនាគារ (៣៩ នាក់ ក្នុងចំណោម ៤៥ នាក់)។ ទោះបីបែបនេះក្តី តួលេខនេះថយចុះពីចំនួន ៩៤% នៅឆ្នាំ២០២៤។ ទោះជាយ៉ាងណា គួរកត់សម្គាល់ថាមិនមានសំណុំរឿងណាមួយដែលសាលាឧទ្ធរណ៍គោលដៅទាំងបួនបានប្រើប្រាស់នូវការប្រកាសទោសជំនួសនោះទេ។

សាលាឧទ្ធរណ៍ភ្នំពេញ

នៅឆ្នាំ២០២៥ មានចំនួន ៨៧,៥% នៃជនជាប់ចោទ ត្រូវបានជាប់ឃុំ (២៩៥ នាក់ ក្នុងចំណោម ៣៣៧ នាក់) ចំនួននេះគឺស្រដៀងគ្នានឹងឆ្នាំ២០២៤ ដែរ គឺ៨៧%។ ក្នុងចំណោមជនជាប់ចោទដែលត្រូវបានឃុំខ្លួនមានចំនួន ៤៨% (១១ នាក់ ក្នុងចំណោម ២៣ នាក់) ជាប់ឃុំរយៈពេលតិចជាងមួយឆ្នាំ ចំណែក ៣៥% (៨ នាក់ ក្នុងចំណោម ២៣ នាក់) ត្រូវជាប់ឃុំពីមួយឆ្នាំ ដល់ពីរឆ្នាំ។ គួរកត់សម្គាល់ថាចំនួន ១៧% (៤ នាក់ ក្នុងចំណោម ២៣ នាក់) នៃជនជាប់ចោទបានជាប់ឃុំរយៈពេលពីរទៅបីឆ្នាំ មុនពេលចាប់ផ្តើមសវនាការនៅសាលាឧទ្ធរណ៍។ គួរឱ្យកត់សម្គាល់ជាវិជ្ជមាន ក្នុងចំណោមសំណុំរឿងដែលត្រូវបានសង្កេត មិនមានជនជាប់ចោទណាម្នាក់ជាប់ឃុំរយៈពេលលើសពីបីឆ្នាំឡើយ បើធៀបនឹងឆ្នាំ២០២៤ មានចំនួនមួយករណីនៅសាលាឧទ្ធរណ៍ភ្នំពេញ។ ជារួម តួលេខនៅឆ្នាំ២០២៥ បង្ហាញពីការថយចុះ បើធៀបនឹងឆ្នាំមុន។

សាលាឧទ្ធរណ៍បាត់ដំបង

មានការកើនឡើងចំនួននៃជនជាប់ចោទដែលបានជាប់ឃុំនៅឆ្នាំ២០២៥ មានចំនួន ៨៩% នៃជនជាប់ចោទត្រូវបានជាប់ឃុំ (៧៣ នាក់ ក្នុងចំណោម ៨២ នាក់) តួលេខនេះកើនឡើងបន្តិច បើធៀបនឹងឆ្នាំ២០២៤ មាន ៨៦% នៅឆ្នាំ២០២៣ មាន ៧៣,៩% និង៧២% នៅឆ្នាំ២០២២។ ចំនួននេះមានការកើនឡើងជាលំដាប់ដែលហាក់ដូចជាមិនមានសង្គតិភាពជាមួយបទប្បញ្ញត្តិថាជាគោលការណ៍ គឺសេរីភាព។ ការឃុំខ្លួនអាចប៉ះពាល់ដល់សិទ្ធិទទួលបានដល់ការសន្មតជាមុនថាគ្មានទោស។ នៅសាលាឧទ្ធរណ៍បាត់ដំបង មានភាពប្រសើរគួរកត់សម្គាល់ចំពោះរយៈពេលនៃការឃុំខ្លួន បើធៀបនឹងឆ្នាំ២០២៤។ មានចំនួន ៨០% បានជាប់ឃុំខ្លួនមានរយៈពេលតិចជាងមួយឆ្នាំ (៤ នាក់ ក្នុងចំណោម ៥ នាក់) ខណៈដែលម្នាក់ត្រូវបានជាប់ឃុំរយៈពេលពីមួយឆ្នាំទៅពីរឆ្នាំ បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៦៣%។

ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា ប្រសិនបើសាលាដំបូងបានផ្តន្ទាទោសបុគ្គលណាម្នាក់ឱ្យជាប់ពន្ធនាគារ នោះសាលាឧទ្ធរណ៍នឹងរក្សាការឃុំខ្លួនបន្តទៀត។[164] ទោះជាយ៉ាងណា សាលាឧទ្ធរណ៍ក៏អាចនឹងធ្វើការវាយតម្លៃផ្ទាល់ខ្លួនពាក់ព័ន្ធនឹងលទ្ធភាពនៃការដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំ នៅពេលដែលគាត់ចូលរួមដំណើរការសវនាការ និងកំពុងរង់ចាំការប្រកាសសាលដីការលើសំណុំរឿងរបស់ខ្លួន។ គួរកត់សម្គាល់ផងដែរថា សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរបស់បុគ្គលណាម្នាក់ ត្រូវអនុវត្តសម្រាប់ដំណើរការជំនុំជម្រះទាំងមូល តាំងពីការស៊ើបអង្កេតសំណុំរឿងព្រហ្ម

[164] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាអំពីរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន ។

ទណ្ឌ និងដំណើរការជំនុំជម្រះ រហូតដល់បណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ។[165] ដូច្នេះហើយ សាលាឧទ្ធរណ៍អាចដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំបាន នៅពេលគាត់ចូលរួមក្នុងដំណើរការសវនាការ និងកំពុងរង់ចាំការប្រកាសសាលដីកាលើសំណុំរឿងរបស់ខ្លួន។

សាលាឧទ្ធរណ៍ព្រះសីហនុ

មានការថយចុះជាវិជ្ជមាននូវចំនួនជនជាប់ចោទដែលបានជាប់ឃុំនៅឆ្នាំ២០២៤ តែចំនួននេះបានកើនឡើងនៅឆ្នាំ២០២៥។ មានចំនួន ៨៦% នៃជនជាប់ចោទត្រូវបានឃុំខ្លួន (១៩ នាក់ ក្នុងចំណោម ២២ នាក់) នេះជាចំនួនកើនឡើង បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ៧០% ។ នេះបង្ហាញពីការកើនឡើងវិញ បើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨២%។ ទោះជាយ៉ាងណា ចំណុចមួយដែលគួរកត់សម្គាល់នោះ គឺថាមានចំនួន ១០០% នៃជនជាប់ចោទដែលត្រូវបានជាប់ឃុំខ្លួនមានរយៈពេលតិចជាងមួយឆ្នាំ។

សាលាឧទ្ធរណ៍ត្បូងឃ្មុំ

រយៈពេលពីរឆ្នាំជាប់ៗគ្នា ចំនួនជនជាប់ចោទដែលត្រូវបានឃុំខ្លួនបានកើនឡើងបន្តិច។ នៅឆ្នាំ២០២៥ មានចំនួន ៨៥% នៃជនជាប់ចោទត្រូវបានឃុំខ្លួន (១១២ នាក់ ក្នុងចំណោម ១៣២ នាក់) កើនឡើង បើធៀបនឹងឆ្នាំ២០២៤ ចំនួន ៨២%។ រយៈពេលនៃការឃុំខ្លួនមានចំនួន ៥០% នៃជនជាប់ចោទបានជាប់ឃុំរយៈពេលតិចជាងមួយឆ្នាំ (៥ នាក់ ក្នុងចំណោម ១០ នាក់) ចំណែកជនជាប់ចោទផ្សេងទៀតជាប់ឃុំពីមួយឆ្នាំដល់ពីរឆ្នាំ។

តារាងទី ២៧៖ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដល់ថ្ងៃសវនាការរបស់សាលាឧទ្ធរណ៍នៅតាមតុលាការគោលដៅ[166]

រយៈពេល	សាលាឧទ្ធរណ៍ភ្នំពេញ	សាលាឧទ្ធរណ៍បាត់ដំបង	សាលាឧទ្ធរណ៍ព្រះសីហនុ	សាលាឧទ្ធរណ៍ត្បូងឃ្មុំ	សរុបជានាក់
តិចជាង ១ ឆ្នាំ	១១	៤	១	៥	២១
១ ដល់ ២ ឆ្នាំ	៨	១	០	៥	១៤
លើស ២ ឆ្នាំ ដល់ ៣ ឆ្នាំ	៤	០	០	០	៤
លើស ៣ ឆ្នាំ	០	០	០	០	០
មិនដឹងចិរវេលាឃុំខ្លួន	២៧២	៦៨	១៨	១០២	៤៦០

[165] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៃ "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ផ្នែកទី ១) ជំពូក ៦ ទំព័រ ២១៩ https://tinyurl.com/35w2rrm6

[166] ទិន្នន័យនេះគឺផ្អែកលើចំនួនជនជាប់ចោទដែលត្រូវឃុំខ្លួន (៤៩៩ នាក់) នៅក្នុងចំណោមសំណុំរឿងដែលត្រូវបានសង្កេតនៅឆ្នាំ ២០២៥។

មិនជាប់ឃុំ	៤២	៩	៣	២០	៧៤
សរុប	៣៣៧	៨២	២២	១៣២	៥៧៣

៥.៤ សិទ្ធិបដ្ឋាញ្ញតស្តុតាង

ច្បាប់អន្តរជាតិ	ច្បាប់កម្ពុជា	
ក.អ.ស.ព.ន	**ក្រមនីតិវិធីព្រហ្មទណ្ឌ**	**ច្បាប់ស្តីពីយុត្តិធម៌អនីតិជន**
មាត្រា ១៤(៣)(ង)	មាត្រា ១៥៣ មាត្រា ១៥៤ មាត្រា ២៩៨ មាត្រា ៣២១ មាត្រា ៣២២ មាត្រា ៣២៤ មាត្រា ៣២៦ មាត្រា ៣២៨ និង មាត្រា ៣៩៤	មាត្រា ៦

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការ ត្រូវតែផ្អែកទាំងស្រុងលើកស្តុតាងដែលបានបង្ហាញនៅក្នុងសវនាការ។ ដូច្នេះភាគីនីមួយៗត្រូវមានលទ្ធភាពបង្ហាញកស្តុតាង និងហៅសាក្សីរបស់ខ្លួន ដើម្បីសាកសួរដេញដោលលើកស្តុតាង និងសាក្សីដែលបានបង្ហាញដោយភាគីម្ខាងទៀត និងតតាំងនឹងកស្តុតាងដែលពួកគេមិនទទួលយក។[167] ចំណុចនេះជាការចាំបាច់ណាស់ ដើម្បីធានាបាននូវសិទ្ធិស្មើគ្នារវាងភាគីពាក់ព័ន្ធ និងជាគោលការណ៍មូលដ្ឋានដែលតម្រូវឱ្យមានការប្រព្រឹត្តិចំពោះភាគីទាំងអស់ ក្នុងរបៀបដែលធានានូវភាពស្មើគ្នាគ្រប់ដំណាក់កាលនៃការជំនុំជម្រះ ហើយគ្មានភាគីណាមួយត្រូវបាត់បង់ឱកាសក្នុងការបង្ហាញរឿងក្តីរបស់ខ្លួនឡើយ។ យោងតាម ក.អ.ស.ព.ន ការកំណត់បទចោទព្រហ្មទណ្ឌណាមួយទៅលើបុគ្គលណាម្នាក់ បុគ្គលនោះមានសិទ្ធិ "សាកសួរ ឬឱ្យគេសាកសួរ" សាក្សីដែលដាក់បន្ទុកលើខ្លួន និងសិទ្ធិស្នើសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុកដែរ។[168] ការផ្តល់កស្តុតាងតាមការថ្លែងជាលាយលក្ខណ៍អក្សរ (ឧ. មិននៅក្នុងអំឡុងពេលសវនាការ) មិនប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទទេ ប្រសិនបើពួកគេបានតទល់ និងសាកសួរសាក្សីនៅពេលដែលសាក្សីនោះបានផ្តល់សក្ខីកម្ម ឬនៅដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ។[169]

---

[167] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅលេខ ៣២ វាក្យខណ្ឌ ១៣, ៣៩។ សម្រាប់ព័ត៌មានលម្អិតស្តីពីសិទ្ធិនេះ សូមមើលកម្រងមេរៀនរបស់ ម.ស.ម.ក "សិទ្ធិបង្ហាញកស្តុតាង (សិទ្ធិក្នុងការហៅ និងសាកសួរសាក្សី)" (ខែកញ្ញា ឆ្នាំ២០២២) https://tinyurl.com/zv93nahs

[168] ក.អ.ស.ព.ន. មាត្រា ១៤(៣)(ង)

[169] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស, Mirilashvili *ទល់នឹង ប្រទេសរុស្ស៊ី* (ថ្ងៃទី ១១ ធ្នូ ២០០៨), បណ្តឹងលេង លេខ ៦២៩១/០៤ វាក្យខណ្ឌ ១៦៣ https://tinyurl.com/4kktr8yr;

តុលាការសិទ្ធិមនុស្សអឺរ៉ុប Asch ទល់នឹងប្រទេសអូទ្រីស (ថ្ងៃ២៦ ខែមេសា ឆ្នាំ១៩៩១) សេរី A លេខ ២០៣ វាក្យខណ្ឌ ២៨ https://tinyurl.com/bdfpm2ah;

តុលាការសិទ្ធិមនុស្សអឺរ៉ុប Isgrò *ទល់នឹងប្រទេសអ៊ីតាលី* (ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩១) សេរី A លេខ ១៩៤-A វាក្យខណ្ឌ ៣៤ https://tinyurl.com/39mz7s7h;

គួរឱ្យកត់សម្គាល់ជាវិជ្ជមាន រយៈពេលបីឆ្នាំជាប់ៗគ្នា ពុំមានសំណុំរឿងណាមួយបង្ហាញថាជនជាប់ចោទមិនទទួលបានឱកាសឱ្យហៅសាក្សីនោះទេ។ លើសពីនេះ ក្នុងរបាយការណ៍បីឆ្នាំជាប់ៗគ្នា ក៏មិនមានការចង្អុលបង្ហាញដែរថា មានភាគីណាមួយមិនទទួលបានឱកាសក្នុងការបង្ហាញកស្តុតាង ឬពិនិត្យមើលសំណុំរឿងមុនពេលសវនាការ ឬបង្ហាញថាចៅក្រមបានចេញសាលដីកាដោយផ្អែកលើកស្តុតាងដែលមិនមាននៅក្នុងសំណុំរឿង ឬមិនបានបង្ហាញនៅក្នុងសវនាការទេ។ ទោះជាបែបនេះក្តី ក៏សិទ្ធិបង្ហាញកស្តុតាងនៅតែមិនទាន់ត្រូវបានគោរពយ៉ាងពេញលេញនៅឡើយ ទោះបីជាមានភាពប្រសើរឡើងគួរកត់សម្គាល់ក្តី ពាក់ព័ន្ធនឹងសិទ្ធិបង្ហាញកស្តុតាងក៏ពិតមែន សិទ្ធិទាំងនេះនៅតែមិនទាន់ទទួលបានការគោរពយ៉ាងពេញលេញនៅឡើយទេ នៅសាលាឧទ្ធរណ៍គោលដៅទាំងបួនដោយសារហេតុផលចម្បងចំនួនពីរ៖ កង្វះការបង្ហាញកស្តុតាងជាកោសលវិច័យ ឬកស្តុតាងវេជ្ជសាស្ត្រ និងសាក្សីដែលត្រូវបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការមុនពេលត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។

ត្រង់ចំណុចទីមួយ ជាការសំខាន់ណាស់ដែលកស្តុតាងសំអាងណាមួយមានភាពត្រឹមត្រូវ និងអាចទុកចិត្តបានសម្រាប់ដំណើរការជំនុំជម្រះ "តម្លៃពេញលេញនៃកស្តុតាង"។ កស្តុតាងដែលត្រូវបានបង្ហាញ និងពិនិត្យដែលមានទាំងគុណភាព និងបរិមាណ មានសារៈសំខាន់ណាស់ ដើម្បីធានាថាបន្ទុកកស្តុតាងហួសពីរមិតិសង្ស័យ។ ក្រៅពីកស្តុតាងជាឯកសារ សាក្សីផ្ទាល់ ចៅក្រម និងព្រះរាជអាជ្ញា គួរតែស្វែងរក និងពិនិត្យមើលយ៉ាងសកម្មលើប្រភេទកស្តុតាងផ្សេងទៀតដែលពាក់ព័ន្ធ ដូចជា កស្តុតាងវេជ្ជសាស្ត្រ និងកស្តុតាងកោសលវិច័យ។ មិនមានភាគីណាមួយបានបានបង្ហាញនូវកស្តុតាងជាកោសលវិច័យ ឬវេជ្ជសាស្ត្រ ក្នុងចំណោមសំណុំរឿងចំនួន ៤២២ នោះទេ។ រយៈពេលពីរឆ្នាំជាប់ៗគ្នាដែលករណីនេះមានការថយចុះ បន្ទាប់ពីមានភាពប្រសើរខ្លះនៅឆ្នាំ២០២៣ មានការបង្ហាញកស្តុតាងបែបនេះ ០,១៣%។ ទោះបីជាជាភាគរយទាបក៏ដោយ វាបង្ហាញពីវឌ្ឍនភាពដែរ បើធៀបនឹងឆ្នាំ២០២៤ និងឆ្នាំ២០២៥។ លើសពីនេះ សាក្សីត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មបានតែ ៩% ប៉ុណ្ណោះ (៣៨ ក្នុងចំណោម ៤២២ សំណុំរឿង) ដែលគួរលេខនេះថយចុះ បើធៀបនឹងឆ្នាំ២០២៤ មានចំនួន ១១,៩%។ ទោះជាយ៉ាងនេះក្តី តួលេខនេះខ្ពស់ជាងឆ្នាំ២០២៣ មានចំនួន ៧%។

ពាក់ព័ន្ធនឹងចំណុចទីពីរ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា សាក្សី និងអ្នកជំនាញដែលតុលាការកោះហៅត្រូវរង់ចាំនៅក្នុងបន្ទប់ដាច់ដោយឡែកពីបន្ទប់សវនាការ ដែលគាត់មិនត្រូវបានអនុញ្ញាតឱ្យមើលឃើញ ឬស្តាប់ឮនូវអ្វីដែលកំពុងកើតឡើងនៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មនោះទេ។ ចំណែកឯសាក្សីដែលមិនត្រូវបានកោះហៅជាផ្លូវការអាចចូលក្នុងបន្ទប់សវនាការតាំងពីដំបូងបាន តែត្រូវឱ្យនៅក្នុងបន្ទប់រង់ចាំ ប្រសិនបើប្រធានសវនាការសម្រេចថា នឹងស្តាប់ចម្លើយរបស់គាត់ នៅពេលដែលមានការស្នើសុំពីភាគីណាមួយប៉ុណ្ណោះ។[170]

តុលាការសិទ្ធិមនុស្សអឺរ៉ុប Kostovski ទល់នឹងប្រទេសហូឡង់ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩) សេរី A លេខ ១៦៦ វាក្យខណ្ឌ ៤១ https://tinyurl.com/2e2pbxsh

[170] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣២៤។

ចំនួន ៦១% នៃសំណុំរឿងដែលសាក្សីត្រូវបានកោះហៅ (២៣ ក្នុងចំណោម ៣៨ សំណុំរឿង) សាក្សីទាំងនោះមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្ម។ តួលេខនេះកើនឡើងនៅឆ្នាំ២០២៤ សាក្សីមានវត្តមានក្នុងបន្ទប់សវនាការចំនួន ៥៧% និងនៅឆ្នាំ២០២៣ មានចំនួន ៣៦,៨%។ ភាគរយកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំជាចំណុចត្រូវយកចិត្តទុកដាក់ ដោយហេតុថាសក្ខីកម្មរបស់សាក្សីអាចរងឥទ្ធិពល ឬមានការប្រែប្រួលដោយដំណើរការដែលគាត់បានឃើញនៅក្នុងបន្ទប់សវនាការ មុនពេលគាត់ផ្តល់សក្ខីកម្មរបស់ខ្លួន។

នៅសាលាឧទ្ធរណ៍ភ្នំពេញ មានភាពប្រសើរគួរសម្គាល់នូវវត្តមានរបស់សាក្សីក្នុងបន្ទប់សវនាការមុនផ្តល់សក្ខីកម្មថយចុះនៅឆ្នាំ២០២៥ ចំណែកសាលាឧទ្ធរណ៍ព្រះសីហនុ មិនមានសាក្សីមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងដែលត្រូវបានសង្កេតនោះទេ។ នៅសាលាឧទ្ធរណ៍ភ្នំពេញ ក្នុងចំណោមសាក្សីដែលត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម សាក្សីនោះមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មគឺមាន ៣៣% (២ ក្នុងចំណោម ៦ សំណុំរឿង) ដែលគួលេខនេះជាការថយចុះពីចំនួន ៤៦% នៅឆ្នាំ២០២៤។ ក្នុងការពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ភ្នំពេញបានបញ្ជាក់ថា សាក្សីត្រូវបានអនុញ្ញាតឱ្យរងចាំនៅក្នុងបន្ទប់រងចាំ ក្រោយពេលដែលគាត់បានផ្តល់សក្ខីកម្មរបស់ខ្លួនរួចរាល់។ ក្នុងសំណុំរឿងមួយចំនួន សាក្សីមានវត្តមានដោយសារតែគាត់ត្រូវបានអញ្ជើញដោយភាគីពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី សាក្សីថ្មីតម្រូវឱ្យធ្វើការស្បថ ហើយត្រូវរង់ចាំនៅខាងក្រៅបន្ទប់សវនាការរហូតដល់ពេលដែលគាត់ត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្ម។[171]

សាក្សីមានវត្តមានក្នុងបន្ទប់សវនាការមុនពេលផ្តល់សាក្ខីកម្មនៅសាលាឧទ្ធរណ៍បាត់ដំបងមានការកើនឡើងពីចំនួន ៧១% នៅឆ្នាំ២០២៣ ដល់ ១០០% នៅឆ្នាំ២០២៥ (១២ ក្នុងចំណោម ១២ សំណុំរឿង)។ ក្នុងអំឡុងពេលពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា នៅពេលដែលជនជាប់ចោទបានសារភាពអំពីពិរុទ្ធភាព ចៅក្រមមិនបន្តសួរចម្លើយសាក្សីទៀតទេ។[172] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បាត់ដំបងបានបញ្ជាក់ថា សាក្សីដែលមិនត្រូវបានបំបែកឱ្យទៅបន្ទប់រង់ចាំនោះ មានដូចជា សាក្សីជាទណ្ឌិតក្នុងសំណុំរឿងជាមួយគ្នា និងសាក្សីដែលមានចម្លើយដូចគ្នា ក្រៅពីនោះ សាក្សីត្រូវបានបំបែកឱ្យទៅបន្ទប់រងចាំ។[173] សាលាឧទ្ធរណ៍ត្បូងឃ្មុំបានរក្សាកំណត់ត្រាដដែលដូចទៅនឹងឆ្នាំ២០២៤ សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្មមានចំនួន ៤៥% (៩ ក្នុងចំណោម ២០ សំណុំរឿង)។ ទោះបីជា មិនមានសាក្សីត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅសាលាឧទ្ធរណ៍ព្រះ

---

[171] នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[172] នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍បាត់ដំបង និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន ។

[173] នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ភ្នំពេញ និងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

សីហនុក៏ដោយ ក៏គួរកត់សម្គាល់ដែរថា នៅអំឡុងពេលពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍បានឱ្យដឹងថា ចំពោះសំណុំរឿងដែលកំណត់ថា "មិនមានភាពស្មុគស្មាញ" សាក្សីត្រូវបានអនុញ្ញាតឱ្យនៅក្នុងបន្ទប់សវនាការមុនពេលផ្តល់សក្ខីកម្ម។[174] លើសពីនេះ បើយោងតាមការអះអាងរបស់តំណាងតុលាការថា ចៅក្រមផ្តោតសំខាន់លើអង្គហេតុនៃសំណុំរឿងជាជាងសក្ខីកម្មរបស់សាក្សីនៅពេលធ្វើសេចក្តីសម្រេច។[175] ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយ ម.ស.ម.ក តំណាងសាលាឧទ្ធរណ៍ត្បូងឃ្មុំបានលើកឡើងថា ចៅក្រមអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមកបំភ្លឺលើសំណុំរឿងដែលខ្លួនបានស៊ើបអង្កេតហាន:ជាសាក្សីស្ថិតក្នុងបន្ទប់សវនាការ តែបើសាក្សី ទាំងជាក់បន្ទុក និងដោះបន្ទុក ចៅក្រមតម្រូវឱ្យស្ថិតនៅបន្ទប់រងចាំ មិនអនុញ្ញាតឱ្យស្ថិតក្នុងបន្ទប់សវនាការអំឡុងពេលសួរដេញដោលនោះទេ។[176] គួរកត់សម្គាល់ថាភស្តុតាង និងសក្ខីកម្មរបស់សាក្សី គឺជាធាតុដ៏សំខាន់ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងជួយដល់ចៅក្រមពិចារណា ឬច្រានចោលអង្គហេតុដែលភាគីទាំងសងខាងបានបង្ហាញ ដើម្បីឈានដល់សេចក្តីសម្រេចមួយ។ ដូច្នេះ ការពិចារណាលើសក្ខីកម្មរបស់សាក្សី និងភស្តុតាងផ្សេងៗទៀតទាំងអស់ គឺពិតជាមានសារៈសំខាន់ណាស់ ព្រោះបើមិនដូច្នេះទេ ដំណើរការនីតិវិធីទាំងមូល និងសាលដីកាអាចនឹងរងផលប៉ះពាល់។

ជាចុងក្រោយ មេធាវីការពារមានចំនួនទាបនៅសាលាឧទ្ធរណ៍គោលដៅទាំងបួន ដូចដែលបានបញ្ជាក់នៅក្នុងចំណុច ៥.២ នៃរបាយការណ៍នេះ បាននាំឱ្យមានចម្ងល់អំពីសមត្ថភាពរបស់ជនជាប់ចោទដែលមិនទទួលបានអត្ថប្រយោជន៍ពីការពិគ្រោះយោបល់ផ្នែកច្បាប់ និងការយល់ដឹងអំពីដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងការអនុវត្តសិទ្ធិរបស់គាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការហៅសាក្សី និងសាកសួរសាក្សីរបស់ភាគីផ្សេងទៀត។ ចំណុចនេះអាចចោទសួរអំពីគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ ដែលជាគោលការណ៍គ្រឹះមួយសម្រាប់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មូលហេតុមួយទៀតដែលជាការកត់សម្គាល់ គឺលទ្ធភាពរបស់ជនជាប់ចោទមិនមានមេធាវីការពារ មិនអាចទទួលបាននូវសំណុំរឿងរបស់ខ្លួនមកពិនិត្យផងដែរ។ ទោះបីជា គ្មានសំណុំរឿងណាមួយដែលបានសង្កេតក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ បានបង្ហាញថាមិនមានការលើកឡើងពីបញ្ហាទាក់ទងនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការរៀបចំការពារក្តីក៏ដោយ យោងតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យមេធាវីការពារពិនិត្យមើលសំណុំរឿង និងថតចម្លងឯកសារសំណុំរឿង តែមិនបានផ្តល់សិទ្ធិដូចគ្នាដល់ជនជាប់ចោទដែលមិនមានមេធាវីការពារនោះ

---

[174] នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ព្រះសីហនុ និងមហាអយ្យការអមសាលាឧទ្ធរណ៍ព្រះសីហនុ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

[175] ដូចខាងលើ

[176] នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ ក្រុមការងារ ម.ស.ម.ក បានជួបប្រជុំជាមួយសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដើម្បីពិភាក្សាលើរបកគំហើញពីការសង្កេតសវនាការរបស់ខ្លួន។

ឡើយ។[177] ប្រការនេះអាចបង្កជាឧបសគ្គដល់ជនជាប់ចោទ ក្នុងការទទួលបានការពិនិត្យមើលសំណុំរឿង និងកស្តុតាងទាំងឡាយដែលប្រឆាំងនឹងខ្លួន ព្រមទាំងមិនអាចរៀបចំការពារដោយខ្លួនឯងបានត្រឹមត្រូវ និងគ្រប់គ្រាន់នោះទេ។

៥.៥ សិទ្ធិកុមារទំនាស់នឹងច្បាប់

ច្បាប់អន្តរជាតិ		ច្បាប់កម្ពុជា			
ក.អ.ស.ព.ន	អ.ស.ក	រដ្ឋធម្មនុញ្ញ	ក្រមនីតិវិធីព្រហ្មទណ្ឌ	ក្រមព្រហ្មទណ្ឌ	ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
មាត្រា ១៤ (១)	មាត្រា ៣៧ និង ៤០	មាត្រា ៣១ និង ៤៨	មាត្រា ១០០ និង ២១២	មាត្រា ៣៩ និង ៤០	មាត្រា ៥, ៦, ៣៩, ៤៧, ៤៨, ៤៩, ៥៤, ៥៧ និង ៨២

ច្បាប់អន្តរជាតិធានាចំពោះសិទ្ធិរបស់កុមារ - ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ដែលបានរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវអនុវត្តដូចគ្នានឹងមនុស្សពេញវ័យដែរ។ ប៉ុន្តែកុមារត្រូវទទួលបាននូវកិច្ចការពារពិសេសផងដែរ ដោយផ្អែកលើអាយុភាពដឹងក្តី និងការអភិវឌ្ឍផ្នែកបញ្ញាស្មារតី។[178]

បទប្បញ្ញត្តិជាក់លាក់សម្រាប់ការប្រព្រឹត្តិលើកុមារក្នុងដំណើរការនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌបានចែងក្នុង ក.អ.ស.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ (“អ.ស.ក.”) ដែលបានចូលជាធរមាននៅប្រទេសកម្ពុជានៅឆ្នាំ ១៩៩២ ។ ការធានាទាំងនេះពង្រឹងបន្ថែមទៀតលើគោលការណ៍ណែនាំ និងបទដ្ឋានអន្តរជាតិជាច្រើន រួមមានវិធានអប្បរមានៃបទដ្ឋានរបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងយុត្តិធម៌កុមារ (វិធានប៉េកាំង)ឬវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការកុមារពីការដកហូតសេរីភាព។ យោងតាមខ្លឹមសារនេះ រដ្ឋតម្រូវឱ្យបង្កើតច្បាប់ នីតិវិធីផ្សេងៗ អាជ្ញាធរទទួលខុសត្រូវ និងស្ថាប័ន ដែលអនុវត្តចំពោះកុមារដែលទទួលស្គាល់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ។ ជាពិសេស រដ្ឋត្រូវកំណត់អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលកុមារត្រូវសន្មតថាមិនមានសមត្ថភាពក្នុងការយល់ដឹងពីច្បាប់ព្រហ្មទណ្ឌ។[179]

កុមារដែលមានអាយុអប្បបរមា ឬលើសពីអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ ប៉ុន្តែក្រោមអាយុ ១៨ ឆ្នាំ អាចត្រូវបានចោទប្រកាន់ជាផ្លូវការ និងទទួលបាននីតិវិធីយុត្តិធម៌កុមារស្របតាម អ.ស.ក។[180]

---

[177] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៤៥, ២៥៤, ៣០៤, ៣១៩, ៣៩១, ៤២៨។

[178] អ.ស.ក មាត្រា ១។

[179] អ.ស.ក មាត្រ ៤០(៣)។

[180] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១។

ទោះបីជាយ៉ាងនេះក្តី រដ្ឋភាគីត្រូវបានតម្រូវឱ្យលើកកម្ពស់វិធានការដោះស្រាយជាមួយកុមារដែលមានទំនាស់នឹងច្បាប់ដោយមិនឈានទៅរកដំណើរការនីតិវិធីតុលាការ "នៅពេលដែលសមស្រប"។[181] លើសពីនេះ ការសម្រេចមួយចំនួនគួរត្រូវបានធ្វើដូចជា ការថែទាំ ការណែនាំ និងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យ ការផ្តល់ប្រឹក្សា ការព្យួរទោសសាកល្បង ការថែទាំជំនួស វិធានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធានាថាកុមារត្រូវបានដោះស្រាយដោយគិតគូរពីសុខុមាលភាពរបស់ពួកគេ ហើយថែមទាំងស្របទៅតាមកាលៈទេសៈ និងបទល្មើសរបស់ពួកគេផងដែរ។[182] ច្បាប់កម្ពុជាបានបញ្ញត្តិបន្ថែមពីការប្រព្រឹត្តិលើកុមារទំនាស់នឹងច្បាប់ខុសៗគ្នានៅក្នុងផ្នែកសំខាន់ៗជាច្រើន។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តក្នុងឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារទំនាស់នឹងច្បាប់។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ

ច្បាប់កម្ពុជាបានកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌចាប់ពី ១៤ ឆ្នាំ ដែលស្របគ្នាទៅនឹងការអនុវត្តរបស់រដ្ឋផ្សេងទៀតជាអន្តរជាតិ។[183] នេះមានន័យថាគ្មានកុមារណាម្នាក់ក្រោមអាយុដែលបានកំណត់នេះនឹងត្រូវបានតុលាការជំនុំជម្រះ នៅពេលមានបទល្មើសកើតឡើងនោះទេ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវស្វែងរកភស្តុតាងដើម្បីកំណត់អាយុរបស់កុមារដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដែលរួមមានដូចជា ស្វែងរកសំបុត្រកំណើត ឬឯកសារបញ្ជាក់កំណើត ឬប្រើប្រាស់មធ្យោបាយដែលអាចទុកចិត្តបានផ្សេងទៀតដែលតុលាការអាចទទួលយកបានដើម្បីកំណត់អាយុរបស់ពួកគេ ក្នុងករណីដែលគ្មានឯកសារបញ្ជាក់កំណើត។ ករណីមានការសង្ស័យណាមួយទាក់ទងនឹងអាយុរបស់កុមារ ត្រូវតែដោះស្រាយឱ្យបានត្រឹមត្រូវដោយគិតពីប្រយោជន៍របស់កុមា។[184] តុលាការត្រូវតែផ្ទៀងផ្ទាត់អាយុរបស់កុមារទំនាស់នឹងច្បាប់ពាក់ព័ន្ធនឹងសំណុំរឿងដែលខ្លួនទទួលបន្ទុកក្នុងការជំនុំជម្រះ។ ប្រសិនបើអាចកំណត់បានថា កុមារដែលរងការចោទប្រកាន់មានអាយុក្រោម ១៤ ឆ្នាំ នៅពេលបទល្មើសកើតឡើង ឬប្រសិនបើមានការសង្ស័យអំពីអាយុរបស់ពួកគេនៅពេលបទល្មើសកើតឡើង នោះចៅក្រមត្រូវឱ្យពួកគេរួចផុតពីបទចោទភ្លាមៗ។

នៅឆ្នាំ២០២៥ មានជនជាប់ចោទចំនួន ៩ នាក់ ក្នុងចំណោម ៥៧៣ នាក់ គឺជាកុមារនៅពេលបទល្មើសកើតឡើង។ ក្នុងចំណោមកុមារទំនាស់នឹងច្បាប់ទាំងប្រាំបួននាក់នោះ មានប្រុសប្រាំបីនាក់ និងស្រីម្នាក់ ហើយម្នាក់មានអាយុចន្លោះពី ១៤ ដល់ ១៥ ឆ្នាំ និងអ្នកផ្សេងទៀតមានអាយុចន្លោះពី ១៦ ដល់ ១៧ ឆ្នាំ។ ក្នុងចំណោមនោះ មានចំនួនប្រាំបីនាក់នៅសាលាឧទ្ធរណ៍បាត់ដំបង និងម្នាក់ទៀតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ មិន

---

[181] អ.ស.ក មាត្រា ៤០ (៣); គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ១៣។

[182] អ.ស.ក មាត្រា ៤០ (៤)។

[183] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ២១ ក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា៣៨ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

[184] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៧។

មានករណីកុមារទំនាស់នឹងច្បាប់ដែល ម.ស.ម.ក បានសង្កេតនៅសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍ព្រះសីហនុទេ។

ក្រាហ្វលេខទី២៨៖ អាយុរបស់កុមារដែលរងការចោទប្រកាន់នៅពេលមានបទល្មើសកើតឡើង[185]



សិទ្ធិមានសេរីភាព និងការសន្មតជាមុនថាគ្មានទោស

វិធានការឃុំខ្លួន មិនគួរត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់នោះទេ លើកលែងតែសំណុំរឿងធ្ងន់ធ្ងរបំផុត និងដាក់ឱ្យកុមារចូលទៅក្នុងសហគមន៍ បន្ទាប់ពីការពិចារណាដោយយកចិត្តទុកដាក់។[186]

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងយ៉ាងច្បាស់ថា ការឃុំខ្លួនលើកុមារទំនាស់នឹងច្បាប់ គឺជាវិធានការចុងក្រោយបំផុត និងចែងថាសាលាឧទ្ធរណ៍ត្រូវពិចារណាដោះលែងកុមារដែលជាប់ឃុំឱ្យមានសេរីភាពដើម្បីការពារឧត្តមប្រយោជន៍របស់ពួកគេ។[187] លើសពីនេះ មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបានចែងថា អនីតិជនដែលបានប្រព្រឹត្តបទល្មើសត្រូវជាកម្មវត្ថុនៃ "វិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ"។ មាត្រា ៤០ នៃក្រមនេះ បន្តចែងថា វិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភ រួមមាន ដូចជា (១) ការប្រគល់ អនីតិជនឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សា អនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត (២) ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន (៣) ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន (៤) ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស (៥) ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

---

[185] ទិន្នន័យនេះផ្អែកលើចំនួនកុមារទំនាស់នឹងច្បាប់សរុបចំនួន ០៩ នាក់ ដែលពាក់ព័ន្ធនឹងសំណុំរឿងចំនួន ៤២២ ដែលបានសង្កេតនៅឆ្នាំ២០២៥។

[186] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៨៦។

[187] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៣៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា ៥៧។

ទោះបើជាមានបទប្បញ្ញត្តិទាំងនេះក៏ដោយ ការសង្កេតសវនាការរបស់ ម.ស.ម.ក បានបង្ហាញពីការប្រើប្រាស់វិធានការឃុំខ្លួនស្ទើរតែជាទម្លាប់នៅក្នុងករណីពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់។

ទោះបីជាមានបទប្បញ្ញត្តិច្បាស់លាស់ក៏ដោយ ការប្រើប្រាស់វិធានការឃុំខ្លួនស្ទើរតែជាទម្លាប់ទោះក្នុងករណីកុមារទំនាស់នឹងច្បាប់ក៏ដោយ។ នៅឆ្នាំ២០២៥ កុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំមានចំនួន ៨៩% (៨ នាក់ ក្នុងចំណោម ៩ នាក់)។ កុមារទំនាស់នឹងច្បាប់ដែលជាប់ឃុំមានចំនួន ៥៥% នៅឆ្នាំ២០២៤ មានភាពប្រសើរបើធៀបនឹងឆ្នាំ២០២៣ មានចំនួន ៨០,៨%។

តួលេខនេះអាចបង្ហាញថា ច្បាប់ស្តីពីយុត្តិធម៌អនីតិជនមិនទាន់បានអនុវត្តឱ្យប្រសើរនៅឡើយទេ ទោះបីជាច្បាប់នេះបានចែងថាវិធានការឃុំខ្លួនជាជម្រើសចុងក្រោយ។[188] ការប្រើវិធានការមិនឃុំខ្លួន គួរត្រូវបានកំណត់ជាអាទិភាព។ នៅឆ្នាំ២០២៥ ម.ស.ម.ក មិនបានស្តាប់សាលដីកានៃសំណុំរឿងកុមារទំនាស់នឹងច្បាប់នោះទេដូចគ្នានឹងឆ្នាំ២០២៤ ដែរ ពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ថាតើចៅក្រមបានពិចារណាកាត់ទោសមិនដាក់ពន្ធនាគារ ឬដាក់ពន្ធនាគារនោះទេ។ នៅឆ្នាំ២០២៥ មានកុមារទំនាស់នឹងច្បាប់ចំនួនប្រាំបីនាក់ត្រូវបានជំនុំជម្រះនៅសាលាឧទ្ធរណ៍បាត់ដំបង និងមួយនាក់ទៀតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ។ គួរកត់សម្គាល់ថាឆ្នាំ២០២៣ ចៅក្រមបានពិចារណាផ្តន្ទាទោសជាជម្រើសមិនដាក់ពន្ធនាគារមានចំនួន ២៧%។

មានការធ្លាក់ចុះគួរកត់សម្គាល់នៃចំនួនកុមារទំនាស់នឹងច្បាប់ ដែលបង្ហាញខ្លួនក្នុងឯកសណ្ឋានពន្ធនាគារពណ៌ខៀវពី ៦០% នៅឆ្នាំ២០២៤ មក ៥០% នៅឆ្នាំ២០២៥ (៤ នាក់ ក្នុងចំណោម ៨ នាក់) ចំនួន ៤ នាក់នៅសាលាឧទ្ធរណ៍បាត់ដំបង ទិន្នន័យនេះមានភាពប្រសើរបើធៀបនឹងឆ្នាំ២០២៤។ វត្តមានក្នុងសវនាការជាមួយនឹងឯកសណ្ឋានពន្ធនាគារ អាចជាបទពិសោធន៍ដែលមានការប៉ះទង្គិចដល់ផ្លូវចិត្តរបស់កុមារ ដូច្នោះចាំបាច់ត្រូវការពារឧត្តមប្រយោជន៍របស់កុមារឱ្យបានពេញលេញនៅគ្រប់ដំណើរការនីតិវិធីទាំងមូល។ ម.ស.ម.ក សូមស្នើឱ្យសាលាឧទ្ធរណ៍គោលដៅ និងអគ្គនាយកដ្ឋានពន្ធនាគារ ពង្រឹងការប្រតិបត្តិល្អបន្ថែមទៀត ដើម្បីធានាថាកុមារទំនាស់នឹងច្បាប់អាចចូលរួមក្នុងសវនាការដោយស្លៀកឯកសណ្ឋានស៊ីវិល។

តួលេខទី២៩៖ ភាគរយនៃជនជាប់ចោទជាកុមារដែលត្រូវបានឃុំខ្លួននៅសាលាឧទ្ធរណ៍ភ្នំពេញ (២០១៤-២០២១) និងតុលាការគោលដៅទាំងបួន (ពីឆ្នាំ២០២២)[189]

---

[188] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា៥។

[189]ទិន្នន័យនេះ ផ្អែកលើចំនួនកុមារជំទាស់នឹងច្បាប់ដែលពាក់ព័ន្ធនឹងសំណុំរឿង ដែលបានសង្កេតក្នុងអំឡុងពេលធ្វើការរាយការណ៍នីមួយៗ ដោយហេតុហេតុថាសាលាឧទ្ធរណ៍ភ្នំពេញមានយុត្តាធិការគ្របដណ្តប់ទូទាំងប្រទេស មុនពេលដែលសាលាឧទ្ធរណ៍ទាំងបីចាប់ផ្តើមដំណើរការក្នុងខែមេសា ឆ្នាំ២០២០ ដូច្នេះតួលេខចុងក្រោយក្នុងអំឡុងពេលធ្វើបាយការណ៍ឆ្នាំ២០១៩/២០២០ អាចត្រូវបានចាត់ទុកថាជាការឆ្លុះបញ្ចាំងពីនិន្នាការថ្នាក់ជាតិ។ តួលេខចាប់ពីឆ្នាំ២០២២ ទៅមុខគឺ ម.ស.ម.ក បានចាប់ផ្តើមការសង្កេតសវនាការរបស់ខ្លួននៅតុលាការទាំងបីបន្ថែមទៀត។ តួលេខនៅឆ្នាំ២០២១ ត្រូវបានបង្ហាញផងដែរដើម្បីបញ្ជៀសគម្លាតនៃទិន្នន័យ ហើយឆ្លុះបញ្ចាំងតែអំពីស្ថានភាពនៅក្នុងដែលស្ថិតក្រោមយុត្តាធិការរបស់សាលាឧទ្ធរណ៍ភ្នំពេញប៉ុណ្ណោះ។



ការបែងចែកជនជាប់ឃុំជាកុមារក្នុងពន្ធនាគារ

បទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌កុមារចែងថា កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពត្រូវដាក់ឱ្យដាច់ដោយឡែកពីជនជាប់ឃុំជាមនុស្សពេញវ័យ និងត្រូវនៅក្នុងកន្លែងដាច់ដោយឡែកពីមន្ត្រីដែលទទួលបន្ទុកហើយមន្ត្រីទាំងនោះបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងប្រតិបត្តិតាមគោលនយោបាយ និងអនុវត្តប្រកបដោយកុមារមេត្រី។ ករណីលើកលែងអាចអនុវត្តបានតែដើម្បីឧត្តមប្រយោជន៍របស់កុមារដែលត្រូវឃុំខ្លួនប៉ុណ្ណោះ។[190] ច្បាប់ស្តីពីយុត្តិធ៌មអនីតិជនចែងថា កុមារដែលត្រូវបានដកហូតសេរីភាពត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកជាប់ឃុំពេញវ័យ ហើយត្រូវឃុំខ្លួននៅក្នុងមជ្ឈមណ្ឌលស្តារយុវនីតិសម្បទាដែលគ្រប់គ្រងដោយមន្ត្រីដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវស្តីពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ បទដ្ឋានសិទ្ធិកុមារជាតិ និងអន្តរជាតិ និងការប្រព្រឹត្តិចំពោះកុមារជាប់ឃុំ។ ច្បាប់នេះបានចែងបន្ថែមទៀតថា អនីតិជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ត្រូវដាក់ឱ្យនៅដាច់ដោយឡែកពីទណ្ឌិតជាកុមារ។[191] ជាចំណុចគួរឱ្យកត់សម្គាល់ សម្រាប់រយៈពេលបួនឆ្នាំជាប់ៗគ្នានេះ គ្មានការបង្ហាញថាកុមារទំនាស់នឹងច្បាប់ណាម្នាក់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតក្នុងឆ្នាំ២០២៥ ត្រូវបានឃុំខ្លួនជាមួយជនជាប់ឃុំពេញវ័យនោះទេ។

ការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់

យោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ កុមារមានសិទ្ធិទទួលបានការគោរពឯកជនភាពរបស់ពួកគេនៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី រាប់បញ្ចូលចាប់ពីដំណាក់កាលដំបូងនៃការអនុវត្តច្បាប់ រហូតដល់សេចក្តីសម្រេចជាស្ថាពរ។[192] សិទ្ធិនេះ ក៏ត្រូវអនុវត្តផងដែរ ប្រសិនបើកុមារត្រូវបានចោទប្រកាន់ ដូចជាការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការឃាត់ខ្លួន/ឃុំឃាំង ឬការដកហូតសេរីភាព។ ហេតុផលជាមូលដ្ឋាននៃសិទ្ធិនេះ គឺដើម្បីជៀសវាងការប៉ះពាល់ដែលបណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬការបង្ខូចកេរ្តិ៍ឈ្មោះ

[190] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៩២ និង៩៣។

[191] ច្បាប់យុត្តិធម៌អនីតិជន ជំពូកទី១៣ និង១៤។

[192]អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា៤០(២)(vii) មាត្រា១៦ មាត្រា ៤០(១) គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៦, ៧៩។

ណាមួយ។ ដូច្នេះ សវនាការលើកុមារទំនាស់នឹងច្បាប់ត្រូវធ្វើឡើងជាអសាធារណៈ។ ក្នុងបរិបទនៃច្បាប់កម្ពុជា ជាពិសេស ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងយ៉ាងច្បាស់ថា ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមនៃរឿងក្តីអនីតិជនត្រូវធ្វើក្នុងសវនាការជាអសាធារណៈ។[193]

ឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ ឬកុមាររងគ្រោះអាចត្រូវបានការពារបន្ថែមទៀតដោយមិនបង្ហាញអត្តសញ្ញាណរបស់ពួកគេ តាមរយៈការដាក់បាំងរនាំង ឬប្រើមធ្យោបាយផ្សេងទៀតក្នុងពេលផ្តល់សក្ខីកម្ម។ ការប្រើប្រាស់ឧបករណ៍នានា ដូចជាសវនាការតាមប្រព័ន្ធវីដេអូ ឬសវនាការអសាធារណៈ គួរតែត្រូវបានពិចារណា។ ប្រសិនបើសាលក្រម ឬការផ្តន្ទាទោសត្រូវប្រកាសជាសាធារណៈ នោះអត្តសញ្ញាណរបស់កុមារ មិនគួរត្រូវបានបង្ហាញឡើយ។[194] ជាចុងក្រោយ រាល់ឯកសារទាក់ទងនឹងកុមារ គួរតែត្រូវបានរក្សាការសម្ងាត់យ៉ាងតឹងរឹង និងមិនបើកចំហដល់តាគីទីបី លើកលែងចំពោះតែអ្នកដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការស៊ើបអង្កេត និងការវិនិច្ឆ័យលើសំណុំរឿង។[195] ប្រការនេះត្រូវធានាឱ្យបាន ទោះបីជានៅពេលកុមារឈានដល់អាយុ ១៨ ឆ្នាំ ក៏ដោយ។[196]

នៅឆ្នាំ២០២៥ គួរឱ្យកត់សម្គាល់ជាវិជ្ជមានចំពោះការការពារឯកជនភាពរបស់កុមារទំនាស់នឹងច្បាប់ដែលមានភាពប្រសើរឡើង។ នៅឆ្នាំ២០២៥ វិធានការការពារឯកជនភាពនេះ តាមរយៈសវនាការត្រូវបានធ្វើឡើងជាអសាធារណៈ មានចំនួន ៨៩% នៃចំនួនកុមារទំនាស់នឹងច្បាប់ (៨ នាក់ ក្នុងចំណោម ៩ នាក់)ជាចំនួនកើនឡើងពី ៧៧,៨% នៅឆ្នាំ២០២៤ និង៥២,៩% នៅឆ្នាំ២០២៣។ នៅឆ្នាំ២០២៥ មានមួយសំណុំរឿងដែលមិនមានវិធានការការពារឯកជនភាពរបស់កុមារទំនាស់ច្បាប់នៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ហើយនេះក៏ជាសំណុំរឿងតែមួយគត់ដែលពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ត្បូងឃ្មុំ ដូច្នេះសង្ឃឹមថា សំណុំរឿងកុមារទំនាស់នឹងច្បាប់ផ្សេងទៀតនឹងមិនអនុវត្តបែបនេះទេ។

---

[193] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មាត្រា៤៧។

[194] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[195] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៦៧។

[196] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ សេចក្តីពន្យល់ទូទៅលេខ ២៤ វាក្យខណ្ឌ ៧០។

៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ជាលើកដំបូងហើយ ចាប់តាំងពី ម.ស.ម.ក បានសង្កេតសវនាការសំណុំរឿងព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ទាំងបួន ដែលសាលាឧទ្ធរណ៍បានលើកកម្ពស់សិទ្ធិចំនួនប្រាំមួយ ក្នុងចំណោមសិទ្ធិចំនួនដប់បួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ នេះជាការវិឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលសិទ្ធិរបស់ជនជាប់ចោទក្នុងដំណើរការជំនុំជម្រះត្រូវបានតុលាការគោលដៅលើកកម្ពស់បានខ្ជាប់ខ្ជួន។ ទោះជាបែបនេះក្តី ក៏មានសិទ្ធិមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ នៅបន្តការខកខានក្នុងការលើកកម្ពស់ឱ្យបានពេញលេញក្នុងចំណោមសាលាឧទ្ធរណ៍ទាំងបួន ក្នុងនោះរួមមាន៖ សិទ្ធិមានសេរីភាព សិទ្ធិបង្ហាញភស្តុតាង សិទ្ធិទទួលបានមេធាវី និងសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ។ គួរលើកទឹកចិត្តចំពោះវិឌ្ឍនភាពនៃការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ តែប្រសិនបើសមាសភាគណាមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មិនត្រូវបានគោរពពេញលេញនោះទេ គឺនាំឱ្យការទទួលបានយុត្តិធម៌មិនពេញលេញ។ ដូច្នោះ បើសិទ្ធិមានសេរីភាព សិទ្ធិបង្ហាញភស្តុតាង សិទ្ធិទទួលបានមេធាវី និងសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ នៅតែមានការខកខានក្នុងការលើកកម្ពស់ គឺមានន័យថាសិទ្ធិរបស់ភាគីជនជាប់ចោទក្នុងដំណើរការនីតិវិធីសវនាការមិនត្រូវបានគោរពពេញលេញ។

ដូចបានបង្ហាញក្នុងរបាយការណ៍កន្លងមក វិធានការមួយចំនួនខាងលើអាចត្រូវបានដោះស្រាយតាមរយៈវិធីសាមញ្ញ។ និងអាចចំណាយធនធានតិច។ វិធីដទៃទៀត គឺត្រូវផ្តល់ការបណ្តុះបណ្តាល និងវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញសម្រាប់ចៅក្រម និងមេធាវីស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងធានាថាអ្នកទាំងនោះបានយល់ដឹងកាន់តែប្រសើរ ដើម្បីចំណាត់ការចំពោះសំណុំរឿងដែលខ្លួនទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

ដើម្បីធានានូវប្រសិទ្ធភាពនៃការបណ្តុះបណ្តាលនេះ ចៅក្រម និងមេធាវី ត្រូវអនុវត្តចំណេះដឹងប្រកបដោយសង្គតិភាព និងមិនអាស្រ័យលើសំណុំរឿង ឬការយល់ឃើញរបស់ខ្លួននោះទេ តែផ្ទុយទៅវិញ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចាំបាច់ត្រូវអនុវត្ត។ ម.ស.ម.ក. លើកទឹកចិត្តថា ការធ្វើឱ្យប្រសើរនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គួរមានលក្ខណៈជាប្រព័ន្ធ ជាពិសេស សិទ្ធិសន្មតទុកជាមុនថាគ្មានទោស និងសិទ្ធិទទួលបានមេធាវី តម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន រួមមានការសម្របសម្រួល និងការចូលរួមពីតុលាការ ក្រសួងយុត្តិធម៌ អគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ និងភាគីពាក់ព័ន្ធផ្សេងទៀត។

៦.១ អនុសាសន៍រួម

៦.១.១ ក្រសួងយុត្តិធម៌គួរបន្តរៀបចំកិច្ចប្រជុំជាទៀងទាត់ ស្តីពីការអនុវត្តជាក់ស្តែងនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមួយចៅក្រមសាលាឧទ្ធរណ៍ ដើម្បីលើកកម្ពស់ការគោរពគោលគំនិតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ផ្អែកលើមូលដ្ឋាននៃបទដ្ឋានជាតិ និងអន្តរជាតិ។

៦.១.២ ក្រសួងយុត្តិធម៌គួរបង្កើតទម្រង់បទដ្ឋានសម្រាប់សេចក្តីសម្រេច និងបញ្ជូនទៅគ្រប់តុលាការទាំងអស់ដើម្បីអនុវត្ត។ ទម្រង់នេះគួរមានព័ត៌មានដូចខាងក្រោម ដើម្បីជានាថារបាយការណ៍សង្ខេបដែលចៅក្រមប្រធានក្រុមប្រឹក្សាអាន គឺមានភាពពេញលេញ៖

១. បទល្មើសដែលបានចោទប្រកាន់លើជនជាប់ចោទ និងមាត្រាច្បាប់ពាក់ព័ន្ធ

២. កាលបរិច្ឆេទ ពេលវេលា ទីកន្លែងដែលបទល្មើសកើតឡើង និងភាគីពាក់ព័ន្ធ

៣. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលជនជាប់ចោទមានសិទ្ធិទទួលបាន។

ជាពិសេស ទម្រង់បទដ្ឋាននៃសេចក្តីសម្រេច គួររំឭកចៅក្រមអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការសន្មតទុកជាមុនថាគ្មានទោសរហូតដល់មានសេចក្តីសម្រេចជាស្ថាពរ និងអាជ្ញាអស់ជំនុំ ព្រមទាំងប្រាប់ថាបន្ទុកនៃភស្តុតាង គឺព្រះរាជអាជ្ញាជាអ្នកទទួលខុសត្រូវ។

៦.១.៣ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ថាតើពួកគេយល់ដឹងអំពីបទចោទប្រកាន់ និងសិទ្ធិរបស់ពួកគេដែរឬទេ។

៦.២ អនុសាសន៍ស្តីពីសិទ្ធិទទួលបានមេធាវី

៦.២.១ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឱ្យជនជាប់ចោទទាំងអស់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទទួលបានមេធាវី ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

៦.២.២ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីអនុញ្ញាតឱ្យជនជាប់ចោទដែលគ្មានមេធាវី អាចពិនិត្យមើលសំណុំរឿងរបស់ខ្លួនមុនពេលចូលសវនាការ និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការការពារខ្លួនដោយខ្លួនឯង។

៦.២.៣ ចៅក្រមគួរប្រាប់ និងពន្យល់ដល់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីរបស់ពួកគេ ប្រសិនបើពួកគេមិនមានមេធាវីការពារ។

៦.២.៤ តុលាការគួរធានាថា មិនមានទំនាស់ផលប្រយោជន៍ ក្នុងករណីដែលមេធាវីម្នាក់ការពារឱ្យជនជាប់ចោទច្រើននាក់នៅពេលសវនាការ។

៦.២.៥ ក្រសួងយុត្តិធម៌ គួរបន្តជូនដំណឹងដល់សាធារណជន អំពីសិទ្ធិទទួលបានជំនួយផ្នែកច្បាប់ដែលរដ្ឋជាអ្នកធ្វើរងតាមរយៈការផ្សព្វផ្សាយនៅតាមប៉ុស្តិ៍នគរបាល ពន្ធនាគារ និងអគារតុលាការផងដែរ។

៦.២.៦ ក្រសួងយុត្តិធម៌គួរបង្កើតគោលនយោបាយជាតិ ស្តីពីជំនួយផ្នែកច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីជំនួយផ្នែកច្បាប់ និងគួរអនុម័តជាផ្លូវការត្រឹមឆ្នាំ២០២៦។

៦.៣ អនុសាសន៍ចាក់ចងនឹងសិទ្ធិមានសេរីភាព

៦.៣.១ ក្រសួងយុត្តិធម៌ គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៣០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថា មាត្រានេះស្របនឹងមាត្រា ៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន (ការឱ្យរួចផុតពីបទចោទ) ដើម្បីលើកកម្ពស់សិទ្ធិមានសេរីភាពរបស់ជនជាប់ចោទ ដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនពីបទចោទ និងត្រូវបង្គាប់ឱ្យដោះលែងជនជាប់ចោទនោះភ្លាម ទោះបីជាតំណាងអយ្យការប្តឹងនឹងសេចក្តីសម្រេចនេះក៏ដោយ។

៦.៣.២ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួសជាជាងការឃុំខ្លួន រួមទាំងការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងអនុលោមតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ចំណុច ១៦.៣ ដើម្បីធានាបាននូវការលើកលែងការឃុំខ្លួន និងរក្សានូវសិទ្ធិមានសេរីភាព ដោយផ្អែកលើការវាយតម្លៃនៃសំណុំរឿងនីមួយៗ។

៦.៣.៣ ចៅក្រមគួរលើកកម្ពស់ការប្រើប្រាស់ទោសជំនួស ជាជាងការកាត់ទោសឱ្យជាប់ពន្ធនាគារ ជាពិសេសសំណុំរឿងដែលជនជាប់ចោទជាកុមារ។

៦.២.៤ តុលាការត្រូវធានាថា ជនជាប់ចោទ ជាពិសេសជនជាប់ឃុំត្រូវបាននាំយកមកជំនុំជម្រះភ្លាមៗតាមដែលអាចធ្វើទៅបាន និងការពន្យារពេលដោយគ្មានសំអាងហេតុត្រឹមត្រូវប៉ះពាល់ដល់សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងការផ្តល់យុត្តិធម៌យ៉ាងឆាប់រហ័ស។

៦.៤ អនុសាសន៍ស្តីពីសិទ្ធិបដ្ឋាញ្ញភស្តុតាង

៦.៤.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទអំពីសិទ្ធិបង្ហាញភស្តុតាងរបស់ពួកគេ ក្នុងលក្ខខណ្ឌដូចគ្នាទៅនឹងការបង្ហាញភស្តុតាងប្រឆាំងនឹងពួកគេដែរ។

៦.៤.២ ចៅក្រមគួរបង្គាប់ឱ្យសាក្សីចាកចេញពីបន្ទប់សវនាការ រហូតទាល់តែពួកគេត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មទើបអាចត្រឡប់មកវិញបាន ដែលនេះជាមធ្យោបាយមួយដើម្បីធានាថា សាក្សីមិនរងឥទ្ធិពលពីភស្តុតាង និងសក្ខីកម្មផ្សេងទៀតដែលបានបង្ហាញនៅពេលសវនាការ។

៦.៤.៣ ចៅក្រមត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្នថា តើភស្តុតាងដែលបានបង្ហាញមានលក្ខណៈហួសពីវិមាត្រិសង្ស័យថាជនជាប់ចោទមានពិរុទ្ធភាពដែរឬទេ។ ប្រសិនបើមានការបកស្រាយថាភស្តុតាងដែលស៊ីចង្វាក់គ្នានឹងភាពគ្មានទោសរបស់ជនជាប់ចោទ ដូច្នោះជនជាប់ចោទត្រូវតែរួចផុតពីបទចោទ។

៦.៤.៤ ក្រសួងយុត្តិធម៌ គួររៀបចំបង្កើតគោលការណ៍ណែនាំច្បាស់លាស់ទាក់ទងនឹងការបង្ហាញ និងការវាយតម្លៃភស្តុតាង ដោយផ្អែកលើការអនុវត្តរបស់ អ.វ.ត.ក[197] និងធានាថា ចៅក្រមទាំងអស់ទទួលបានការបណ្តុះបណ្តាលសមស្រប។

៦.៥ អនុសាសន៍ទាក់ទងនឹងសិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់

៦.៥.១ ចៅក្រមគួរអានប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់លើពួកគេ និងផ្តល់ព័ត៌មានពាក់ព័ន្ធនានាដូចជាកាលបរិច្ឆេទ ទីកន្លែង ភាគីពាក់ព័ន្ធ និងមាត្រាច្បាប់ពាក់ព័ន្ធ។ ការណ៍នេះមានសារៈសំខាន់ជាពិសេសក្នុងករណីដែលបទចោទប្រកាន់អាចត្រូវបានប្តូរ ឬកែប្រែចាប់តាំងពីពេលចាប់ខ្លួន/ចោទប្រកាន់ដំបូង។

៦.៥.២ ចៅក្រមគួរសាកសួរជនជាប់ចោទដោយផ្ទាល់ តើពួកគេយល់ដឹងអំពីបទចោទប្រកាន់មកលើពួកគេ និងសិទ្ធិរបស់ពួកគេដែរឬទេ។

៦.៥.៣ ចៅក្រមគួរផ្តល់ការពន្យល់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីសិទ្ធិទទួលបានជំនុំជម្រះរបស់ជនជាប់ចោទ ទោះបីជាពួកគេត្រូវបានពន្យល់រួចហើយនៅសាលាដំបូងក៏ដោយ។

៦.៦ អនុសាសន៍សិទ្ធិមានឥតគិតថ្លៃក្នុងសវនាការ

៦.៦.១ តុលាការ និងអគ្គនាយកដ្ឋានពន្ធនាគារ គួរពិគ្រោះយោបល់ និងសម្របសម្រួលគ្នា ដើម្បីដោះស្រាយបញ្ហាកស្តុការ និងទំនាក់ទំនងឱ្យបានឆាប់តាមដែលអាចធ្វើទៅបានពាក់ព័ន្ធនឹងទីកន្លែងដែលជនជាប់ចោទត្រូវបានឃុំខ្លួន ដើម្បីធានាឱ្យជនជាប់ចោទមានវត្តមាននៅពេលសវនាការ។

៦.៦.២ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ព័ត៌មានអំពីការផ្ទេរជនជាប់ឃុំ គឺត្រូវបានបញ្ជូនជាទៀងទាត់ទៅកាន់មហាអយ្យការ ដើម្បីធានាថាតុលាការនឹងផ្តល់ព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលានៃសវនាការនៃបណ្តឹងឧទ្ធរណ៍ទៅដល់មណ្ឌលអប់រំកែប្រែដែលឃុំខ្លួនជនជាប់ចោទឱ្យបានត្រឹមត្រូវ។

៦.៦.៣ ចៅក្រមគួរពន្យារពេលសវនាការណាមួយ ប្រសិនបើជនជាប់ចោទមិនមានវត្តមាន ទោះបីជាពួកគេមានមេធាវីការពារក៏ដោយ លុះត្រាតែពួកគេបានលះបង់សិទ្ធិមានវត្តមានជាផ្លូវការរបស់ខ្លួន។

៦.៧ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

៦.៧.១ ចៅក្រមត្រូវប្រាប់ជនជាប់ចោទឱ្យបានយល់ច្បាស់ អំពីសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសរបស់ពួកគេ រហូតទាល់តែមានសេចក្តីសម្រេចជាស្ថាពរ និងអំពីបន្ទុកនៃភស្តុតាងជាភារកិច្ចរបស់

---

[197] ការអនុវត្តរបស់ អ.វ.ត.ក អាចជាការណែនាំដ៏មានប្រយោជន៍ ជាពិសេសវិធានផ្ទៃក្នុងរបស់ខ្លួន ដូចជាវាក្យខណ្ឌ២០៤ ដល់ ២០៩ នៃសំណុំរឿងលេខ ០០២/០១ សាលក្រមរបស់អង្គបុរេជំនុំជម្រះ សូមមើល "សាលក្រមអង្គបុរេជំនុំជម្រះ"; អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល (ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦) សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-ECCC/SC, https://tinyurl.com/3xyzz4wz

តំណាងមហាអយ្យការ ហើយជនជាប់ចោទមានសិទ្ធិនៅស្ងៀម ដែលចៅក្រមមិនអាចប្រើប្រាស់ភាពនៅស្ងៀមនេះប្រឆាំងនឹងជនជាប់ចោទឡើយ។

៦.៧.២ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ គួរផ្សព្វផ្សាយអំពីគោលការណ៍ណែនាំច្បាស់លាស់ទៅតុលាការដែលបញ្ជាក់ថា ជនជាប់ចោទដែលត្រូវបានឃុំខ្លួន ត្រូវអនុញ្ញាតឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងសម្លៀកបំពាក់ស៊ីវិលធម្មតា។

៦.៧.៣ អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ជនជាប់ចោទដែលត្រូវបាននាំមកតុលាការមិនត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ខៀវទេ។

៦.៧.៤ ចៅក្រមគួរអនុញ្ញាតឱ្យជនជាប់ចោទ ដែលត្រូវបាននាំមកតុលាការក្នុងឯកសណ្ឋានទណ្ឌិតត្រូវស្លៀកពាក់ឯកសណ្ឋានស៊ីវិលជំនួសវិញមុនពេលសវនាការ។

៦.៨ អនុសាសន៍ទាក់ទងនឹងសិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព

៦.៨.១ តុលាការត្រូវតែស៊ើបអង្កេតភ្លាមៗ ដោយហ្មត់ចត់ និងមានប្រសិទ្ធភាពចំពោះការលើកឡើងរបស់ជនជាប់ចោទថាមានការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពមុននឹងចេញសេចក្តីសម្រេច។

៦.៨.២ តុលាការត្រូវធានាថា ប្រសិនបើមានការលើកឡើងថាមានការបង្ខិតបង្ខំ ការគាបសង្កត់ ឬការធ្វើទារុណកម្មណាមួយ ដូចនេះ រាល់កស្តុតាង ឬចម្លើយសារភាពដែលទទួលបានតាមវិធីបែបនេះ គឺមិនអាចទទួលយកបានឡើយ ហើយត្រូវធ្វើការជំនុំជម្រះឡើងវិញ និងធានាថាមានការជួសជុលសំណងសមរម្យដល់ជនរងគ្រោះ។

៦.៨.៣ ក្រសួងយុត្តិធម៌គួរពិចារណាស្នើធ្វើវិសោធនកម្មមាត្រា ៩៨ នៃក្រមនេះពាក់ព័ន្ធនឹងការឃាត់ខ្លួនដោយនគរបាល ដោយលុបចេញរយៈពេល ២៤ ម៉ោងបន្ទាប់ពីសម្រេចថាឃាត់ខ្លួន ដើម្បីឱ្យជនសង្ស័យធ្វើការសន្ទនាជាមួយមេធាវី ឬបុគ្គលដែលខ្លួនជ្រើសរើសបានឆាប់ដែលអាចធ្វើទៅបាន ។

៦.៩ អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានសេចក្តីសម្រេចមានសំអាងហេតុ

៦.៩.១ តុលាការត្រូវធានាថាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយសរសេរអក្សរកាត់ក្នុងករណីចាំបាច់ ដើម្បីការពារអត្តសញ្ញាណរបស់ជនជាប់ចោទ ជនរងគ្រោះ ឬសាក្សី ឬសម្រាប់ហេតុផលណាមួយផ្សេងទៀត។

៦.៩.២ ដោយអនុវត្តតាមរបស់ អ.វ.ត.ក[198] គួរបង្កើតក្របខ័ណ្ឌមួយដែលចៅក្រមមានកាតព្វកិច្ចក្នុងការប្រាប់និងពន្យល់អំពីសំអាងហេតុច្បាប់ និងកស្តុតាងលើមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួន ហើយធានាថាសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរមានសំអាងហេតុត្រូវបានផ្តល់ដល់ជនជាប់ចោទ។

៦.១០ អនុសាសន៍ទាក់ទងនឹងវិជ្ជាជីវៈរបស់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី

៦.១០.១ ចៅក្រមត្រូវធានាថាបានបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការស្តាប់សវនាការរបស់ខ្លួន ដើម្បីធានាថាសំណុំរឿងរបស់ខ្លួនត្រូវបានជំនុំជម្រះបានត្រឹមត្រូវ និងដោយហ្មត់ចត់។

៦.១០.២ ក្រសួងយុត្តិធម៌ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរធ្វើការរួមគ្នាដើម្បីពិនិត្យឡើងវិញលើក្រមសីលធម៌របស់ចៅក្រម និងធ្វើការកែសម្រួលតាមការចាំបាច់។ ការកែសម្រួលគួររាប់បញ្ចូលទាំងការហាមឃាត់លើការសន្ទនាតាមទូរស័ព្ទ និងគួរអនុញ្ញាតឱ្យមានការសម្រាករយៈពេលខ្លី ដើម្បីអនុញ្ញាតឱ្យចៅក្រម តំណាងមហាអយ្យការ និងមេធាវីអាចចាកចេញពីបន្ទប់សវនាការ ឬទទួលទូរស័ព្ទរបស់ខ្លួន។

៦.១១ អនុសាសន៍ទាក់ទងនឹងសិទ្ធិរបស់កុមារជំនាស់នឹងច្បាប់

៦.១១.១ ចៅក្រមគួរពន្លឿន និងពង្រឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាពិសេសមាត្រា ៤៧ ដែលតម្រូវឱ្យដំណើរការជំនុំជម្រះ និងការប្រកាសសេចក្តីសម្រេចត្រូវធ្វើឡើងជាអសាធារណៈ។

៦.១១.២ ចៅក្រមគួរអនុវត្តតាមការប្រតិបត្តិល្អរបស់ អ.វ.ត.ក និងអនុញ្ញាតឱ្យកុមារទំនាស់នឹងច្បាប់បង្ហាញខ្លួននៅចំពោះមុខតុលាការដោយប្រើប្រាស់សម្លៀកបំពាក់របស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងមូល។

៦.១១.៣ ចៅក្រមគួរកម្រិតការឃុំខ្លួនកុមារទំនាស់នឹងច្បាប់តែក្នុងករណីពិសេស នៅពេលដែលមិនមានជម្រើសផ្សេងទៀតប៉ុណ្ណោះ ហើយធានាថា ក្នុងករណីបែបនេះ រាល់វិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តដើម្បីគោរពសិទ្ធិរបស់កុមារទំនាស់នឹងច្បាប់។

៦.១១.៤ ក្រសួងយុត្តិធម៌គួរធានាថា ចៅក្រម និងព្រះរាជអាជ្ញា គួរទទួលបានការបណ្តុះបណ្តាលជាក់លាក់ទាក់ទងនឹងយុត្តិធម៌កុមារ។

៦.១១.៥ ចៅក្រមគួរពិនិត្យ និងប្រើប្រាស់វិធានការមិនឃុំខ្លួនកុមារទំនាស់នឹងច្បាប់ និងអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តន្ទាទោសលើកុមារដែលត្រូវបានទទួលស្គាល់ថាជាការបំពានច្បាប់ព្រហ្មទណ្ឌ ដូចនេះ ត្រូវផ្តោតសំខាន់លើការស្តារនីតិសម្បទាជាជាងការផ្តន្ទាទោសតែម្យ៉ាង ព្រមទាំងផ្តោតលើឧត្តមប្រយោជន៍របស់កុមារផងដែរ។

---

[198] សូមមើលជាពិសេស "សាលក្រមនៃអង្គបុរេជំនុំជម្រះ, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, អង្គជំនុំជម្រះតុលាការកំពូល, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦, សំណុំរឿងលេខ០០២/១៩-០៩-២០០៧-ECCC/SC, https://tinyurl.com/2amb8t57

៦.១១.៦ តុលាការគួរអនុវត្តវិធានការបង្វែរដែលតាមរយៈវិធាននេះ កុមារទំនាស់នឹងច្បាប់ទទួលបានជំនួយគាំទ្រ និងស្ថានីតិសម្បទាចូលក្នុងសហគមន៍វិញដែលជាវិធានមួយជំនួសឱ្យការចោទប្រកាន់ជាផ្លូវការ។ វិធាននេះ ត្រូវអនុវត្តចំពោះគ្រប់កុមារទំនាស់នឹងច្បាប់ទាំងអស់ដែលប្រព្រឹត្តបទល្មើសដំបូង លើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

៦.១១.៧ ក្រសួងយុត្តិធម៌ត្រូវពិនិត្យឡើងវិញលើច្បាប់ដែលមានស្រាប់ រួមទាំងច្បាប់ពាក់ព័ន្ធនឹងតុលាការ ដើម្បីធានាបាននូវការអនុលោមតាមបទដ្ឋានអន្តរជាតិស្តីពីប្រព័ន្ធយុត្តិធម៌កុមារ រួមមាន វិធានក្រុងប៉េកាំង គោលការណ៍ណែនាំរបស់អង្គការយូនីសេហ្វសម្រាប់កំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន[199] សៀវភៅណែនាំការអនុវត្តរបស់អង្គការយូនីសេហ្វសម្រាប់អនុសញ្ញាស្តីពីសិទ្ធិកុមារ[200] និងកំណែទម្រង់ច្បាប់របស់អង្គការយូនីសេហ្វ និងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ៕[201]

[199] អង្គការយូនីសេហ្វ "គោលការណ៍ណែនាំស្តីពីកំណែទម្រង់ច្បាប់ស្តីពីយុត្តិធម៌អនីតិជន" (ឆ្នាំ២០១១) https://tinyurl.com/3y34324u

[200] អង្គការយូនីសេហ្វ សៀវភៅណែនាំការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (ឆ្នាំ២០០៧) ទំព័រ ១០៧ https://tinyurl.com/yc3c7v8x

[201] អង្គការយូនីសេហ្វ "កំណែទម្រង់ច្បាប់ និងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ" ទំព័រ ៨៧, http://www.unicef-irc.org/publications/pdf/law_reform_crc_imp.pdf។